ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# មគ្គុទេសក៍សម្រាប់ការរៀបចំច្បាប់ ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ

# GUIDANCE
## FOR THE PREPARATION OF LAWS
## BASED ON THE 1991 OF THE UPOV CONVENTION

បោះពុម្ពដោយ
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
អគ្គនាយកដ្ឋានឧស្សាហកម្ម
នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម



UPOV

ការិយាល័យប្រភេទថ្មីនៃរុក្ខជាតិ និងជម្រុញការច្នៃប្រឌិត និងតក្កកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# មគ្គុទេសក៍សម្រាប់ការរៀបចំច្បាប់ ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ

## GUIDANCE

## FOR THE PREPARATION OF LAWS

## BASED ON THE 1991 OF THE UPOV CONVENTION

បោះពុម្ពដោយ
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
អគ្គនាយកដ្ឋានឧស្សាហកម្ម
នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម



ការិយាល័យប្រភេទថ្មីនៃរុក្ខជាតិ និងជម្រុញការច្នៃប្រឌិត និងឥក្កកម្ម

# មគ្គុទ្ទេសក៍សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ

អនុម័តដោយក្រុមប្រឹក្សា ក្នុងកិច្ចប្រជុំសាមញ្ញលើកទី៤៥របស់ខ្លួន
ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១១

# តារាងមាតិកា

**សេចក្តីផ្តើម**..........................................................................................................៥

**ជំពូកទី១ អត្ថបទគំរូនៃមាត្រានានាសម្រាប់ពិចារណាក្នុងការរៀបចំច្បាប់ដោយផ្អែកលើច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញា យូប៉ូវ**....................................៩

**ផ្នែកទី ១ និយមន័យ**..........................................................................................៩

មាត្រា១ និយមន័យ..........................................................................................៩

**ផ្នែកទី ២ ទូទៅ**..............................................................................................១១

មាត្រា ២ គោលបំណង..........................................................................................១១

មាត្រា ៣ អំបូរនិងប្រភេទពូជដែលត្រូវការពារ..........................................................១១

មាត្រា ៤ ប្រព្រឹត្តិកម្មជាតិ..........................................................................................១១

**ផ្នែកទី៣ លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ**.............១៣

មាត្រា ៥ លក្ខខណ្ឌដើម្បីការពារ..........................................................................១៣

មាត្រា ៦ ភាពថ្មី..........................................................................................១៤

មាត្រា ៧ ភាពខុសប្លែក..........................................................................................១៥

មាត្រា ៨ ឯកសណ្ឋានភាព..........................................................................................១៥

មាត្រា ៩ ស្ថេរភាព..........................................................................................១៥

**ផ្នែកទី៤ ការដាក់ពាក្យស្នើសុំដើម្បីផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ**.....១៦

មាត្រា១០ការដាក់ពាក្យស្នើសុំ..........................................................................១៦

មាត្រា១១ សិទ្ធិអាទិភាព..........................................................................................១៦

មាត្រា១២ ការត្រួតពិនិត្យពាក្យស្នើសុំ..........................................................................១៧

មាត្រា១៣ កិច្ចការពារបណ្តោះអាសន្ន..........................................................................១៧

**ផ្នែកទី ៥ សិទ្ធិអ្នកបង្កាត់ពូជដំណាំ**..........................................................................១៨

មាត្រា១៤ វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ..........................................................១៨

មាត្រា១៥ ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ..........................................២០

មាត្រា១៦ ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២១
មាត្រា១៧ ការកម្រិតការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២១
មាត្រា១៨ វិធានគ្រប់គ្រងពាណិជ្ជកម្ម ........ ២៣
មាត្រា១៩ រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២៣

**ផ្នែកទី ៦ ការដាក់ឈ្មោះពូជដំណាំ ........ ២៤**
មាត្រា២០ ការដាក់ឈ្មោះពូជដំណាំ ........ ២៤

**ផ្នែកទី ៧ មោឃភាពនិងការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២៦**
មាត្រា២១ មោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២៦
មាត្រា២២ ការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២៦

**ផ្នែកទី ៨ ការអនុវត្តន៍ច្បាប់និងអវសានបញ្ញត្តិ ........ ២៧**
មាត្រា*២៣ ការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ២៧
មាត្រា*២៤ ការគ្រប់គ្រង ........ ២៧
មាត្រា*២៥ ការបោះពុម្ពផ្សាយ ........ ២៧
មាត្រា*២៦ [បទបញ្ញា] និង/ឬ [ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី] ........ ២៨
មាត្រា*២៧ ការចូលជាធរមាន ........ ២៨

**ជំពូកទី២ កំណត់ពន្យល់នានាផ្អែកលើឯកសារព័ត៌មានពាក់ព័ន្ធនឹងមាត្រាមួយចំនួននៃច្បាប់ឆ្នាំ១៩៩១ របស់អនុសញ្ញាយូប៉ូវ.................................................២៩**
កំណត់ពន្យល់ចំពោះមាត្រា១ និយមន័យ....................................................៣០
កំណត់ពន្យល់ចំពោះមាត្រា៣ អំបូរនិងប្រភេទពូជដែលត្រូវការពារ.................៣៥
កំណត់ពន្យល់ចំពោះមាត្រា៤ ប្រព្រឹត្តិកម្មជាតិ............................................៣៧
កំណត់ពន្យល់ចំពោះមាត្រា៥ លក្ខខណ្ឌដើម្បីការពារ...................................៣៩
កំណត់ពន្យល់ចំពោះមាត្រា៦ ភាពថ្មី...........................................................៤៣
កំណត់ពន្យល់ចំពោះមាត្រា៧ ភាពខុសប្លែក.................................................៤៩
កំណត់ពន្យល់ចំពោះមាត្រា៨ ឯកសណ្ឋានភាព.............................................៥១
កំណត់ពន្យល់ចំពោះមាត្រា៩ ស្ថេរភាព.......................................................៥៣
កំណត់ពន្យល់ចំពោះមាត្រា១០ ការដាក់ពាក្យស្នើសុំ.......................................៥៥
កំណត់ពន្យល់ចំពោះមាត្រា១១ សិទ្ធិអាទិភាព.................................................៥៧
កំណត់ពន្យល់ចំពោះមាត្រា១២ ការត្រួតពិនិត្យពាក្យស្នើសុំ..............................៦៥
កំណត់ពន្យល់ចំពោះមាត្រា១៣ កិច្ចការពារបណ្ដោះអាសន្ន.............................៧១
កំណត់ពន្យល់ចំពោះមាត្រា១៤ វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ...........៧៥
កំណត់ពន្យល់ចំពោះមាត្រា១៥ ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ..៩១
កំណត់ពន្យល់ចំពោះមាត្រា១៦ ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ.................១០១
កំណត់ពន្យល់ចំពោះមាត្រា១៧ ការកម្រិតការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ......១០៣
កំណត់ពន្យល់ចំពោះមាត្រា១៨ វិធានគ្រប់គ្រងពាណិជ្ជកម្ម....................................១០៥
កំណត់ពន្យល់ចំពោះមាត្រា១៩ រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ............១០៧
កំណត់ពន្យល់ចំពោះមាត្រា២០ ការដាក់ឈ្មោះពូជដំណាំ.......................................១០៩
កំណត់ពន្យល់ចំពោះមាត្រា២១ មោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ............. ........១៣៩
កំណត់ពន្យល់ចំពោះមាត្រា២២ ការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ.................១៤១
កំណត់ពន្យល់ចំពោះមាត្រា៣០ ការអនុវត្តន៍អនុសញ្ញា..........................................១៤៣

# សេចក្ដីផ្ដើម

១. ឯកសារ "មគ្គុទ្ទេសក៍សម្រាប់ការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១នៃសន្ធិសញ្ញាយូប៉ូវ" (ឯកសារមគ្គុទ្ទេសក៍) មានបំណងផ្តល់ជំនួយដល់រដ្ឋ /អង្គការអន្តររដ្ឋាភិបាលនានាដែលមានបំណងធ្វើសេចក្តីព្រាងច្បាប់ ដោយអនុលោមតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ។ ឯកសារមគ្គុទេសន៍នេះមានប្រយោជន៍ចំពោះអនាគតសមាជិកនៃយូប៉ូវ និងសមាជិកយូប៉ូវដែលចងភ្ជាប់ដោយច្បាប់មុននៃអនុសញ្ញាយូប៉ូវ ដែលមានបំណងធ្វើសេចក្តីព្រាងច្បាប់ដោយអនុលោមតាមច្បាប់ឆ្នាំ១៩៩១។ ឯកសារមគ្គុទ្ទេសក៍នេះ មានពីរជំពូក:

ជំពូកទី១ : អត្ថបទគំរូនៃមាត្រានានាសម្រាប់ពិចារណាក្នុងការរៀបចំច្បាប់ផ្អែកលើច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវនិង

ជំពូកទី២ :កំណត់នានាដោយផ្អែកលើឯកសារព័ត៌មានដែលពាក់ព័ន្ធនឹងមាត្រាមួយចំនួននៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ។

ជំពូកទី១ :អត្ថបទគំរូនៃមាត្រានានាសម្រាប់ពិចារណាក្នុងការរៀបចំច្បាប់ ផ្អែកលើច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ

២. ជំពូកទី១នៃឯកសារមគ្គុទ្ទេសក៍នេះ បើអាច យកតាមរចនាសម្ព័ន្ធមាតិកា និងបង់លេខដូចមាត្រានានានៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ។ ការបង្ហាញជំពូកទី១នៃឯកសារមគ្គុទ្ទេសក៍ត្រូវពន្យល់តាមកថាខណ្ឌនានាដូចខាងក្រោម:

៣. អត្ថបទដែលមានគូសពណ៌ក្នុងវង់ដង្កៀប ធ្វើឡើងសម្រាប់អ្នកព្រាងច្បាប់ដែលពាក់ព័ន្ធនឹងការរៀបចំច្បាប់ហើយត្រូវបង្ហាញចំនុចដូចខាងក្រោម:

(i) អត្ថបទដែលត្រូវបំពេញ (ដូចជា[ឈ្មោះរដ្ឋ/ឈ្មោះអង្គការអន្តររដ្ឋាភិបាល] ឬ [ឈ្មោះអាជ្ញាធរ]

(ii) បទប្បញ្ញត្តិជាជម្រើសនៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ (ដូចជា [ (២) ] [ ពូជដំណាំដែលបង្កើតថ្មី] ឬ [ (២) [ការលើកលែងជាជម្រើស])

(iii) បទប្បញ្ញត្តិច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ដែលចែងពីកម្រិតអប្បបរមានិង/ឬជម្រើសមួយ( ដូចជា មើលមាត្រា១៣ស្តីពីកិច្ចការពារបណ្តោះអាសន្ន និងមាត្រា១៩ ស្តីពីរយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ)

(iv) ការយោងឆ្លងក្នុងបទប្បញ្ញត្តិគំរូនៃជំពូកទី១របស់ឯកសារទៅលើការពន្យល់ ដែលទាក់ទងក្នុងជំពូកទី២ នៃឯកសារ (ដូចជា អំបូរ និងប្រភេទពូជ ដែលត្រូវការពារ

[កំណត់ពន្យល់-មាត្រា៣])

(v) ការបង់លេខនៃបទប្បញ្ញត្តិទាំងឡាយដែលអាចត្រូវផ្លាស់ប្តូរ (ដូចជាក្នុងអត្ថបទគំរូទាក់ទងនឹងមាត្រា១៥(១)(iii)នៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ "សកម្មភាពដែលធ្វើសម្រាប់គោលបំណងបង្កាត់ពូជដំណាំផ្សេងៗនិងលើកលែងតែនៅពេលដែលអនុវត្តបទប្បញ្ញត្តិមាត្រា[១៤(៥)] សកម្មភាពដូចមានចែងក្នុងមាត្រា[១៤(១)ដល់(៤) ] ដែលអនុវត្តចំពោះពូជដំណាំផ្សេងៗនេះ"។)

៤. ចំណងជើងបទប្បញ្ញត្តិជាក់លាក់នានានៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវដែលពាក់ព័ន្ធនឹងអង្គការអន្តររដ្ឋាភិបាលត្រូវបានរក្សាទុកក្នុងជំពូកទី១នៃឯកសារមគ្គុទ្ទេសក៍។ មាតិកានៃបទប្បញ្ញត្តិទាំងនេះ និងបើចាំបាច់ ការពន្យល់ដែលទាក់ទង អាចរកឃើញក្នុងជំពូកទី២ នៃឯកសារមគ្គុទ្ទេសក៍។

៥. លេខដែលទាក់ទងនឹងអត្ថបទគំរូសម្រាប់មាត្រា ២៣ ដល់ មាត្រា ២៧ ក្នុងជំពូកទី១ នៃឯកសារមគ្គុទ្ទេសក៍ ដែលមិនទាក់ទងនឹងលេខនៃមាត្រានានានៃច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ ត្រូវមានសញ្ញាផ្កាយនៅពីមុខ។ កំណត់ជើងទំព័រ(Footnote)ដែលទាក់ទងត្រូវបានបន្ថែមសម្រាប់គោលបំណងនេះក្នុងមាត្រាពាក់ព័ន្ធនៃជំពូកទី១នៃឯកសារមគ្គុទ្ទេសក៍។

៦. បទប្បញ្ញត្តិគំរូក្នុងឯកសារនេះ ដែលទាក់ទងនឹងបទប្បញ្ញត្តិមួយចំនួននៃច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ ដូចជាប្រព្រឹត្តិកម្មជាតិ ឬសិទ្ធិអាទិភាព នឹងត្រូវបំពេញតាមលក្ខខណ្ឌនៃអនុសញ្ញាយូប៉ូវ ។ រដ្ឋឬអង្គការអន្តររដ្ឋាភិបាលនីមួយៗ អាចពង្រីកបទប្បញ្ញត្តិទាំងនេះ ដើម្បីឱ្យស្របតាមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតជាដើម។ មគ្គុទ្ទេសក៍ស្តីពីការបង្កើតបទប្បញ្ញត្តិទាំងនេះ អាចរកបានតាមការស្នើសុំទៅការិយាល័យនៃសហភាព។

៧. ឯកសារ UPOV/INF/13 ផ្តល់នូវ"មគ្គុទ្ទេសក៍ ស្តីពី របៀបដើម្បីក្លាយជាសមាជិកយូប៉ូវ" ហើយឯកសារUPOV/INF/14 ផ្តល់នូវ"មគ្គុទ្ទេសក៍សម្រាប់សមាជិកយូប៉ូវស្តីពីរបៀបផ្តល់សច្ចាប័ន ឬ ចូលជាសមាជិកនៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ"។ មគ្គុទ្ទេសក៍បន្ថែមទៀតស្តីពីបញ្ហាទាំងនេះ អាចរកបានតាមការស្នើសុំទៅការិយាល័យនៃសហភាព។

## ជំពូកទី២ : កំណត់ពន្យល់នានាផ្អែកលើឯកសារព័ត៌មានដែលពាក់ព័ន្ធនឹងមាត្រាមួយចំនួននៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ

៨. ជំពូកទី២ នៃឯកសារមគ្គុទ្ទេសក៍មាន កំណត់ពន្យល់នានា ដែលផ្អែកលើឯកសារ

ព័ត៌មាន ដែលពាក់ព័ន្ធនឹងមាត្រាមួយចំនួននៃច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ (ដូចជាឯកសារក្រុមប្រឹក្សា កំណត់ពន្យល់ សម្ភារៈសិក្សាពីចំងាយ) ហើយជាពិសេសកំណត់ពន្យល់ដូចខាងក្រោម:

- UPOV/EXN/VAR: (មាត្រា១(vi)) — កំណត់ពន្យល់ស្តីពី និយមន័យពូជដំណាំតាមច្បាប់ ឆ្នាំ ១៩៩១ នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/GEN: (មាត្រា៣) — កំណត់ពន្យល់ស្តីពីអំបូរនិងប្រភេទពូជដែលត្រូវការពារតាមច្បាប់ឆ្នាំ ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/NAT: (មាត្រា៤) — កំណត់ពន្យល់ស្តីពីប្រព្រឹត្តិកម្មជាតិតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/NOV: (មាត្រា៦) — កំណតពន្យល់ស្តីពីភាពថ្មីតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/PRI: (មាត្រា១១) — កំណត់ពន្យល់ស្តីពីសិទ្ធិអាទិភាពតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/PRP: (មាត្រា១៣) — កំណត់ពន្យល់ស្តីពីកិច្ចការពារបណ្តោះអាសន្នតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/CAL: (មាត្រា១៤(១)) — កំណត់ពន្យល់ស្តីពីលក្ខខណ្ឌនិងការកម្រិតសិទ្ធិដែលពាក់ព័ន្ធនឹងការអនុញ្ញាតរបស់អ្នកបង្កាត់ពូជចំពោះបំណែកពូជដែលអាចយកទៅដាំដុះបានតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/EDV: (មាត្រា១៤(៥)) — កំណត់ពន្យល់ស្តីពីពូជដំណាំដែលមានស្រឡាយសំខាន់តាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ
- UPOV/EXN/EXC: (មាត្រា១៥) — កំណត់ពន្យល់ស្តីពីការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ

- UPOV/INF/12: (មាត្រា ២០) កំណត់ពន្យល់ស្តីពីការដាក់ឈ្មោះពូជដំណាំតាមអនុសញ្ញាយូប៉ូវ

- UPOV/EXN/NUL: (មាត្រា២១) កំណត់ពន្យល់ស្តីពីមោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំតាមអនុសញ្ញាយូប៉ូវ

- UPOV/EXN/CAN: (មាត្រា២២) កំណត់ពន្យល់ស្តីពីការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំតាមអនុសញ្ញាយូប៉ូវ

- UPOV/EXN/ENF: (មាត្រា៣០(១)(i)) កំណត់ពន្យល់ស្តីពីការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំតាមអនុសញ្ញាយូប៉ូវ

ជំពូកទី២នៃឯកសារមគ្គុទ្ទេសក៍ នឹងត្រូវធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរណាមួយក្នុងមាតិកានិង/ឬឋាន:នៃប្រភព។

៩. រចនាសម្ព័ន្ធនៃឯកសារមគ្គុទ្ទេសក៍ ចែងពីការយោងឆ្លងពីជំពូកទី១ទៅជំពូកទី២។

# ជំពូកទី១ : អត្ថបទគំរូនៃមាត្រានានាសម្រាប់ពិចារណាក្នុងការរៀបចំច្បាប់ផ្អែកលើ
# ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ

[ចំណងជើងនៃសេចក្តីព្រាងច្បាប់]

## ផ្នែកទី១
## និយមន័យ

### មាត្រា១
### និយមន័យ

[កំណត់ពន្យល់-មាត្រា១]

សម្រាប់គោលបំណងនៃច្បាប់នេះ:

(i) អ្នកបង្កាត់ពូជដំណា"សំដៅដល់:

- បុគ្គល ដែលបង្កាត់ឬរកឃើញ និងអភិវឌ្ឍពូជដំណាំ
- [ បុគ្គលដែលជានិយោជកនៃបុគ្គលដែលបានរៀបរាប់ខាងលើ ឬ បុគ្គលដែលបានជួលឱ្យធ្វើការងារឱ្យគាត់] ឬ
- អ្នកទទួលសិទ្ធិពីបុគ្គលទី១ [ឬទី២]ដូចបានរៀបរាប់ខាងលើ តាមករណីនីមួយៗ

(ii) "សិទ្ធិអ្នកបង្កាត់ពូជដំណាំ " សំដៅដល់សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំ ដូចមានចែងក្នុងច្បាប់នេះ

(iii) "ពូជ" សំដៅដល់ ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយ ដែលគេស្គាល់តិចបំផុត ទោះជាមិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្តីដែលអាច:

- ត្រូវកំណត់ដោយការបង្ហាញចរិតលក្ខណ:ដែលជាលទ្ធផលនៃគំរូហ្សែន ឬ បន្សំគំរូហ្សែន
- ត្រូវខុសប្លែកពីក្រុមរុក្ខជាតិផ្សេងទៀត តាមរយ:ការបង្ហាញយ៉ាងហោចណាស់នូវលក្ខណ:ណាមួយនៃចរិកលក្ខណ:ខាងលើ ហើយ
- ត្រូវចាត់ទុកជា ក្រុមមួយ ចំពោះលទ្ធភាព ដែលអាចដាំដុះបន្ត ដោយមិនផ្លាស់ប្តូរ។

(iv) "[ ឈ្មោះអាជ្ញាធរ]"

(v) "យូប៉ូវ សំដៅដល់សហភាពអន្តរជាតិដើម្បីការពារពូជថ្មីនៃដំណាំ ដែល

បង្កើតឡើងដោយអនុសញ្ញាអន្តរជាតិស្ដីពីកិច្ចការពារពូជថ្មីនៃដំណាំឆ្នាំ១៩៦១ ហើយត្រូវបានថែងបន្ថែមក្នុងច្បាប់ឆ្នាំ១៩៧២ ច្បាប់ឆ្នាំ១៩៧៨ និង ច្បាប់ឆ្នាំ១៩៩១

(vi) "សមាជិក យូប៉ូវ" សំដៅដល់រដ្ឋជាភាគីអនុសញ្ញាយូប៉ូវឆ្នាំ១៩៦១/ ច្បាប់ឆ្នាំ១៩៧២ ឬច្បាប់ឆ្នាំ១៩៧៨ ឬ ភាគីហត្ថលេខីនៃច្បាប់ឆ្នាំ១៩៩១

[(vii) "ដែនដី"] (ចំពោះអង្គការអន្តររដ្ឋាភិបាល)។

# ផ្នែកទី២
# លក្ខណៈទូទៅ
## មាត្រា ២
## គោលបំណង

[ កំណត់ពន្យល់-មាត្រា១(ix) ]

(១)គោលបំណងនៃច្បាប់នេះ គឺដើម្បីផ្តល់និងការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

(២)[ឈ្មោះអាជ្ញាធរ]គឺជាអាជ្ញាធរដែលទទួលបន្ទុកផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## មាត្រា៣
## អំបូរ និង ប្រភេទពូជដែលត្រូវការពារ

[កំណត់ពន្យល់-មាត្រា៣]

**(ជម្រើសទី១)**

[ច្បាប់នេះ ត្រូវអនុវត្តតាមកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ចំពោះអំបូរ និង ប្រភេទពូជដំណាំទាំងអស់។]

**(ជម្រើទី២)**

[ច្បាប់នេះត្រូវអនុវត្តចំពោះអំបូរ និងប្រភេទពូជដំណាំទាំងឡាយដែលកំណត់ដោយ [សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី/បទបញ្ញានានា]ហើយយ៉ាងយូរបំផុត តាមការផុតកំណត់រយៈពេល[៥(ប្រាំ)] /[ ១០(ដប់)] ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ ចំពោះអំបូរ និងប្រភេទពូជដំណាំទាំងអស់។]

## មាត្រា៤
## ប្រព្រឹត្តិកម្មជាតិ

[កំណត់ពន្យល់-មាត្រា៤]

[(១)][ប្រព្រឹត្តិកម្ម] ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដែលមានចែងក្នុងច្បាប់នេះ ពលរដ្ឋនៃសមាជិកយូប៉ូវ ក៏ដូចជារូបវន្តបុគ្គលដែលមានលំនៅ និងនីតិបុគ្គលដែលមានការិយាល័យដែលបានចុះបញ្ជីក្នុងដែនដីនៃសមាជិកយូប៉ូវ ចំពោះការផ្តល់និងកិច្ចការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវទទួលក្នុងដែនដីនៃ[ឈ្មោះរដ្ឋ/អង្គការអន្តររដ្ឋាភិបាល] នូវប្រព្រឹត្តិកម្មដូចគ្នានឹងប្រព្រឹត្តិកម្មដែលបានផ្តល់ឱ្យដោយច្បាប់នេះចំពោះពលរដ្ឋនៃ [ឈ្មោះរដ្ឋ/អង្គការអន្តររដ្ឋាភិបាល]។ ពលរដ្ឋទាំងនេះ ទោះជារូបវន្តបុគ្គលឬនីតិបុគ្គលក្តីដែលជាសមាជិកយូប៉ូវ ត្រូវគោរពតាមលក្ខខណ្ឌនិងបែបបទដែលបានតម្រូវដល់ពលរដ្ឋនៃ[ឈ្មោះរដ្ឋ/អង្គការអន្តររដ្ឋាភិបាល]នេះ។

[(២)] [‟ពលរដ្ឋ″] សម្រាប់គោលបំណងនៃកថាខណ្ឌទី[(១) ]‟ពលរដ្ឋ″ នៅពេលដែលសមាជិកយូប៉ូវ ជារដ្ឋ គឺពលរដ្ឋនៃរដ្ឋនេះ ហើយបើសមាជិកយូប៉ូវ ជាអង្គការអន្តររដ្ឋាភិបាល គឺពលរដ្ឋនៃរដ្ឋដែលជាសមាជិកនៃអង្គការនេះ។

# ផ្នែកទី៣
# លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

## មាត្រា៥

## លក្ខខណ្ឌដើម្បីការពារ

[កំណត់ពន្យល់-មាត្រា៥]

(១) [ លក្ខណៈវិនិច្ឆ័យដែលត្រូវបំពេញ] សិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវផ្តល់ឱ្យនៅពេលដែលពូជដំណាំ :

(i) ថ្មី

(ii) ភាពខុសប្លែក

(iii) ឯកសណ្ឋានភាព និង

(iv) ស្ថេរភាព។

(២) [ លក្ខខណ្ឌផ្សេងទៀត] ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនត្រូវបំពេញលក្ខខណ្ឌបន្ថែម ឬផ្សេងទៀតឡើយ ឱ្យតែពូជដំណាំនេះត្រូវបានកំណត់ដោយការដាក់ឈ្មោះស្របតាមបទប្បញ្ញត្តិនៃមាត្រា [២០] ហើយឱ្យតែអ្នកដាក់ពាក្យស្នើសុំ បានបំពេញតាមទម្រង់ដូចមានចែងក្នុងច្បាប់នេះនិងបានបង់កម្រៃដែលបានកំណត់។

## មាត្រា៦
## ភាពថ្មី

[កំណត់ពន្យល់-មាត្រា៦]

[(១)] [លក្ខណៈវិនិច្ឆ័យ] ពូជដំណាំដែលចាត់ទុកថាថ្មីត្រឹមកាលបរិច្ឆេទការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ លុះត្រាតែបំណែកពូជដែលអាចយកទៅដាំដុះបាន ឬបំណែកពូជដែលប្រមូលផលបានពីការដាំដុះ ពុំទាន់ដាក់លក់ ឬដាក់បង្ហាញទៅបុគ្គលដទៃទៀតដោយអ្នកបង្កាត់ពូជដំណាំ ឬដោយមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ:

(i) ក្នុងដែនដីនៃ[ឈ្មោះរដ្ឋ/អង្គការអន្តររដ្ឋាភិបាល] ក្នុងរយៈពេលមិនលើសពីមួយឆ្នាំមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំនេះ និង

(ii) ក្រៅដែនដីនៃ[ឈ្មោះរដ្ឋ/អង្គការអន្តររដ្ឋាភិបាល] បានដាក់មុនរយៈពេល ៤(បួន)ឆ្នាំ ឬក្នុងករណីដំណាំឈើ ឬដំណាំវល្លិបានដាក់មុនរយៈពេល៦ (ប្រាំមួយ)ឆ្នាំ មុនកាលបរិច្ឆេទនេះ។

[(២)] [ពូជដំណាំដែលបង្កើតថ្មី] ( បទប្បញ្ញត្តិជាជម្រើស-មើលកំណត់ពន្យល់-មាត្រា៦(២))

[(៣)]["ដែនដី"ក្នុងករណីមួយចំនួន] (សម្រាប់សមាជិកទាំងឡាយនៃយូប៉ូវ ដែលជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលមួយដូចគ្នា)

## មាត្រា៧

## ភាពខុសប្លែក

[កំណត់ពន្យល់-មាត្រា៧]

ពូជដំណាំត្រូវចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។ ដោយឡែក ការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំឬការបញ្ចូលពូជដំណាំផ្សេងក្នុងបញ្ជីពូជដំណាំជាផ្លូវការក្នុងប្រទេសណាមួយ ត្រូវចាត់ទុកថាបានធ្វើឱ្យពូជដំណាំផ្សេងនេះស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ លុះត្រាតែការដាក់ពាក្យនេះឈានដល់ការផ្ដល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬឈានដល់ការបញ្ចូលពូជដំណាំនេះក្នុងបញ្ជីពូជដំណាំជាផ្លូវការ តាមករណីនីមួយៗ។

## មាត្រា៨

## ឯកសណ្ឋានភាព

[កំណត់ពន្យល់-មាត្រា៨]

ពូជដំណាំដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជអាចរក្សាឯកសណ្ឋានគ្រប់គ្រាន់ លើកលែងតែមានការប្រែប្រួលលក្ខណៈពិសេសនៃការដាំដុះ។

## មាត្រា៩

## ស្ថេរភាព

[កំណត់ពន្យល់-មាត្រា៩]

ពូជដំណាំដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈពាក់ព័ន្ធរបស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ ឬក្នុងករណីវដ្តដោយឡែកនៃការលូតលាស់ គឺគ្មានការប្រែប្រួលពេលបញ្ចប់វដ្តនីមួយៗ។

## ផ្នែកទី៤
## ការដាក់ពាក្យស្នើសុំសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

### មាត្រា១០
### ការដាក់ពាក្យស្នើសុំ

[កំណត់ពន្យល់ -មាត្រា ១០]

(១) កាលបរិច្ឆេទការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវជាកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំដែលបានដាក់ត្រឹមត្រូវដូចដែលបានកំណត់ដោយ [ច្បាប់នេះ/បទបញ្ជា/សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី]។

(២) [ឯករាជ្យភាពនៃកិច្ចការពារ] [ឈ្មោះអាជ្ញាធរ] មិនត្រូវបដិសេធន៍ផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬកម្រិតរយៈពេលការពារ ដោយមូលហេតុថាកិច្ចការពារពូជដំណាំតែមួយមិនបានដាក់ពាក្យសុំ ត្រូវបានបដិសេធន៍ឬបានហួសរយៈពេល ក្នុងរដ្ឋឬអង្គការអន្តររដ្ឋាភិបាលណាមួយផ្សេងទៀត។

### មាត្រា១១
### សិទ្ធិអាទិភាព

[កំណត់ពន្យល់-មាត្រា១១]

(១) [សិទ្ធិ រយៈពេល] អ្នកបង្កាត់ពូជដំណាំ ដែលបានដាក់ពាក្យស្នើសុំការពារពូជដំណាំត្រឹមត្រូវ ក្នុងសមាជិកមួយនៃយូប៉ូវ ("ពាក្យស្នើសុំដំបូង") ក្នុងគោលបំណង ដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំចំពោះពូជដំណាំតែមួយ នៅ[ឈ្មោះអាជ្ញាធរ] ត្រូវទទួលសិទ្ធិអាទិភាពក្នុងរយៈពេល១២(ដប់ពីរ)ខែ។ រយៈពេលនេះត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង។ ថ្ងៃនៃការដាក់ពាក្យមិនរាប់បញ្ចូលជាកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូងឡើយ។

(២) [ការអះអាងសិទ្ធិ] ដើម្បីទទួលអត្ថប្រយោជន៍ពីសិទ្ធិអាទិភាព អ្នកបង្កាត់ពូជដំណាំត្រូវអះអាងសិទ្ធិអាទិភាពនៃពាក្យស្នើសុំដំបូង ក្នុងពាក្យស្នើសុំដែលបានដាក់នៅ[ឈ្មោះអាជ្ញាធរ] ។ ក្នុង[រយៈពេលមិនតិចជាង៣(បី)ខែ]បន្ទាប់ពីកាលបិច្ឆេទដាក់ពាក្យស្នើសុំ [ឈ្មោះអាជ្ញាធរ] ត្រូវតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ឯកសារចម្លងនៃពាក្យស្នើសុំដំបូងដោយបញ្ជាក់ថាជាឯកសារត្រឹមត្រូវដោយអាជ្ញាធរដែលទទួលពាក្យស្នើសុំនេះ។ គំរូឬភស្តុតាង ដែលពូជដំណាំជាកម្មវត្ថុនៃពាក្យស្នើសុំទាំងពីរត្រូវតែដូចគ្នា។

(៣) [ឯកសារ និងបំណែកពូជ] អ្នកបង្កាត់ពូជដំណាំត្រូវបានផ្តល់រយៈពេល២(ពីរ)ឆ្នាំបន្ទាប់ពីផុតរយៈពេលអាទិភាព ឬនៅពេលដែលពាក្យស្នើសុំដំបូងត្រូវបានបដិសេធន៍ឬដក

ចេញ ត្រូវបានផ្តល់ឱ្យរយៈពេលសមរម្យមួយ បន្ទាប់ពីការបដិសេធន៍ឬការដកពាក្យស្នើសុំ ដើម្បីផ្តល់ដល់[ឈ្មោះអាជ្ញាធរ] នូវព័ត៌មានចាំបាច់ ឯកសារ ឬ បំណែកពូជផ្សេងៗ ដែលទាមទារក្នុងការត្រួតពិនិត្យ តាមមាត្រា[១២]។

(៤) [ព្រឹត្តិការណ៍ដែលកើតឡើងក្នុងរយៈពេលអាទិភាព] ព្រឹត្តិការណ៍នានាដែលកើតឡើងក្នុងរយៈពេលដែលមានចែងក្នុងកថាខណ្ឌទី(១) ដូចជាការដាក់ពាក្យស្នើសុំផ្សេងទៀត ឬ ការបោះពុម្ពផ្សាយ ឬការប្រើប្រាស់ពូជដំណាំដែលជាកម្មវត្ថុនៃការដាក់ពាក្យស្នើសុំដំបូង មិនត្រូវចាត់ទុកជាមូលដ្ឋានក្នុងការបដិសេធន៍ការដាក់ពាក្យស្នើសុំបន្ទាប់ឡើយ។ ព្រឹត្តិការណ៍ទាំងនេះ មិនត្រូវបង្កើតជាសិទ្ធិដល់តតិយជនឡើយ។

## មាត្រា១២
## ការត្រួតពិនិត្យពាក្យស្នើសុំ
[កំណត់ពន្យល់-មាត្រា១២]

សេចក្តីសម្រេចណាដែលផ្តល់សិទ្ធិឱ្យអ្នកបង្កាត់ពូជដំណាំ ត្រូវទាមទារឱ្យត្រួតពិនិត្យអនុលោមភាពជាមួយលក្ខខណ្ឌនៃមាត្រា[៥ដល់៩]។ពេលកំពុងត្រួតពិនិត្យ[ឈ្មោះអាជ្ញាធរ] អាចបណ្តុះពូជដំណាំ ឬធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀត ឱ្យគេបណ្តុះពូជដំណាំ ឬ ឱ្យគេធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀត ឬពិចារណាលើលទ្ធផលនៃការពិសោធន៍បណ្តុះ ឬការសាកល្បងផ្សេងទៀត ដែលបានធ្វើរួចហើយ។ ក្នុងគោលបំណងត្រួតពិនិត្យ [ឈ្មោះអាជ្ញាធរ] អាចទាមទារឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ព័ត៌មាន ឯកសារ ឬបំណែកពូជចាំបាច់នានាដូចដែលកំណត់ក្នុង[ច្បាប់នេះ/បទបញ្ជា/សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី]។

## មាត្រា១៣
## កិច្ចការពារបណ្តោះអាសន្ន
[កំណត់ពន្យល់-មាត្រា១៣]

(១) កិច្ចការពារបណ្តោះអាសន្នត្រូវបានផ្តល់ឱ្យដើម្បីការពារផលប្រយោជន៍អ្នកបង្កាត់ពូជដំណាំក្នុងចន្លោះពេល[ដាក់ឬបោះពុម្ពផ្សាយ]ពាក្យស្នើសុំផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការផ្តល់សិទ្ធិនេះ។

(២)[វិធានការនានាដែលត្រូវកំណត់]

# ផ្នែកទី៥
# សិទ្ធិអ្នកបង្កាត់ពូជដំណាំ
## មាត្រា១៤
## វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា១៤]

(១) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាន] (ក)លើកលែងតែមាត្រា[១៥]និងមាត្រា[១៦] សកម្មភាពខាងក្រោមទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ ត្រូវមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ:

(i) ការផលិតឬការផលិតឡើងវិញ(ចំនួនច្រើន)

(ii) ការដាក់លក្ខខណ្ឌក្នុងគោលបំណងនៃការដាំដុះ

(iii) ការដាក់លក់

(iv) ការលក់ឬចរាចរផ្សេងទៀត

(v) ការនាំចេញ

(vi) ការនាំចូល

(vii) ការស្តុកទុកសម្រាប់គោលបំណងណាមួយដូចមានចែងក្នុងចំនុច(i) ដល់ (vi) ខាងលើ។

(ខ) អ្នកបង្កាត់ពូជដំណាំអាចផ្តល់ការអនុញ្ញាត ដោយភ្ជាប់នូវលក្ខខណ្ឌនិងការកម្រិតសិទ្ធិ។

(២) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន ] លើកលែងតែមាត្រា[១៥]និងមាត្រា[១៦]សកម្មភាពដូចមានចែងក្នុងចំនុច(i)ដល់(vii) នៃកថាខណ្ឌទី(១)(ក)ទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូលនិងផ្នែកនៃដំណាំ ដែលទទួលបានតាមរយៈការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនៃបំណែកពូជ ដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបានខាងលើ។

[(៣)] [សកម្មភាពទាក់ទងនឹងផលិតផលមួយចំនួន] [បទប្បញ្ញត្តិជាជម្រើស] លើកលែងតែមាត្រា[១៥] និងមាត្រា[១៦] សកម្មភាពដូចមានចែងក្នុងចំនុច(i)ដល់(vii) នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងផលិតផលដែលបង្កើតឡើង ដោយផ្ទាល់ពីបំណែកពូជ ដែល

ប្រមូលផលបាននៃពូជដំណាំដែលបានការពារក្នុងបទប្បញ្ញត្តិនៃកថាខណ្ឌ[ទី(២)] តាមរយៈការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនៃបំណែកពូជដែលប្រមូលផលបាននេះ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាននេះ]។

[(៤)] [សកម្មភាពបន្ថែមដែលអាចមាន] (បទប្បញ្ញត្តិជាជម្រើស-មើលកំណត់ពន្យល់-មាត្រា១៤(៤))។

[(៥)] [ ពូជដំណាំដែលមានស្រឡាយសំខាន់ និងពូជដំណាំផ្សេងទៀតមួយចំនួន]

(ក)បទប្បញ្ញត្តិនៃកថាខណ្ឌ[ទី(១)ដល់ទី(៤)] ត្រូវអនុវត្តផងដែរទាក់ទងនឹងៈ

(i) ពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំដែលបានការពារ នៅពេលដែលពូជដំណាំដែលបានការពារ មិនមែនជាពូជដំណាំដែលមានស្រឡាយសំខាន់នោះទេ

(ii) ពូជដំណាំដែលមិនអាចញែកដាច់ពីគ្នាស្រឡះ អនុលោមតាមមាត្រា៧ ពីពូជដំណាំដែលបានការពារ និង

(iii) ការផលិតពូជដំណាំ តម្រូវឱ្យមានការប្រើប្រាស់ម្តងហើយម្តងទៀតនូវពូជដំណាំដែលបានការពារ។

(ខ) សម្រាប់គោលបំណងនៃអនុកថាខណ្ឌ(ក)(i) ពូជដំណាំត្រូវចាត់ទុក ថាមានស្រឡាយសំខាន់ពីពូជដំណាំមួយផ្សេងទៀត ("ពូជដំណាំដើម") នៅពេលដែលៈ

(i) ពូជដំណាំដែលមានស្រឡាយលើសលុបពីពូជដំណាំដើម ឬពីពូជដំណាំមួយដែលវាជាស្រឡាយលើសលុបពីពូជដំណាំដើម តែនៅរក្សាការបង្ហាញចរិតលក្ខណៈសំខាន់ជាលទ្ធផលនៃគំរូហ្សែន ឬបន្សំគំរូហ្សែននៃពូជដំណាំដើម

(ii) ពូជដំណាំអាចញែកដាច់ពីគ្នាស្រឡះពីពូជដំណាំដើម និង

(iii) លើកលែងតែភាពខុសគ្នាដែលកើតពីអំពើនៃការបំប្លែងពូជដំណាំដូចនឹងពូជដំណាំដើម ក្នុងការបង្ហាញចរិតលក្ខណៈសំខាន់ ជាលទ្ធផលនៃគំរូហ្សែន ឬបន្សំគំរូហ្សែននៃពូជដំណាំដើម។

(គ) ពូជបំលែងសំខាន់ៗដែលអាចទទួលបាន ដូចជា តាមការជ្រើសរើសដោយធម្មជាតិឬដោយការបំបែកកោសិកា ឬដោយបំរែបំរួលហ្សែន ការជ្រើសរើសពូជបំរែបំរួលមួយៗចេញពីពូជដំណាំដែលគេបង្កើតឡើង ត្រូវធ្វើតាមរយៈការបង្កាត់ត្រឡប់ឬការបំប្លែងតាមរយៈវិស្វកម្មហ្សែន។

## មាត្រា១៥

## ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា១៥]

[(១)] [ការលើកលែងដោយបង្ខំ] សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់:

(i) សកម្មភាពដែលធ្វើឡើងដោយឯកជននិងគ្មានបំណងពាណិជ្ជកម្ម

(ii) សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងពិសោធន៍ និង

(iii) សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងបង្កាត់ពូជដំណាំផ្សេងទៀតនិងសកម្មភាពដូចមានចែងក្នុងមាត្រា[១៤(១)ដល់(៤)] ទាក់ទងនឹងពូជដំណាំផ្សេងទៀតនោះ លើកលែងតែអនុវត្តបទប្បញ្ញត្តិនៃមាត្រា[១៤(៥)] ។

[(២)] [ការលើកលែងជាជម្រើស] (សូមមើលកំណត់ពន្យល់-មាត្រា១៥(២)

## មាត្រា១៦

## ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា១៦]

(១) [ការរលត់សិទ្ធិ] សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់សកម្មភាពពាក់ព័ន្ធនឹងបំណែកពូជណាមួយនៃពូជដំណាំដែលបានការពារ ឬ នៃពូជដំណាំដែលគ្រប់គ្រងដោយបទប្បញ្ញត្តិនៃមាត្រា[១៤(៥)] ដែលបានលក់ឬចរាចរលើទីផ្សារដោយអ្នកបង្កាត់ពូជដំណាំ ឬដោយមានការយល់ព្រមពីខ្លួនក្នុងដែនដីនៃ[ឈ្មោះរដ្ឋ/អង្គការអន្តររដ្ឋាភិបាល] ឬបំណែកពូជណាមួយដែលមានស្រឡាយពីបំណែកពូជនេះ លើកលែងតែសកម្មភាពទាំងនេះ :

(i) ទាក់ទងនឹងការដាំដុះបន្តនៃពូជដំណានេះ ឬ

(ii) ទាក់ទងនឹងការនាំចេញបំណែកនៃពូជដំណាំ ដែលអាចបណ្តុះពូជដំណាំបានទៅប្រទេសមួយ ដែលមិនការពារពូជដំណាំនៃអំបូរឬប្រភេទពូជរុក្ខជាតិដែលជាពូជដំណាំនោះលើកលែងតែបំណែកពូជនាំចេញមានគោលបំណងសម្រាប់ប្រើប្រាស់ចុងក្រោយ។

(២) [ អត្ថន័យនៃ"បំណែកពូជ"] សម្រាប់គោលបំណងនៃកថាខណ្ឌទី[(១)] ទាក់ទងនឹងពូជដំណាំ "បំណែកពូជ" មានន័យថា:

(i) បំណែកពូជនៃប្រភេទណាមួយដែលអាចយកទៅដាំដុះបាន

(ii) បំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូល និងផ្នែកនៃដំណាំ និង

(iii) ផលិតផលណាមួយ ដែលបង្កើតឡើងដោយផ្ទាល់ពីបំណែកពូជដែលប្រមូលផលបាន។

[(៣)] ["ដែនដី" ក្នុងករណីមួយចំនួន] [ចំពោះសមាជិកយូប៉ូវដែលជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលតែមួយដូចគ្នា]។

## មាត្រា១៧

## ការកម្រិតការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា១៧]

(១) [ផលប្រយោជន៍សាធារណៈ] លើកលែងតែមានចែងច្បាស់ក្នុងច្បាប់នេះ សេរីភាពអនុវត្តសិទ្ធិអ្នកបង្កាត់ពូជដំណាំ មិនត្រូវកម្រិតដោយមូលហេតុផ្សេងក្រៅពីផលប្រយោជន៍សាធារណៈឡើយ។

(២) [ លាភការសមរម្យ ] នៅពេលដែលការកម្រិតណាមួយបែបនេះមានអានុភាពដោយ[រដ្ឋមន្ត្រី/អាជ្ញាធរមានសមត្ថកិច្ច]អនុញ្ញាតឱ្យតតិយជន ដើម្បីធ្វើសកម្មភាពណាមួយដែលតម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ អ្នកបង្កាត់ពូជដំណាំត្រូវទទួលបានលាភការសមរម្យ។

## មាត្រា១៨
## វិធានការគ្រប់គ្រងពាណិជ្ជកម្ម
[កំណត់ពន្យល់-មាត្រា១៨]

សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវឯករាជ្យពីវិធានណាមួយក្នុងការគ្រប់គ្រងលើការផលិត ការបញ្ជាក់និងចរាចរបំណែកពូជដំណាំ ឬការនាំចូលឬការនាំចេញបំណែកពូជនេះ។ ប៉ុន្តែ វិធានការទាំងនេះមិនត្រូវប៉ះពាល់ដល់ការអនុវត្តន៍បទប្បញ្ញត្តិនៃច្បាប់នេះឡើយ។

## មាត្រា១៩
## រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ
[កំណត់ពន្យល់-មាត្រា១៩]

សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវផ្តល់ឱ្យក្នុងរយៈពេលមួយ នៃ[រយៈពេលដែលត្រូវកំណត់]រាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។ ចំពោះដំណាំឈើនិងដំណាំវល្លិ រយៈពេលនេះត្រូវជា[រយៈពេលដែលត្រូវកំណត់]រាប់ចាប់ពីកាលបរិច្ឆេទនេះ។

# ផ្នែកទី៦
# ការដាក់ឈ្មោះពូជដំណាំ
## មាត្រា២០
## ការដាក់ឈ្មោះពូជដំណាំ

[កំណត់ពន្យល់-មាត្រា២០]

(១) [ការកំណត់ពូជដំណាំដោយការដាក់ឈ្មោះ ការប្រើប្រាស់ការដាក់ឈ្មោះ] ពូជដំណាំ ត្រូវតំណត់ដោយការដាក់ឈ្មោះ ដែលនឹងក្លាយជាការកំណត់ប្រភេទពូជដំណាំ។ លើកលែងតែកថាខណ្ឌទី[(៤)] សិទ្ធិចំពោះការកំណត់ដែលបានចុះបញ្ជី ជាការដាក់ឈ្មោះពូជដំណាំ មិនត្រូវរារាំងការប្រើប្រាស់ដោយសេរីនៃការដាក់ឈ្មោះពូជដំណាំ ទោះបីបន្ទាប់ពីផុតសុពលភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំក៏ដោយ។

(២) [ចរិតលក្ខណៈនៃការដាក់ឈ្មោះ] ការដាក់ឈ្មោះត្រូវតែអាចសម្គាល់ពូជដំណាំបាន។ ការដាក់ឈ្មោះមិនត្រូវមានសញ្ញាតែមួយទេ លើកលែងតែសញ្ញានេះជាការអនុវត្តន៍ពីមុន ក្នុងការកំណត់ពូជដំណាំ។ ការដាក់ឈ្មោះ មិនត្រូវនាំឱ្យយល់ខុសឬបណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជដំណាំឡើយ។ ជាពិសេស ការដាក់ឈ្មោះត្រូវខុសពីរាល់ការដាក់ឈ្មោះលើពូជដំណាំដែលមានរួចហើយ ក្នុងប្រភេទពូជដំណាំតែមួយឬក្នុងប្រភេទដែលទាក់ទងជិតស្និទ្ធក្នុងដែនដីនៃសមាជិកយូប៉ូវណាមួយ។

(៣) [ការចុះបញ្ជីការដាក់ឈ្មោះ] ការដាក់ឈ្មោះពូជដំណាំត្រូវស្នើដោយអ្នកបង្កាត់ពូជដំណាំទៅ[ឈ្មោះអាជ្ញាធរ]។ ប្រសិនបើរកឃើញថា ការដាក់ឈ្មោះ មិនបានបំពេញលក្ខខណ្ឌនៃកថាខណ្ឌទី[(២)] [ឈ្មោះអាជ្ញាធរ] ត្រូវបដិសេធន៍ការចុះបញ្ជីហើយតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំស្នើការដាក់ឈ្មោះមួយផ្សេងទៀត ក្នុងរយៈពេលកំណត់មួយ។ ការដាក់ឈ្មោះ ត្រូវចុះបញ្ជីដោយ[ឈ្មោះអាជ្ញាធរ] ក្នុងពេលតែមួយស្របគ្នានឹងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។

(៤) [សិទ្ធិពីមុននៃតតិយជន] សិទ្ធិពីមុននៃតតិយជនមិនត្រូវប៉ះពាល់ឡើយ។ ដោយមូលហេតុនៃសិទ្ធិពីមុន ប្រសិនបើការប្រើប្រាស់ការដាក់ឈ្មោះពូជដំណាំ ត្រូវហាមឃាត់ចំពោះបុគ្គលដែលតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី[(៧)]តម្រូវឱ្យប្រើប្រាស់ការដាក់ឈ្មោះនេះ [ឈ្មោះអាជ្ញាធរ]ត្រូវតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំស្នើការដាក់ឈ្មោះមួយផ្សេងទៀតសម្រាប់ពូជដំណាំនេះ។

(៥) [ការដាក់ឈ្មោះដូចគ្នាក្នុងសមាជិកទាំងអស់នៃយូប៉ូវ] ពូជដំណាំមួយត្រូវបញ្ជូន

ទៅសមាជិកទាំងអស់នៃយូប៉ូវក្រោមការដាក់ឈ្មោះតែមួយ។ [ឈ្មោះអាជ្ញាធរ] ត្រូវចុះបញ្ជីការដាក់ឈ្មោះដែលបានបញ្ជូនមក លើកលែងតែយល់ថាការដាក់ឈ្មោះនេះមិនសមស្របក្នុងករណីនេះ តម្រូវឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ការដាក់ឈ្មោះមួយផ្សេងទៀត។

(៦) [ព័ត៌មានពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំ] [ឈ្មោះអាជ្ញាធរ] ត្រូវធានាថាអាជ្ញាធរនៃសមាជិកទាំងឡាយនៃយូប៉ូវ ត្រូវបានជូនដំណឹងពីបញ្ហាពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំ ជាពិសេស ការបញ្ជូល ការចុះបញ្ជី និងការលុបចោលការដាក់ឈ្មោះ។ អាជ្ញាធរណាមួយអាចលើកឡើងអំពីការសង្កេតរបស់ខ្លួនបើមាន លើការចុះបញ្ជីការដាក់ឈ្មោះទៅ[ឈ្មោះអាជ្ញាធរ] ។

(៧) [កាតព្វកិច្ចប្រើប្រាស់ការដាក់ឈ្មោះ] បុគ្គលណាមួយដែលដាក់លក់ ឬចរាចរបំណែកនៃពូជដំណាំដែលបានការពារក្នុងដែនដីនៃ[រដ្ឋ/អង្គការអន្តររដ្ឋាភិបាល] ត្រូវប្រើប្រាស់ការដាក់ឈ្មោះពូជដំណាំនេះ ទោះបីបន្ទាប់ពីសិទ្ធិអ្នកបង្កាត់ពូជដំណាំផុតសុពលភាពចំពោះពូជដំណាំនេះក៏ដោយ លើកលែងតែសិទ្ធិពីមុនណាមួយរារាំងដល់ការប្រើប្រាស់បែបនេះ តាមបទប្បញ្ញត្តិនៃកថាខណ្ឌទី[(៤)]។

(៨) [ការបញ្ជាក់ដែលប្រើប្រាស់ទាក់ទងនឹងការដាក់ឈ្មោះ] នៅពេលដែលពូជដំណាំមួយ ត្រូវបានដាក់លក់ ឬចរាចរ ពូជដំណាំត្រូវបានអនុញ្ញាឱ្យភ្ជាប់ទៅនឹងពាណិជ្ជសញ្ញា ពាណិជ្ជនាម ឬការបញ្ជាក់ប្រហាក់ប្រហែលផ្សេងទៀត ជាមួយការដាក់ឈ្មោះពូជដំណាំដែលបានចុះបញ្ជី។ ប្រសិនបើការបញ្ជាក់នេះ ត្រូវបានភ្ជាប់បែបនេះ ការដាក់ឈ្មោះត្រូវធ្វើយ៉ាងណាឱ្យងាយស្គាល់។

# ផ្នែកទី៧
# មោឃភាពនិងការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ

## មាត្រា ២១
## មោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា២១]

(១) [មូលហេតុនៃមោឃភាព] សិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវប្រកាសថា មោឃភាព នៅពេលដែល:

(i) លក្ខខណ្ឌក្នុងមាត្រា[៦ឬ៧]មិនបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

(ii) ក្នុងករណីដែលការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ផ្អែកជាសំខាន់លើព័ត៌មាន និងឯកសារដែលផ្តល់ឱ្យដោយអ្នកបង្កាត់ពូជដំណាំ លក្ខខណ្ឌក្នុងមាត្រា[៨ឬ៩] មិនបានបំពេញ ដូចកាលពីពេលផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬ

(iii) សិទ្ធិអ្នកបង្កាត់ពូជដំណាំ បានផ្តល់ទៅឱ្យបុគ្គលមួយ ដែលគ្មានសិទ្ធិទទួល លើកលែងតែសិទ្ធិនេះត្រូវបានផ្ទេរទៅឱ្យបុគ្គលដែលមានសិទ្ធិទទួល។

(២) [ ការបដិសេធន៍មូលហេតុផ្សេងៗទៀត ] សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនត្រូវបានប្រកាសថាមោឃភាព ដោយមូលហេតុផ្សេងក្រៅពីមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី[(១)]ឡើយ។

## មាត្រា២២
## ការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា២២]

(១) [មូលហេតុនៃការលុបចោល] (ក) សិទ្ធិអ្នកបង្កាត់ពូជដំណាំ[អាច]ត្រូវបានលុបចោល ប្រសិនបើមានភស្តុតាងបង្ហាញថាលក្ខខណ្ឌក្នុង[មាត្រា៨ឬមាត្រា៩]លែងបំពេញបាន។

(ខ) ជាងនេះទៅទៀត សិទ្ធិអ្នកបង្កាត់ពូជដំណាំអាចត្រូវបានលុបចោល ប្រសិនបើបន្ទាប់ពីមានសំណើនិងក្នុងរយៈពេលកំណត់មួយ:

(i) អ្នកបង្កាត់ពូជដំណាំមិនបានផ្តល់ព័ត៌មាន ឯកសារ ឬបំណែកពូជ ដែលចាំបាច់សម្រាប់ផ្ទៀងផ្ទាត់ការរក្សាសិទ្ធិនៃពូជដំណាំដល់[ឈ្មោះអាជ្ញាធរ]

(ii) អ្នកបង្កាត់ពូជដំណាំខកខានមិនបានបង់កម្រៃដើម្បីរក្សាសិទ្ធិខ្លួនឱ្យនៅជាធរមាន ឬ

(iii) អ្នកបង្កាត់ពូជដំណាំមិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីឈ្មោះពូជដំណាំដែលទទួលបានសិទ្ធិនេះត្រូវបានលុបចោល។

(២) [ ការបដិសេធន៍មូលហេតុផ្សេងទៀត ] សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនត្រូវបានលុបចោលដោយមូលហេតុផ្សេងក្រៅពីមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី[(១)]ឡើយ។

## ផ្នែកទី ៨
## ការអនុវត្តន៍អនុសញ្ញានិងអន្តរបញ្ញត្តិ

### មាត្រា*២៣
### ការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ

[កំណត់ពន្យល់-មាត្រា៣០(១)(i)]

វិធានការដោះស្រាយតាមច្បាប់នានាដូចខាងក្រោម ត្រូវតែមានចំពោះការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ:[...]

### មាត្រា*២៤
### ការត្រួតពិនិត្យ

[កំណត់ពន្យល់-មាត្រា៣០(១)(i)]

ការត្រួតពិនិត្យលើការអនុវត្តន៍ច្បាប់នេះ[និងបទបញ្ញា/សេចក្តីសម្រេចដែលអនុម័តតាមច្បាប់នេះ] ត្រូវអនុវត្តដោយ[រដ្ឋមន្ត្រី/អ្នកធ្វើអធិការ/អាជ្ញាធរមានសមត្ថកិច្ច]។

វិធានការរដ្ឋបាលនិងទណ្ឌកម្មខាងក្រោម ត្រូវអនុវត្តក្នុងករណីមានការបំពានច្បាប់នេះ [និងបទបញ្ញា/សេចក្តីសម្រេច]: [...]

### មាត្រា*២៥
### ការបោះពុម្ពផ្សាយ

[កំណត់ពន្យល់-មាត្រា៣០(១)(iii)]

សាធារណជន ត្រូវបានជូនដំណឹងតាមរយៈការបោះពុម្ពផ្សាយព័ត៌មានជាទៀងទាត់ពាក់ព័ន្ធនឹង:

- ការដាក់ពាក្យស្នើសុំនិងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ និង

* លេខមាត្រាដែលមិនដូចនិងលេខមាត្រា ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ត្រូវមានសញ្ញាផ្កាយនៅពីមុខ។

- ការដាក់ឈ្មោះដែលបានស្នើនិងបានយល់ព្រម។

**មាត្រា*២៦**

**[បទបញ្ញា]និង/ឬ[សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី]**

[កំណត់ពន្យល់-មាត្រា៣០]

[អាជ្ញាធរមានសមត្ថកិច្ច/រដ្ឋមន្ត្រី] អាចបង្កើតបទបញ្ញានានា ឬចេញសេចក្តីសម្រេចនានាលើបញ្ហាណាមួយដែលទាមទារចំពោះការអនុវត្តន៍ច្បាប់នេះ ជាពិសេសៈ

(១) បញ្ហានីតិវិធីដែលពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

(២) បញ្ហានានាពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំ

(៣) បញ្ហានានាពាក់ព័ន្ធនឹងការត្រួតពិនិត្យការដាក់ពាក្យស្នើសុំផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

(៤) លក្ខខណ្ឌការបោះពុម្ពផ្សាយ

(៥) នីតិវិធីប្តឹងទាស់

(៦) ប្តឹងឧទ្ធរណ៍

(៧) តារាងកម្រៃ និង

(៨) ទិន្នន័យដែលត្រូវបញ្ចូលក្នុងបញ្ជីដែលពាក់ព័ន្ធនឹងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

**មាត្រា*២៧**

**ការចូលជាធរមាន**

ច្បាប់នេះត្រូវចូលជាធរមានតាម [...]

---

* លេខនៃមាត្រានានាដែលមិនដូចនឹងលេខមាត្រានៃច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ ត្រូវមានសញ្ញាផ្កាយនៅពីមុខ។

## ជំពូកទី ២ កំណត់នានាផ្អែកលើឯកសារព័ត៌មានពាក់ព័ន្ធនឹងមាត្រាមួយចំនួននៃច្បាប់ឆ្នាំ១៩៩១ របស់អនុសញ្ញាយូប៉ូវ


កំណត់ពន្យល់ចំពោះមាត្រា១ និយមន័យ.....................................................៣០

កំណត់ពន្យល់ចំពោះមាត្រា៣ អំបូរនិងប្រភេទពូជដែលត្រូវការពារ.................៣៥

កំណត់ពន្យល់ចំពោះមាត្រា៤ ប្រព្រឹត្តិកម្មជាតិ.............................................៣៧

កំណត់ពន្យល់ចំពោះមាត្រា៥ លក្ខខណ្ឌដើម្បីការពារ....................................៣៩

កំណត់ពន្យល់ចំពោះមាត្រា៦ ភាពថ្មី............................................................៤៣

កំណត់ពន្យល់ចំពោះមាត្រា៧ ភាពខុសប្លែក..................................................៤៩

កំណត់ពន្យល់ចំពោះមាត្រា៨ ឯកសណ្ឋានភាព............................................៥១

កំណត់ពន្យល់ចំពោះមាត្រា៩ ស្ថេរភាព........................................................៥៣

កំណត់ពន្យល់ចំពោះមាត្រា១០ ការដាក់ពាក្យស្នើសុំ.....................................៥៥

កំណត់ពន្យល់ចំពោះមាត្រា១១ សិទ្ធិអាទិភាព.............................................៥៧

កំណត់ពន្យល់ចំពោះមាត្រា១២ ការត្រួតពិនិត្យពាក្យស្នើសុំ...........................៦៥

កំណត់ពន្យល់ចំពោះមាត្រា១៣ កិច្ចការពារបណ្ដោះអាសន្ន..........................៧១

កំណត់ពន្យល់ចំពោះមាត្រា១៤ វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ...................៧៥

កំណត់ពន្យល់ចំពោះមាត្រា១៥ ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ..........៩១

កំណត់ពន្យល់ចំពោះមាត្រា១៦ ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ.........................១០១

កំណត់ពន្យល់ចំពោះមាត្រា១៧ ការកម្រិតការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ......១០៣

កំណត់ពន្យល់ចំពោះមាត្រា១៨ វិធានគ្រប់គ្រងពាណិជ្ជកម្ម..................................១០៥

កំណត់ពន្យល់ចំពោះមាត្រា១៩ រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ............១០៧

កំណត់ពន្យល់ចំពោះមាត្រា២០ ការដាក់ឈ្មោះពូជដំណាំ......................................១០៩

កំណត់ពន្យល់ចំពោះមាត្រា២១ មោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ............. ........១៣៩

កំណត់ពន្យល់ចំពោះមាត្រា២២ ការលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំ.................១៤១

កំណត់ពន្យល់ចំពោះមាត្រា៣០ ការអនុវត្តន៍អនុសញ្ញា.........................................១៤៣

# ជំពូកទី ២ :
# កំណត់ពន្យល់នានាផ្អែកលើឯកសារព័ត៌មានពាក់ព័ន្ធនឹងមាត្រាមួយចំនួន នៃច្បាប់ឆ្នាំ១៩៩១ របស់អនុសញ្ញាយូប៉ូវ

## កំណត់ពន្យល់ចំពោះមាត្រា១ និយមន័យ

### មាត្រា១(iv) "អ្នកបង្កាត់ពូជដំណាំ"

(iv) អ្នកបង្កាត់ពូជដំណា "សំដៅដល់:

- បុគ្គល ដែលបង្កាត់ឬរកឃើញ និងអភិវឌ្ឍពូជដំណាំ
- បុគ្គលដែលជានិយោជកនៃបុគ្គលដែលបានរៀបរាប់ខាងលើឬបុគ្គលដែលបានជួលឱ្យធ្វើការងារឱ្យគាត់ ដែលច្បាប់នៃភាគីហត្ថលេខីដែលពាក់ព័ន្ធបានចែងបែបនោះ ឬ
- អ្នកទទួលសិទ្ធិពីបុគ្គលទី១ឬទី២ ដូចបានរៀបរាប់ខាងលើ តាមករណីនីមួយៗ

## មាត្រា១(vi) "ពូជ"

" ពូជ " សំដៅដល់ ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយដែលគេស្គាល់តិចបំផុត ទោះជាមិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្តី ដែលអាចៈ

- ត្រូវកំណត់ដោយការបង្ហាញចរិតលក្ខណៈ ដែលជាលទ្ធផលនៃគំរូហ្សែន ឬ បន្សំគំរូហ្សែន
- ត្រូវខុសប្លែកពីក្រុមរុក្ខជាតិផ្សេងទៀត តាមរយៈការបង្ហាញយ៉ាងហោចណាស់នូវលក្ខណៈណាមួយនៃចរិតលក្ខណៈខាងលើ ហើយ
- ត្រូវចាត់ទុកជា ក្រុមមួយ ចំពោះលទ្ធភាព ដែលអាចដាំដុះបន្តដោយមិនផ្លាស់ប្តូរ។

កថាខណ្ឌនានាខាងក្រោមពន្យល់ពីទិដ្ឋភាពមួយចំនួននៃនិយមន័យនៃពូជ។

(*i*) ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយដែលគេស្គាល់តិចបំផុត

១. និយមន័យនៃ "ពូជ" តាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ផ្តើមដោយចែងថា ជា"ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយដែលគេស្គាល់តិចបំផុត..." ដែលតាមរយៈនេះបញ្ជាក់ថា ពូជដំណាំមួយ ជាឧទាហរណ៍ មិនអាចមានដំណាំច្រើនជាងមួយប្រភេទទេ។

២. ការឱ្យនិយមន័យថា ពូជ ជា "ក្រុមរុក្ខជាតិ" បញ្ជាក់ថា ចំណុចខាងក្រោម ជាឧទាហរណ៍ មិនទាក់ទងនឹងនិយមន័យនៃពូជៈ

– ដំណាំតែមួយ (ប៉ុន្តែ ដំណាំដែលមានស្រាប់អាចតំណាងដោយដំណាំតែមួយឬផ្នែក(ផ្នែកនានា) នៃដំណាំ ឱ្យតែ ដំណាំនេះឬផ្នែក(ផ្នែកនានា)នៃដំណាំនេះ អាចត្រូវបានប្រើប្រាស់ដើម្បីដាំដុះពូជដំណាំបាន)

– លក្ខណៈមួយ( ដូចជា ការធន់នឹងជម្ងឺ ពណ៌ផ្កា)

– សារធាតុគីមីឬសារធាតុផ្សេងទៀត(ដូចជា ប្រេង DNA)

– បច្ចេកវិទ្យាបង្កាត់ពូជដំណាំ( ដូចជា ការបណ្តុះជាលិកា)។

(ii) ទោះជា មិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្តី

៣. និយមន័យនៃ "ពូជ" ក្នុងមាត្រា១(vi) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ចែងថា ក្រុមរុក្ខជាតិនៃចំណាត់ថ្នាក់តែមួយដែលគេស្គាល់តិចបំផុត អាចជាពូជដំណាំទោះជាមិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្តី។ដូច្នេះនិយមន័យនៃ"ពូជ" គឺមានភាពទូលាយជាង "ពូជដែលអាចការពារបាន"។

៤. និយមន័យនៃ "ពូជ" ដើរតួយ៉ាងសំខាន់ក្នុងបរិបទនៃការត្រួតពិនិត្យភាពខុសប្លែក។ មាត្រា៧ ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ចែងថា ពូជដំណាំត្រូវចាត់ទុកថា មានភាពខុសប្លែកពីគេលុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។ ពាក្យ "ទោះជាមិនបានបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំក្តី" បញ្ជាក់ឱ្យច្បាស់ថា ពូជដំណាំនានាដែលគេស្គាល់ជាទូទៅដែលមិនត្រូវបានការពារ ប៉ុន្តែ អាចនៅតែជាពូជដំណាំដែលដូចនឹងនិយមន័យនៃពូជ ក្នុងមាត្រា១(vi) ដែលបេក្ខភាពពូជដំណាំ(Candidate Variety) ( ពូជដំណាំមួយដែលបានដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ) ត្រូវតែមានភាពខុសគ្នាដាច់ស្រឡះ។ មគ្គុទ្ទេសក៍ស្តីពីពូជដំណាំដែលគេស្គាល់ជាទូទៅ មានចែងក្នុងឯកសារ TG/1/3 " សេចក្តីណែនាំទូទៅចំពោះការត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាពនិងស្ថេរភាព និងការអភិវឌ្ឍន៍សេចក្តីអធិប្បាយនៃពូជថ្មីនៃដំណាំដែលបានធ្វើសុខុដុមនីយកម្ម និង ឯកសារ TGP/4/1 " ការបង្កើតនិងការរក្សា ការប្រមូលផ្តុំពូជដំណាំ"។

៥. ជាទូទៅ អាជ្ញាធរ មិនត្រួតពិនិត្យ ថាតើ "បេក្ខភាពពូជដំណាំ" ដូចនឹងនិយមន័យនៃ ពូជតាមមាត្រា១(vi) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវឡើយ ។ អាជ្ញាធរ ត្រូវត្រួតពិនិត្យថាតើការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ បំពេញលក្ខខណ្ឌទាំងឡាយចំពោះការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ជាពិសេសរួមបញ្ចូល ថាតើ បេក្ខភាពពូជដំណាំមានភាពខុសប្លែក មានឯកសណ្ឋានភាព និងមានស្ថេរភាព(DUS)ដែររឺទេ។ ពូជដំណាំមួយដែលបានបំពេញលក្ខណៈវិនិច្ឆ័យនៃ DUS នឹងត្រូវតាមនិយមន័យនៃពូជ។ ជាទូទៅ ក្នុងករណីបដិសេធន៍ការដាក់ពាក្យស្នើសុំ អាជ្ញាធរនឹងមិនបង្ហាញថាតើ អាជ្ញាធរគិតថាបេក្ខភាពពូជដំណាំ ដូចឬមិនដូចទៅនឹងនិយមន័យនៃ"ពូជ"ឡើយ។

(iii) ត្រូវកំណត់ដោយការបង្ហាញចរិតលក្ខណៈ ដែលជាលទ្ធផលនៃគំរូហ្សែន ឬ បន្សំគំរូហ្សែន

៦.សញ្ញាណនៃ"បន្សំនៃគំរូហៃ្សន" គ្របដណ្ដប់លើពូជដំណាំសំយោគ និងពូជបង្កាត់ទំនើប (hybrids)ជាដើម។

(iv) ត្រូវចាត់ទុកជា ក្រុមមួយ ចំពោះលទ្ធភាព ដែលអាចដាំដុះបន្ត ដោយមិនផ្លាស់ប្ដូរ

៧. អនុសញ្ញាយូប៉ូវ មិនកម្រិតពីមធ្យោបាយដែលពូជដំណាំអាចត្រូវបានដាំដុះដោយមិនផ្លាស់ប្ដូរឡើយ។ ក្នុងករណីពូជដំណាំមួយចំនួន ដូចជា ពូជដំណាំដែលដាំដុះបន្តដោយមិនប្រើគ្រាប់ ឬ លម្អង ពូជដំណាំស្វ័យលម្អង និងពូជដំណាំលម្អងកាត់ ពូជដំណាំមួយ អាចត្រូវបានដាំដុះដោយមិនផ្លាស់ប្ដូរពីដំណាំនៃប្រភេទពូជដំណាំខ្លួនឯង។ ក្នុងករណីពូជដំណាំផ្សេងទៀតដូចជាពូជបង្កាត់ទំនើប (hybrid variety) និងពូជដំណាំសំយោគ (synthetic variety) ពូជដំណាំនេះ អាចត្រូវបានដាំដុះដោយមិនផ្លាស់ប្ដូរ ដោយវដ្ដនៃការដាំដុះ ដែលអាចទាក់ទងនឹងដំណាំនានាក្រៅពីដំណាំនៃពូជនេះ។ វដ្ដនៃការដាំដុះនេះ អាចទាក់ទងនឹងការឆ្លងជាធម្មតានៃខ្សែមេបាពីរ (ឧទាហរណ៍ ពូជបង្កាត់ទំនើបធម្មតា(Simple hybrid)) ឬអាចទាក់ទងនឹងវដ្ដដ៏ស្មុគស្មាញនៃការដាំដុះ(ឧទាហរណ៍ ពូជបង្កាត់ទំនើបបីផ្លូវ ពូជដំណាំសំយោគ ។ល។) ឧទាហរណ៍មួយចំនួននៃវិធីសាស្រ្តដាំដុះពូជដំណាំ អាចរកបានក្នុងឯកសារ TGP/7 "ការអភិវឌ្ឍន៍នៃមគ្គុទ្ទេសក៍ពិសោធន៍" ឧបសម្ព័ន្ធ៣ "កំណត់មគ្គុទ្ទេសក៍" GN31 "ព័ត៌មានស្ដីពីវិធីសាស្រ្តនៃការដាំដុះពូជដំណាំ" និង GN32 "ព័ត៌មានស្ដីពីវិធីសាស្រ្តនៃការដាំដុះពូជដំណាំកូនកាត់" [ការយោងឆ្លង]។

## មាត្រា ១(viii) "ដែនដី"

(viii) "ដែនដី " ក្នុងទំនាក់ទំនងជាមួយភាគីហត្ថលេខី នៅពេលដែលភាគីហត្ថលេខីជារដ្ឋ សំដៅដល់ដែនដីនៃរដ្ឋនោះ ហើយបើជាអង្គការអន្តររដ្ឋាភិបាល សំដៅដល់ដែនដីដែលអនុវត្តសន្ធិសញ្ញាដែលបង្កើតអង្គការអន្តររដ្ឋាភិបាលនោះ

មាត្រា៦(៣) ដែលពាក់ព័ន្ធនឹង "ភាពថ្មី" និង មាត្រា១៦(៣) ដែលពាក់ព័ន្ធនឹងការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ មានបទប្បញ្ញត្តិស្តីពី "ដែនដីក្នុងករណីមួយចំនួន"។

## មាត្រា១(ix) "អាជ្ញាធរ"

(ix) "អាជ្ញាធរ" សំដៅដល់ អាជ្ញាធរ ដូចមានចែងក្នុងមាត្រា៣០(១)(ii) [ សូមមើល មាត្រា២ ជំពូកទី១នៃឯកសារនេះ]

មាត្រា៣០(១)(ii) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ តម្រូវថា សមាជិកមួយនៃយូប៉ូវត្រូវគ្រប់គ្រងអាជ្ញាធរទទួលបន្ទុកការងារផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬត្រូវផ្តល់ការងារនេះទៅអាជ្ញាធរដែលគ្រប់គ្រងដោយសមាជិកណាមួយផ្សេងទៀតនៃយូប៉ូវ។

## កំណត់ពន្យល់ចំពោះមាត្រា៣ អំបូរនិងប្រភេទពូជដែលត្រូវការពារ

(១) [រដ្ឋដែលជាសមាជិកហើយ នៃសហភាព] ភាគីហត្ថលេខីនីមួយៗដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦១/១៩៧២ ឬ ច្បាប់ឆ្នាំ១៩៧៨ ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ:

- (i) ត្រឹមកាលបរិច្ឆេទដែលភាគីហត្ថលេខី ចងភ្ជាប់ដោយអនុសញ្ញានេះ ចំពោះ អំបូរនិងប្រភេទពូជដំណាំទាំងអស់ ដែលខ្លួនអនុវត្តក្នុងបទ-ប្បញ្ញត្តិនៃច្បាប់ឆ្នាំ១៩៦១/១៩៧២និងច្បាប់ឆ្នាំ១៩៧៨តាមកាលបរិច្ឆេទនេះ ហើយ
- (ii) យូរបំផុត ត្រឹមផុតកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនេះ ចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់

(២) [ សមាជិកថ្មីនៃសហភាព] ភាគីហត្ថលេខីនីមួយៗ ដែលមិនចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៦១/១៩៧២ ឬច្បាប់ឆ្នាំ១៩៧៨ ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ:

- (i) ត្រឹមកាលបរិច្ឆេទដែលភាគីហត្ថលេខី ចងភ្ជាប់ដោយអនុសញ្ញានេះ ចំពោះអំបូរនិងប្រភេទពូជដំណាំយ៉ាងហោចណាស់១៥(ដប់ប្រាំ) ហើយ
- (ii) យូរបំផុតត្រឹមផុតកំណត់រយៈពេល១០(ដប់)ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទនេះ ចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់។

១.១ រដ្ឋឬអង្គការអន្តររដ្ឋាភិបាលទាំងឡាយ ជាដំបូង អាចអនុវត្តបទប្បញ្ញត្តិទាំងឡាយ នៃអនុសញ្ញាយូប៉ូវ ចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់។ នៅពេលដែលច្បាប់នៃរដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលដែលពាក់ព័ន្ធ ជាដំបូង មិនអនុវត្តចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់ លក្ខខណ្ឌអប្បបរមាគឺត្រូវអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ឆ្នាំ១៩៩១ នៃអនុ-សញ្ញាយូប៉ូវ:

១.១.១ រដ្ឋដែលជាសមាជិកហើយ នៃយូប៉ូវ

ចំពោះអំបូរនិងប្រភេទពូជដំណាំដែលខ្លួនអនុវត្តត្រឹមកាលបរិច្ឆេទចូលជាធរមានច្បាប់ ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ បទប្បញ្ញត្តិទាំងឡាយនៃច្បាប់មុននៃអនុសញ្ញាយូប៉ូវដែលខ្លួនចងភ្ជាប់និងយូរបំផុតត្រឹមផុតកំណត់រយៈពេល៥(ឆ្នាំ) ចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់( សូមមើលមាត្រា៣(១)(i)និង(ii) នៃច្បាប់ឆ្នាំ១៩៩១)

១.១.២ សមាជិកថ្មីនៃយូប៉ូវ

ចំពោះ អំបូរឬប្រភេទពូជចំនួន១៥(ដប់ប្រាំ) ត្រឹមកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញាយូប៉ូវ និង យូរបំផុតត្រឹមផុតកំណត់រយៈពេល១០(ដប់)ឆ្នាំ រាប់ពីកាលបរិច្ឆេទនេះចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់(សូមមើលមាត្រា៣(២)(i)និង(ii)នៃច្បាប់ឆ្នាំ១៩៩១)។

១.២ នៅពេលដែលច្បាប់នៃរដ្ឋឬអង្គការអន្តររដ្ឋាភិបាលដែលពាក់ព័ន្ធ មិនចែងពីកិច្ចការពារចំពោះអំបូរ និងប្រភេទពូជដំណាំទាំងអស់ លក្ខខណ្ឌដែលត្រូវការពារ អាចត្រូវបានបញ្ជាក់ដោយការបង្ហាញបញ្ជីអំបូរ និងប្រភេទពូជដំណាំដោយឈ្មោះរុក្ខជាតិ។

១.៣ មគ្គុទ្ទេសក៍ស្តីពីព័ត៌មានដែលអាចមានក្នុងទម្រង់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំដើម្បីជួយអ្នកដាក់ពាក្យស្នើសុំក្នុងការកំណត់ថាតើអំបូរឬប្រភេទពូជដំណាំ ជាពូជដំណាំដែលច្បាប់អនុវត្ត គឺមានចែងក្នុងឯកសារ TGP/5 “បទពិសោធន៍និងកិច្ចសហប្រតិបត្តិការក្នុងការធ្វើពិសោធន៍DUS” ជំពូកទី២ “ទម្រង់គំរូរបស់យូប៉ូវចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ” (សូមមើល សេចក្តីណែនាំពីការបំលែងទម្រង់គំរូរបស់យូប៉ូវចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំទៅជាទម្រង់របស់អាជ្ញាធរផ្ទាល់:**ខ**ចំនុចទី៣)។

## កំណត់ពន្យល់ចំពោះមាត្រា៤ ប្រព្រឹត្តិកម្មជាតិ

(១) [ប្រព្រឹត្តិកម្ម] ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដែលមានចែងក្នុងអនុសញ្ញានេះ ពលរដ្ឋនៃភាគីហត្ថលេខី ក៏ដូចជារូបវន្តបុគ្គលដែលមានលំនៅ និងនីតិបុគ្គលដែលមានការិ-យាល័យដែលបានចុះបញ្ជីក្នុងដែនដីនៃភាគីហត្ថលេខីមួយ ចំពោះការផ្តល់និងកិច្ចការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវទទួល ក្នុងដែនដីនៃភាគីហត្ថលេខីផ្សេងទៀត នូវប្រព្រឹត្តិកម្មដូចគ្នានឹងប្រព្រឹត្តិកម្មដែលបានផ្តល់ ឬអាចត្រូវបានផ្តល់ នាពេលបន្ទាប់ដោយច្បាប់នៃភាគីហត្ថលេខីនីមួយៗផ្សេងទៀតចំពោះពលរដ្ឋរបស់ខ្លួន ឱ្យតែពលរដ្ឋទាំងនេះ ទោះជារូបវន្តបុគ្គលឬនីតិបុគ្គលក្តី អនុលោមតាមលក្ខខណ្ឌនិងបែបបទ ដែលបានតម្រូវដល់ពលរដ្ឋនៃភាគីហត្ថលេខីផ្សេងទៀតនេះ។

(២) [ពលរដ្ឋ] សម្រាប់គោលបំណងនៃកថាខណ្ឌខាងលើ "ពលរដ្ឋ" នៅពេលដែលភាគីហត្ថលេខីជារដ្ឋគឺពលរដ្ឋនៃរដ្ឋនេះ ហើយបើភាគីហត្ថលេខី ជាអង្គការអន្តររដ្ឋាភិបាល គឺពលរដ្ឋនៃរដ្ឋដែលជាសមាជិកនៃអង្គការនេះ។

១.១ ទាក់ទងនឹងការដាក់ពាក្យស្នើសុំ បទប្បញ្ញត្តិនៃប្រព្រឹត្តិកម្មជាតិមិនតម្រូវឡើយ ប្រសិនបើ ច្បាប់មិនបានដាក់កំហិតលើសញ្ជាតិ ទីកន្លែងនៃលំនៅឋានរបស់រូបវន្តបុគ្គល ឬទីកន្លែងដែលការិយាល័យបានចុះបញ្ជីចំពោះនីតិបុគ្គល។

១.២ ប្រសិនបើច្បាប់ចែងពីបទប្បញ្ញត្តិនៃប្រព្រឹត្តិកម្មជាតិ អាជ្ញាធរអាចស្នើឱ្យមានព័ត៌មានចាំបាច់ក្នុងទម្រង់ពាក្យស្នើសុំដើម្បីកំណត់ ដោយផ្អែកលើសញ្ជាតិ ទីកន្លែងនៃលំនៅឋានឬទីកន្លែងនៃការិយាល័យដែលបានចុះបញ្ជីនៃអ្នកដាក់ពាក្យស្នើសុំ(តាមករណីនីមួយៗ)ថាតើអ្នកដាក់ពាក្យស្នើសុំ មានសិទ្ធិដាក់ពាក្យស្នើសុំដែររឺទេ។ ទម្រង់គំរូរបស់យូប៉ូវ ចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ ( ឯកសារ TGP/5 "បទពិសោធន៍និងកិច្ចសហប្រតិបត្តិការក្នុងការធ្វើពិសោធន៍ DUS" ជំពូកទី២ ចំនុចទី១)ត្រូវផ្តល់ការស្នើព័ត៌មានដូចខាងក្រោម

| |
|---|
| **១. (ក) អ្នកដាក់ពាក្យស្នើសុំ(ច្រើន)**[១] |
| **ឈ្មោះ(ច្រើន)** ________________ |
| យូប៉ូវ-ក១: ១(ក)(i) |
| **អាសយដ្ឋាន(ច្រើន)** ________________ |
| យូប៉ូវ-ក១: ១(ក)(ii) |
| **ទូរស័ព្ទលេខ(ច្រើន)** ________________ |

យូប៉ូវ-ក១: ១(ក)(iii)

**ទូរសារលេខ(ច្រើន)** ________________________________

យូប៉ូវ-ក១: ១(ក)(iv)

**អ៊ីម៉ែល(ច្រើន)** ________________________________

យូប៉ូវ-ក១: ១(ក)(v)

**(ខ) សញ្ជាតិ(ច្រើន):** ________________________________

យូប៉ូវ-ក១: ១(ខ)

**(គ) លំនៅឋាន(រដ្ឋ):** ________________________________

យូប៉ូវ-ក១: ១(គ)

**(ឃ) ការិយាល័យដែលបានចុះបញ្ជីចំពោះនីតិបុគ្គល(រដ្ឋ):** ________________

យូប៉ូវ-ក១: ១(ឃ)

**(ង) នីតិវិធីតំណាង/ភ្នាក់ងារ/ប្រទានសិទ្ធិ នឹងត្រូវប្រើ:** ☐**មែន** ☐ **មិនមែន**

យូប៉ូវ-ក១: ១(ង)(i) យូប៉ូវ-ក១: ១(ង)(ii)

________________

១. អ្នកដាក់ពាក្យស្នើសុំ គួរជាអ្នកបង្កាត់ពូជដំណាំ ដោយអនុលោមតាមនិយមន័យ អ្នកបង្កាត់ពូជដំណាំ ក្នុងមាត្រា១ (iv) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ដែលជា:

- បុគ្គល ដែលបង្កាត់ឬរកឃើញ និងអភិវឌ្ឍពូជដំណាំ
- បុគ្គលដែលជានិយោជកនៃបុគ្គល ដែលបានរៀបរាប់ខាងលើ ឬបុគ្គលដែលបានជួលឱ្យធ្វើការងារឱ្យគាត់ដែលច្បាប់នៃភាគីហត្ថលេខីដែលពាក់ព័ន្ធបានចែងបែបនោះ ឬ
- អ្នកទទួលសិទ្ធិពីបុគ្គល ទី១ ឬទី២ដូចបានរៀបរាប់ខាងលើ តាមករណីនីមួយៗ

## កំណត់ពន្យល់ចំពោះមាត្រា៥ លក្ខខណ្ឌដើម្បីការពារ

(១) [ លក្ខណៈវិនិច្ឆ័យដែលត្រូវបំពេញ]សិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវផ្តល់ឱ្យ នៅពេលដែលពូជដំណាំ :

(i) ថ្មី

(ii) ភាពខុសប្លែក

(iii) ឯកសណ្ឋានភាព និង

(iv) ស្ថេរភាព។

(២) [លក្ខខណ្ឌផ្សេងទៀត] ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ មិនត្រូវបំពេញលក្ខ-ខណ្ឌបន្ថែមឬផ្សេងទៀតឡើយ ឱ្យតែពូជដំណាំនេះត្រូវបានកំណត់ដោយការដាក់ឈ្មោះស្របតាមបទប្បញ្ញត្តិនៃមាត្រា២០ ហើយឱ្យតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមទម្រង់ដូចមានចែងក្នុងច្បាប់នៃភាគីហត្ថលេខី ជាមួយអាជ្ញាធរនៃភាគីហត្ថលេខី ដែលពាក្យស្នើសុំបានដាក់ និងបានបង់កម្រៃដែលបានកំណត់។

ទាក់ទងនឹងបទប្បញ្ញត្តិទាំងឡាយតាមមាត្រា៥(២) ច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ នាកិច្ចប្រជុំសាមញ្ញលើកទី៣៧របស់ខ្លួន ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៣ ក្រុមប្រឹក្សាយូប៉ូវ បានអនុម័ត "ការឆ្លើយតបរបស់យូប៉ូវ ចំពោះសេចក្តីជូនដំណឹងចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៣ពីលេខាធិការប្រតិបត្តិនៃអនុសញ្ញាស្តីពីជីវចំរុះ(CBD)"
http://www.upov.int/news/en/2003/pdf/cbd_response_oct232003.pdf (កថាខណ្ឌទី៧ ដល់ទី១១ ត្រូវបានស្រង់ឡើងវិញដូចខាងក្រោម)។

### ការបង្ហាញប្រភពដើម

"៧.លក្ខខណ្ឌចំពោះភាពខុសប្លែក ក្នុងអនុសញ្ញាយូប៉ូវ[១] មានន័យថា កិច្ចការពារត្រូវបានផ្តល់ឱ្យតែបន្ទាប់ពីការត្រួតពិនិត្យដើម្បីកំណត់ថាតើពូជដំណាំ មានភាពខុសគ្នាដាច់ស្រឡះពីពូជផ្សេងទៀតទាំងអស់ ដែលគេស្គាល់ជាទូទៅ[២] ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ ដោយមិនគិតពីប្រភពដើមនៃភូមិសាស្ត្រ។ ជាងនេះទៅទៀត

[១] យោងទៅអនុសញ្ញាយូប៉ូវ ឯកសារនេះគួរត្រូវបានយល់ថាជាការយោងទៅច្បាប់ចុងក្រោយបំផុតនៃអនុសញ្ញាយូប៉ូវ (ច្បាប់ឆ្នាំ១៩៩១)។អត្ថបទទាំងមូលនៃអនុសញ្ញាយូប៉ូវអាចរកបានតាម: http://www.upov.int/upovlex/en/conventions/1991/pdf/act/1991.pdf.

[២] បញ្ហានៃការស្គាល់ជាទូទៅត្រូវបានពិចារណាបន្ថែមក្នុងឯកសារយូប៉ូវ "សញ្ញាណនៃអ្នកបង្កាត់ពូជដំណាំនិងការស្គាល់ជាទូទៅ"(C(Extr.)/19/2Rev.)។ឯកសារនេះអាចរកបាននៅ: http://www.upov.int/about/en/pdf/c_extr_19_2_rev.pdf.

អនុសញ្ញាយូប៉ូវ ចែងថា ប្រសិនបើរកឃើញថា សិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវបានផ្តល់ឱ្យពូជដំណាំ ដែលមិនមានភាពខុសប្លែក សិទ្ធិនេះត្រូវបានប្រកាសមោឃភាព។

“៨.អ្នកបង្កាត់ពូជដំណាំ ជាទូទៅ ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រវត្តិការបង្កាត់ពូជនិងហ្សែនដើមនៃពូជដំណាំ ក្នុងបញ្ជីសំនួរបច្ចេកទេសមួយដែលអមជាមួយពាក្យស្នើសុំឱ្យការពាររបស់ខ្លួន។ យូប៉ូវ ជំរុញឱ្យផ្តល់ព័ត៌មានស្តីពីប្រភពដើមនៃបំណែក ពូជដំណាំដែលប្រើក្នុងការបង្កាត់ពូជដំណាំ នៅពេលដែលព័ត៌មាននេះជួយសម្រួល ដល់ការត្រួតពិនិត្យដូចបានលើកឡើងខាងលើ ប៉ុន្តែមិនអាចទទួលយកព័ត៌មាន ជាលក្ខខណ្ឌបន្ថែមនៃកិច្ចការពារឡើយ ដោយសារអនុសញ្ញាយូប៉ូវ ចែងថា កិច្ចការពារគួរត្រូវបានផ្តល់ឱ្យចំពោះពូជដំណាំទាំងឡាយដែលបំពេញលក្ខខណ្ឌ ថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព ស្ថេរភាព និងការដាក់ឈ្មោះសមរម្យ ហើយមិនអនុញ្ញាតឱ្យមានលក្ខខណ្ឌដើម្បីការពារបន្ថែមឬផ្សេងណាមួយឡើយ។ តាមពិត ក្នុងករណីមួយចំនួនសម្រាប់ហេតុផលបច្ចេកទេស អ្នកដាក់ពាក្យស្នើសុំ អាចយល់ថាពិបាកឬ ធ្វើមិនបានក្នុងការបង្ហាញប្រភពដើមនៃភូមិសាស្ត្រពិតនៃបំណែកពូជទាំងអស់ដែលប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជ។

“៩. ក្នុងក្របខ័ណ្ឌគោលនយោបាយទូទៅរបស់ខ្លួន ប្រសិនបើប្រទេសមួយសម្រេចដាក់ចេញយន្តការមួយ ចំពោះការបង្ហាញប្រទេសដើមឬប្រភពដើមនៃភូមិសាស្ត្រនៃធនធានហ្សែន យន្តការនេះមិនគួរដាក់ចេញក្នុងន័យចង្អៀត ជាលក្ខខណ្ឌដើម្បីការពារពូជដំណាំឡើយ។ យន្តការដោយឡែកពីច្បាប់ការពារពូជដំណាំ ដូចជា យន្តការដែលប្រើសម្រាប់លក្ខខណ្ឌភូតគាមអនាម័យ អាចត្រូវបានអនុវត្តដូចគ្នាចំពោះសកម្មភាពទាំងអស់ពាក់ព័ន្ធនឹងអាជីវកម្មពូជដំណាំដោយ រួមទាំង គុណភាពពូជដំណាំ ឬបទបញ្ញាផ្សេងទៀតដែលទាក់ទងនឹងការធ្វើចរាចរក្នុងទីផ្សារ ជាដើម។

**ការជូនដំណឹងពីការយល់ព្រមជាមុន**

១០. ទាក់ទងនឹងលក្ខខណ្ឌណាមួយ ចំពោះសេចក្តីប្រកាសថាបំណែកហ្សែនត្រូវបានទទួលដោយស្របច្បាប់ឬ មានភស្តុតាងថា ការជូនដំណឹងពីការយល់ព្រមជាមុនពាក់ព័ន្ធនឹងការទទួលបានបំណែកហ្សែន យូប៉ូវជំរុញឱ្យមានគោលការណ៍តម្លាភាពនិងក្រម-សីលធម៌ក្នុងសកម្មភាពបង្កាត់ពូជដំណាំ ហើយក្នុងបញ្ហានេះ ការទទួលបានបំណែកហ្សែនដែលត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍន៍ពូជថ្មី គួរត្រូវបានធ្វើដោយគោរពតាមក្របខ័ណ្ឌច្បាប់នៃប្រទេសដើមរបស់បំណែកហ្សែន។ ប៉ុន្តែអនុសញ្ញាយូប៉ូវ តម្រូវថា សិទ្ធិអ្នកបង្កាត់ពូជដំណាំមិនគួរអនុលោមតាមលក្ខខណ្ឌបន្ថែម ឬលក្ខខណ្ឌផ្សេងពីលក្ខខណ្ឌដើម្បីទទួល

បានកិច្ចការពារឡើយ។ កំណត់នានារបស់យូប៉ូវ ដែលស្របតាមមាត្រា១៥នៃ CBD ដែលចែងថា ការកំណត់ការទទួលបានធនធានហ្សែន អាស្រ័យលើរដ្ឋាភិបាលជាតិ និងជាកម្មវត្ថុនៃច្បាប់ជាតិ។ ជាងនេះទៅទៀត យូប៉ូវ ចាត់ទុកថា អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ មិនមានសមត្ថកិច្ចក្នុងការផ្ទៀងផ្ទាត់ថាតើការទទួលបានបំណែកហ្សែនត្រូវបានធ្វើឡើងតាមច្បាប់ដែលអនុវត្តក្នុងវិស័យនេះឡើយ។

**សង្ខេប**

១១.ដោយសារច្បាប់ស្តីពីការទទួលបំណែកហ្សែននិងច្បាប់ទាក់ទងនឹងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ មានកម្មវត្ថុផ្សេងគ្នា មានវិសាលភាពនៃការអនុវត្តន៍ផ្សេងគ្នា និងតម្រូវរចនាសម្ព័ន្ធរដ្ឋបាលផ្សេងគ្នាដើម្បីត្រួតពិនិត្យការអនុវត្តន៍របស់ខ្លួន យូប៉ូវយល់ឃើញថា ជាការសមស្របដើម្បីបញ្ចូលចំនុចខាងលើក្នុងច្បាប់ផ្សេងគ្នា ទោះបីបើច្បាប់នេះគួរស្របគ្នា និងគាំទ្រគ្នាទៅវិញទៅមកក៏ដោយ។

## កំណត់ពន្យល់ចំពោះមាត្រា៦ ភាពថ្មី

[ សូមមើលផងដែរ "កំណត់ចំពោះមាត្រា១២ ចំពោះគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យអនុលោមភាពនឹងលក្ខខណ្ឌភាពថ្មី"]

(១) [លក្ខណៈវិនិច្ឆ័យ] ពូជដំណាំដែលចាត់ទុកថាថ្មី ត្រឹមកាលបរិច្ឆេទការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ លុះត្រាតែបំណែកពូជដែលអាចយកទៅដាំដុះបាន ឬបំណែកពូជដែលប្រមូលផលបានពីការដាំដុះ ពុំទាន់ដាក់លក់ ឬដាក់បង្ហាញទៅបុគ្គលដទៃទៀត ដោយអ្នកបង្កាត់ពូជដំណាំ ឬដោយមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ ក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ[...]។

### បំណែកពូជដំណាំ

១.១ ដូចមានចែងក្នុងច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ បទប្បញ្ញត្តិនៃភាពថ្មី ពាក់ព័ន្ធនឹងបំណែកពូជដែលអាចយកទៅដាំដុះបាននិងបំណែកពូជដែលប្រមូលផលបាន។

ការដាក់លក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀត ដោយអ្នកបង្កាត់ពូជដំណាំ ឬមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំសម្រាប់គោលបំណងធ្វើអាជីវកម្មពូជដំណាំ (ការដាក់លក់និងចរាចរ ដោយមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ)

១.២ ច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ បញ្ជាក់ថា ភាពថ្មី ត្រូវប៉ះពាល់តែនៅពេលដែលមានការលក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀត (ឬដាក់លក់ឬចរាចរ ចំពោះច្បាប់ឆ្នាំ១៩៧៨) នៃបំណែកពូជដែលអាចយកទៅដាំដុះបានឬបំណែកពូជដែលប្រមូលផលបានដោយអ្នកបង្កាត់ពូជដំណាំឬមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ[៣]សម្រាប់គោលបំណងធ្វើអាជីវកម្មពូជដំណាំ។

---

[៣] ពាក្យ "អ្នកបង្កាត់ពូជដំណាំ" គួរត្រូវបានយល់ដូចកំណត់ក្នុងមាត្រា១(iv) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ:

- បុគ្គល ដែលបង្កាត់ឬរកឃើញ និងអភិវឌ្ឍពូជដំណាំ
- បុគ្គលដែលជានិយោជកនៃបុគ្គលដែលបានរៀបរាប់ខាងលើ ឬបុគ្គលដែលបានជួលឱ្យធ្វើការងារឱ្យគាត់ ដែលច្បាប់នៃភាគីហត្ថលេខីដែលពាក់ព័ន្ធបានចែងបែបនោះ ឬ
- អ្នកទទួលសិទ្ធិពីបុគ្គលទី១ឬទី២ ដូចបានរៀបរាប់ខាងលើ តាមករណីនីមួយៗ។

ពាក្យ បុគ្គល ក្នុងមាត្រា១(iv) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ គួរត្រូវបានយល់រួមបញ្ចូលទាំង រូបវន្តបុគ្គលនិងនីតិបុគ្គល(ដូចជា ក្រុមហ៊ុនជាដើម)។

១.៣ សកម្មភាពខាងក្រោមអាចចាត់ទុកថាមិនបណ្តាលឱ្យបាត់បង់ភាពថ្មី:

(i) ការពិសោធន៍ពូជដំណាំដែលមិនទាក់ទងនឹងការលក់ឬការដាក់បង្ហាញទៅអ្នកដទៃក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ(ដែលបានបញ្ជាក់ក្នុងច្បាប់ឆ្នាំ១៩៧៨)

(ii) ការលក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀតដោយគ្មានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ

(iii)ការលក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀតដែលជាផ្នែកនៃកិច្ចព្រមព្រៀងស្តីពីការផ្ទេរសិទ្ធិ ទៅអ្នកទទួលបានសិទ្ធិ

(iv)ការលក់ ឬការដាក់បង្ហាញទៅបុគ្គលដទៃទៀត ដែលជាផ្នែកនៃកិច្ចព្រមព្រៀងដែលបុគ្គលម្នាក់បង្កើនបំណែកពូជ ដែលអាចយកទៅដាំដុះបាន ក្នុងនាមអ្នកបង្កាត់ពូជដំណាំ នៅពេលដែលកិច្ចព្រមព្រៀងនេះ ទាមទារឱ្យទ្រព្យសម្បត្តិ ដែលកើតចេញពីការបង្កើនបំណែកនេះ ត្រូវបង្វិលទៅឱ្យអ្នកបង្កាត់ពូជដំណាំវិញ

(v) ការលក់ ឬការដាក់បង្ហាញទៅបុគ្គលដទៃទៀត ដែលជាផ្នែកនៃកិច្ចព្រមព្រៀងដែលបុគ្គលម្នាក់សន្យាធ្វើពិសោធន៍ដល់កន្លែងឬធ្វើពិសោធន៍នៅមន្ទីរពិសោធន៍ ឬធ្វើដំណើរការពិសោធន៍បរិមាណតិច ដើម្បីវាយតម្លៃពូជដំណាំ

(vi) ការលក់ឬការដាក់បង្ហាញទៅបុគ្គលដទៃទៀត ដែលជាផ្នែកនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ឬរដ្ឋបាល ជាពិសេសពាក់ព័ន្ធនឹងជីវៈសុវត្ថិភាពឬការបញ្ចូលពូជដំណាំក្នុងបញ្ជីពូជដំណាំផ្លូវការដែលអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្ម

(vii) ការលក់ ឬការដាក់បង្ហាញទៅបុគ្គលដទៃទៀត នៃបំណែកពូជដែលប្រមូលផលបាន ជាផលិតផលឬជាផលិតផលលើសពីការបង្កើតពូជដំណាំឬពីសកម្មភាព ដូចមានចែង ក្នុងចំនុច(iv)ដល់(vi)ខាងលើ ឱ្យតែបំណែកនេះ ត្រូវបានលក់ឬដាក់បង្ហាញដោយ គ្មានអត្តសញ្ញាណពូជដំណាំក្នុងគោលបំណងប្រើប្រាស់ និង

(viii)ការដាក់បង្ហាញទៅបុគ្គលដទៃទៀត ក្នុងគោលបំណងបង្ហាញពូជដំណាំក្នុងពិព័ណជាផ្លូវការ ឬដែលទទួលស្គាល់ជាផ្លូវការ។

### មាត្រា៦(១)

(១) [លក្ខណៈវិនិច្ឆ័យ] ពូជដំណាំដែលចាត់ទុកថាថ្មី ត្រឹមកាលបរិច្ឆេទការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ លុះត្រាតែបំណែកពូជដែលអាចយកទៅដាំដុះបាន ឬបំណែកពូជដែលប្រមូលផលបានពីការដាំដុះ ពុំទាន់ដាក់លក់ ឬ ដាក់បង្ហាញទៅបុគ្គលដទៃទៀត ដោយអ្នកបង្កាត់ពូជដំណាំ ឬ ដោយមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ

ក្នុងគោល បំណងធ្វើអាជីវកម្មពូជដំណាំ:

(i) ក្នុងដែនដីនៃភាគីហត្ថលេខី ដែលការដាក់ពាក្យស្នើសុំបានធ្វើ ក្នុងរយៈពេល មិនលើសពីមួយឆ្នាំមុនកាលបរិច្ឆេទនេះ និង

(ii) ក្រៅដែនដីភាគីហត្ថលេខី ដែលពាក្យស្នើសុំបានដាក់មុនរយៈពេល៤(បួន)ឆ្នាំ ឬ ក្នុងករណីដំណាំឈើ ឬដំណាំវល្លិ បានដាក់មុនរយៈពេល៦(ប្រាំមួយ)ឆ្នាំ មុនកាលបរិច្ឆេទនេះ

## រយៈពេលពាក់ព័ន្ធ

១.៤ រយៈពេលផ្សេងៗគ្នាចំពោះការលក់ ឬការដាក់បង្ហាញពូជដំណាំក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ ក្នុងដែនដីសមាជិកនៃសហភាព នៅពេលដែលពាក្យស្នើសុំត្រូវបានដាក់ហើយ ក្នុងដែនដីផ្សេងទៀតដោយគ្មានប៉ះពាល់ភាពថ្មី ត្រូវបានបង្កើតឡើងក្នុងការទទួលស្គាល់ទំហំនៃការវាយតម្លៃ ដោយអ្នកបង្កាត់ពូជដំណាំ ក្នុងដែនដីនីមួយៗ ដើម្បីសម្រេចស្វែងរកកិច្ចការពារ។ រយៈពេលវែងជាងចំពោះដំណាំឈើនិងវល្លិបានពិចារណាទៅលើការលូតលាស់និងការកើនឡើងយឺតនៃប្រភេទដំណាំទាំងនេះ។

១.៥ យូប៉ូវ មានការផ្លាស់ប្តូរព័ត៌មានស្តីពីសញ្ញាណនៃដំណាំឈើនិងដំណាំវល្លិ សម្រាប់គោលបំណងនៃបទប្បញ្ញត្តិស្តីពីភាពថ្មី និងរយៈពេលការពារ(មាត្រា១៩នៃច្បាប់ឆ្នាំ១៩៩១ និងមាត្រា៨នៃច្បាប់ឆ្នាំ១៩៧៨) ការផ្លាស់ប្តូរនេះ បង្ហាញថា មានការបកស្រាយផ្សេងគ្នាពីសញ្ញាណនៃដំណាំឈើនិងដំណាំវល្លិ ហើយថា វាមិនអាចទៅរួចក្នុងការបង្កើតចំណាត់ថ្នាក់មួយក្នុងកម្រិតយូប៉ូវ។ ព័ត៌មានស្តីពីសញ្ញាណនៃដំណាំឈើនិងដំណាំវល្លិ សម្រាប់សមាជិកនីមួយៗនៃសហភាព អាចទទួលបានដោយមើលច្បាប់ដែលទាក់ទងរបស់សមាជិកសហភាពដែលពាក់ព័ន្ធ(សូមមើលគេហទំព័ររបស់យូប៉ូវ: http://www.upov.int/upovlex/en/#notified)។

## មាត្រា៦(២) [បទប្បញ្ញត្តិជាជម្រើស]

(២) [ពូជដំណាំដែលបង្កើតថ្មី] នៅពេលដែលភាគីហត្ថលេខី អនុវត្តអនុសញ្ញានេះចំពោះអំបូរ ឬប្រភេទពូជដំណាំមួយដែលភាគីហត្ថលេខីពីមុនមិនបានអនុវត្តអនុសញ្ញានេះ ឬច្បាប់មុន ភាគីនេះអាចចាត់ទុកពូជដំណាំដែលបង្កើតថ្មី ដែលមានត្រឹមកាលបរិច្ឆេទនៃការពង្រីកកិច្ចការពារ ថាបានបំពេញលក្ខខណ្ឌថ្មី ដូចមានចែងក្នុងកថាខណ្ឌទី១ ទោះបីបើការដាក់លក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀត ដូចមានចែងក្នុងកថាខណ្ឌនោះ ប្រព្រឹត្តិទៅមុខការកម្រិតរយៈពេលដូចមានចែងក្នុងកថាខណ្ឌនោះក៏ដោយ។

ពូជដំណាំដែលបង្កើតថ្មី

២.១ បទប្បញ្ញត្តិ "អន្តរកាល" ចំពោះពូជដំណាំដែលបង្កើតថ្មី ជាបទប្បញ្ញត្តិជាជម្រើស។ គោលបំណងនៃបទប្បញ្ញត្តិអន្តរកាលស្តីពីភាពថ្មី គឺអនុញ្ញាតឱ្យមានកិច្ចការពារពូជដំណាំដែលបានបង្កើតមុនមានកិច្ចការពារដំបូងបន្តិច ប៉ុន្តែមិនស្ថិតក្នុងរយៈពេលចំពោះភាពថ្មីដូចមានចែងក្នុងមាត្រា៦(១)(i) នៃច្បាប់ឆ្នាំ១៩៩១។ គំនិតមួយដែលត្រូវបានជ្រើសរើសដើម្បីបង្ហាញបទប្បញ្ញត្តិនេះ ដែលប្រកាន់យកដោយសមាជិកសហភាព គឺ ត្រូវឱ្យមានរយៈពេលដូចគ្នា ចំពោះការលក់ឬការដាក់បង្ហាញពូជដំណាំក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំក្នុងដែនដីនៃសមាជិកសហភាព ក៏ដូចចំពោះពូជដំណាំក្នុងដែនដីផ្សេងទៀតក្រៅពីសមាជិកនៃសហភាពដែលពាក់ព័ន្ធ ដូចជាក្នុងរយៈពេល៤(បួន)ឆ្នាំ ឬ ក្នុងករណីដំណាំឈើឬដំណាំវល្លិ ក្នុងរយៈពេល៦(ប្រាំមួយ)ឆ្នាំ។ ក្នុងករណីបញ្ចូលបទប្បញ្ញត្តិអន្តរកាល ជាការសមស្របដើម្បីកំណត់រយៈពេលសម្រាប់អ្នកបង្កាត់ពូជដំណាំ ដើម្បីទាមទារអត្ថប្រយោជន៍ពីបទ-ប្បញ្ញត្តិអន្តរកាលនេះ។

២.២ បទប្បញ្ញត្តិអន្តរកាលស្តីពីរបបគតិយុត្តនៃភាពថ្មី ចំពោះពូជដំណាំដែលបង្កើតថ្មី អាចបញ្ចូលក្នុងច្បាប់ដែលចែងជាលើកដំបូងពីកិច្ចការពារពូជដំណាំ ឱ្យស្របនឹងអនុសញ្ញាយូប៉ូវចំពោះសមាជិកទាំងនោះ នៅពេលដែលកិច្ចការពារត្រូវបានកម្រិតចំពោះបញ្ជីនៃអំបូរនិងប្រភេទពូជដំណាំ អាចបញ្ចូលបទប្បញ្ញត្តិអន្តរកាល ស្តីពីរបបគតិយុត្តនៃភាពថ្មីអន្តរកាលពេលដែលមានកិច្ចការពារចំពោះអំបូរឬប្រភេទពូជបន្ថែមនេះ ឬ ចំពោះអំបូរនិងប្រភេទពូជដំណាំទាំងអស់។

២.៣ បទប្បញ្ញត្តិជាឧទាហរណ៍ដូចខាងក្រោម មានចេតនាផ្តល់ជាជំនួយដល់រដ្ឋ/អង្គការ

អន្តររដ្ឋាភិបាលទាំងឡាយ ដែលចង់បញ្ចូលបទប្បញ្ញត្តិជាជម្រើសនៃមាត្រា៦(២) ច្បាប់ឆ្នាំ ១៩៩១ នៃអនុសញ្ញាយូប៉ូវ "ពូជដំណាំដែលបង្កើតថ្មី" ក្នុងច្បាប់របស់ខ្លួន។

## មាត្រា [៦]
## ភាពថ្មី

[(១)] [លក្ខណៈវិនិច្ឆ័យ] ពូជដំណាំដែលចាត់ទុកថាថ្មី ត្រឹមកាលបរិច្ឆេទការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ លុះត្រាតែបំណែកពូជដែលអាចយកទៅដាំដុះបាន ឬបំណែកពូជដែលប្រមូលផលបាន ពីការដាំដុះ ពុំទាន់ដាក់លក់ ឬ ដាក់បង្ហាញទៅបុគ្គលដទៃទៀត ដោយអ្នកបង្កាត់ពូជដំណាំ ឬដោយមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ ក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ:

(i) ក្នុងដែនដីនៃ[ឈ្មោះនៃរដ្ឋ/អង្គការអន្តររដ្ឋាភិបាល] មិនលើសពី១(មួយ)ឆ្នាំមុនកាលបរិច្ឆេទដាក់ពាក្យស្នើសុំ និង

(ii) ក្រៅដែនដីនៃ[ឈ្មោះនៃរដ្ឋ/អង្គការអន្តររដ្ឋាភិបាល]មិនលើសពី៤(បួន)ឆ្នាំ ឬក្នុងករណីដំណាំឈើឬដំណាំវល្លិ មិនលើសពី៦(ប្រាំមួយ)ឆ្នាំ មុនកាលបរិច្ឆេទនេះ

[(២)] [ពូជដំណាំដែលបង្កើតថ្មី] [អនុលោមតាមមាត្រា[ដាក់លេខ]] នៅពេលដែលអនុវត្តអនុសញ្ញានេះ ចំពោះអំបូរ ឬប្រភេទពូជដំណាំមួយដែលពីមុនមិនបានអនុវត្ត ពូជដំណាំដែលជាអំបូរឬប្រភេទពូជដំណាំនេះត្រូវចាត់ទុកថាបានបំពេញលក្ខខណ្ឌថ្មី ដូចមានចែងក្នុងកថាខណ្ឌ[ទី១]នៃមាត្រា[នេះ] ទោះបីបើការដាក់លក់ឬដាក់បង្ហាញទៅអ្នកដទៃ ដូចមានចែងក្នុងកថាខណ្ឌនោះ ប្រព្រឹត្តិទៅក្នុងដែនដីនៃ[ឈ្មោះនៃរដ្ឋ/អង្គការអន្តររដ្ឋាភិបាល] ក្នុងរយៈពេល៤(បួន)ឆ្នាំមុនកាលបរិច្ឆេទដាក់ពាក្យសុំឬក្នុងករណីដំណាំឈើឬដំណាំវល្លិក្នុងរយៈពេល៦(ប្រាំមួយ)ឆ្នាំមុនកាលបរិច្ឆេទនេះ។

[(៣)] បទប្បញ្ញត្តិតាមកថាខណ្ឌទី[(២)]នៃមាត្រា[នេះ] ត្រូវអនុវត្តតែចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលបានដាក់ក្នុងរយៈពេល១(មួយ)ឆ្នាំ យ៉ាងយូរបំផុតបន្ទាប់ពីបទប្បញ្ញត្តិនៃច្បាប់ត្រូវអនុវត្តចំពោះអំបូរឬប្រភេទពូជដែលពាក់ព័ន្ធ។

## មាត្រា៦(៣)

["ដែនដី"ក្នុងករណីមួយចំនួន]សម្រាប់គោលបំណនៃកថាខណ្ឌទី(១) ភាគីហត្ថលេខីទាំងអស់ដែលជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលមួយដូចគ្នា នៅពេលដែលវិធានរបស់អង្គការតម្រូវ អាចចាត់វិធានការរួមគ្នា ដើម្បីប្រៀបប្រដូចសកម្មភាព ដែលប្រព្រឹត្តិលើដែនដីនៃរដ្ឋសមាជិករបស់អង្គការ ទៅនឹងសកម្មភាពដែលធ្វើឡើងក្នុងដែនដីរបស់ខ្លួនផ្ទាល់

ហើយបើធ្វើបែបនេះ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ។

## កំណត់ពន្យល់ចំពោះមាត្រា៧  ភាពខុសប្លែក

ពូជដំណាំ ត្រូវចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។ ដោយឡែក ការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬ ការបញ្ចូលពូជដំណាំផ្សេងក្នុងបញ្ជីពូជដំណាំជាផ្លូវការ ក្នុងប្រទេសណាមួយ ត្រូវចាត់ទុកថាបានធ្វើឱ្យពូជដំណាំផ្សេងនេះស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆទនៃការដាក់ពាក្យស្នើសុំ លុះត្រាតែការដាក់ពាក្យនេះឈានដល់ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬឈានដល់ការបញ្ចូលពូជដំណាំនេះ ក្នុងបញ្ជីពូជដំណាំជាផ្លូវការ តាមករណីនីមួយៗ។

មគ្គុទ្ទេសក៍ស្តីពីការត្រួតពិនិត្យភាពខុសប្លែក អាចរកបានក្នុងឯកសារនានាដូចខាងក្រោមៈ

- ឯកសារ TG/1/3 "សេចក្តីណែនាំជាទូទៅចំពោះការត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព និងការអភិវឌ្ឍន៍សេចក្តីអធិប្បាយដែលបានធ្វើសុខដុមនីយកម្មនៃពូជថ្មីនៃដំណាំ" ("សេចក្តីណែនាំទូទៅ")
- ឯកសារ TGP/4/1 "ការបង្កើតនិងការរក្សា ការប្រមូលផ្តុំពូជដំណាំ"
- ឯកសារ TGP/9/1 "ការត្រួតពិនិត្យភាពខុសប្លែក"។

## កំណត់ពន្យល់ចំពោះមាត្រា៨ ឯកសណ្ឋានភាព

ពូជដំណាំដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ អាចរក្សាឯកសណ្ឋានគ្រប់គ្រាន់ លើកលែងតែមានការប្រែប្រួលលក្ខណៈពិសេសនៃការដាំដុះ។

មគ្គុទ្ទេសក៍ស្តីពីការត្រួតពិនិត្យឯកសណ្ឋានភាព អាចរកបានក្នុង "សេចក្តីណែនាំទូទៅ ចំពោះការត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព និងការអភិវឌ្ឍន៍សេចក្តីអធិប្បាយដែលបានធ្វើសុខដុមនីយកម្មពូជថ្មីនៃដំណាំ" (ឯកសារ TG/1/3"សេចក្តីណែនាំទូទៅ" និង ក្នុងឯកសារ TGP/10 "ការត្រួតពិនិត្យឯកសណ្ឋានភាព"។

## កំណត់ពន្យល់ចំពោះមាត្រា៩ ស្ថេរភាព

ពូជដំណាំដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈពាក់ព័ន្ធរបស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ ឬ ក្នុងករណីវដ្តដោយឡែកនៃការលូតលាស់ គឺគ្មានការប្រែប្រួលពេលបញ្ចប់វដ្តនីមួយៗ។

មគ្គុទ្ទេសក៍ស្តីពីការត្រួតពិនិត្យស្ថេរភាព អាចរកបានក្នុង សេចក្តីណែនាំទូទៅចំពោះការត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព និងការអភិវឌ្ឍន៍សេចក្តីអធិប្បាយដែលបានធ្វើសុខដុមនីយកម្ម ពូជថ្មីនៃដំណាំ" (ឯកសារ TG/1/3 "សេចក្តីណែនាំទូទៅ" និង ក្នុងឯកសារ TGP/11 "ការត្រួតពិនិត្យស្ថេរភាព"។

## កំណត់ពន្យល់ចំពោះមាត្រា១០ ការដាក់ពាក្យស្នើសុំ

(១) [ទីកន្លែងនៃការដាក់ពាក្យស្នើសុំលើកដំបូង] អ្នកបង្កាត់ពូជដំណាំអាចជ្រើសរើសអាជ្ញាធរនៃភាគីហត្ថលេខី ដែលគាត់ចង់ដាក់ពាក្យស្នើសុំលើកដំបូង ដើម្បីទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

(២) [ពេលវេលានៃពាក្យស្នើសុំបន្ទាប់] អ្នកបង្កាត់ពូជដំណាំអាចដាក់ពាក្យទៅអាជ្ញាធរនៃភាគីហត្ថលេខីផ្សេងទៀត ដើម្បីទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំដោយមិនរងចាំការផ្តល់សិទ្ធិដោយអាជ្ញាធរនៃភាគីហត្ថលេខី ដែលបានដាក់ពាក្យលើកដំបូងឡើយ។

(៣) [ឯករាជ្យភាពនៃកិច្ចការពារ] គ្មានភាគីហត្ថលេខីណា បដិសេធមិនផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬកម្រិតរយៈពេលការពារ ដោយមូលហេតុថាកិច្ចការពារពូជដំណាំតែមួយមិនបានដាក់ពាក្យសុំ ត្រូវបានបដិសេធ ឬបានហួសរយៈពេល ក្នុងរដ្ឋឬអង្គការអន្តររដ្ឋាភិបាលណាមួយផ្សេងទៀត។

១.១ ទម្រង់គំរូរបស់យូប៉ូវ ចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ(ឯកសារTGP/5 "បទពិសោធន៍និងកិច្ចសហការណ៍ក្នុងការធ្វើពិសោធDUS" ផ្នែកទី២) ផ្តល់ជាមគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍន៍ទម្រង់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ។.

១.២ ចំពោះបញ្ជីសំនួរបច្ចេកទេសយូប៉ូវ ដែលត្រូវបំពេញទាក់ទងនឹងពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ សូមមើលឯកសារ TGP/5 "បទពិសោធន៍និងកិច្ចសហការណ៍ក្នុងការធ្វើពិសោធន៍ DUS" ផ្នែកទី៣)។

## កំណត់ពន្យល់ចំពោះមាត្រា១១ សិទ្ធិអាទិភាព

## មាត្រា១១(១)

(១) [សិទ្ធិ រយៈពេល] អ្នកបង្កាត់ពូជដំណាំ ដែលបានដាក់ពាក្យស្នើសុំការពារពូជដំណាំត្រឹមត្រូវ ក្នុងភាគីហត្ថលេខីណាមួយ ("ពាក្យស្នើសុំដំបូង") ក្នុងគោលបំណងដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំចំពោះពូជដំណាំតែមួយ នៅអាជ្ញាធរនៃភាគីហត្ថលេខីណាមួយផ្សេងទៀត (ពាក្យស្នើសុំបន្ទាប់) ត្រូវទទួលសិទ្ធិអាទិភាពក្នុងរយៈពេល១២(ដប់ពីរ)ខែ។ រយៈពេលនេះត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង។ ថ្ងៃនៃការដាក់ពាក្យមិនរាប់បញ្ចូលជាកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូងឡើយ។

១.១ អនុសញ្ញាយូប៉ូវ ចែងពីសិទ្ធិអាទិភាព១២(ដប់ពីរ)ខែ ផ្អែកតាមពាក្យស្នើសុំការពារពូជដំណាំតែមួយពីមុន ដែលដាក់នៅសមាជិកផ្សេងទៀតនៃយូប៉ូវ ហេតុនេះពាក្យស្នើសុំបន្ទាប់ត្រូវទទួលប្រព្រឹត្តិកម្មដូចជាបានដាក់តាមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង។ នៅចុងបញ្ចប់នៃកំណត់ពន្យល់ទាំងនេះចំពោះមាត្រា១១ មានការបង្ហាញឧទាហរណ៍ជាសម្មតិកម្មពីទិដ្ឋភាពផ្សេងគ្នាពាក់ព័ន្ធនឹងសិទ្ធិអាទិភាព។

១.២ កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង យោងទៅកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំដំបូង ដែលបានដាក់ត្រឹមត្រូវដូចបានកំណត់ក្នុងច្បាប់សមាជិកនៃសហភាពដែលពាក់ព័ន្ធ។

**ភាពថ្មីនិងសិទ្ធិអាទិភាព**

១.៣ សិទ្ធិអាទិភាព មានអានុភាពទាក់ទងនឹងការដាក់លក់ឬបង្ហាញពូជដំណាំក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំដោយមិនធ្វើឱ្យប៉ះពាល់ដល់ភាពថ្មី(មាត្រា៦(១)(i)និង(ii)ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ)។ កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូងនៅអាជ្ញាធរនៃសមាជិកយូប៉ូវមួយ ("សមាជិកយូប៉ូវ ក") ត្រូវចាត់ទុកជាកាលបរិច្ឆេទនៃពាក្យស្នើសុំបន្ទាប់ដែលបានដាក់នៅអាជ្ញាធរនៃសមាជិកផ្សេងទៀត ("ពាក្យស្នើសុំបន្ទាប់ដែលបានដាក់នៅសមាជិក យូប៉ូវ ខ") ។ ដូច្នេះ បទប្បញ្ញត្តិមាត្រា៦(១) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ គួរមានអានុភាពដូចខាងក្រោម:

ពាក្យស្នើសុំបន្ទាប់: ភាពថ្មី

ពាក្យស្នើសុំដំបូង: សមាជិក ក

ដាក់ពាក្យស្នើសុំបន្ទាប់: សមាជិក ខ

ពូជដំណាំត្រូវចាត់ទុកថាថ្មី ប្រសិនបើ នៅ[កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំការពារពូជដំណាំដំបូងនៅសមាជិកយូប៉ូវក] បំណែកពូជដែលអាចយកទៅដាំដុះបានឬបំណែកពូជដែលប្រមូលផលបាននៃពូជដំណាំ មិនត្រូវបានលក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀតដោយឬមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ ក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ

(i) ក្នុងដែនដីនៃ[សមាជិកយូប៉ូវខ] មិនលើសពី១(មួយ)ឆ្នាំមុន[កាលបរិច្ឆេទនៃការដាក់ពាក្យនៅសមាជិកយូប៉ូវ ក(ពាក្យស្នើសុំដំបូង)] និង

(ii) ក្រៅដែនដី[សមាជិកយូប៉ូវខ] មិនលើសពី៤(បួន)ឆ្នាំ ឬក្នុងករណីដំណាំឈើឬដំណាំវល្លិ មិនលើសពី៦(ប្រាំមួយ)ឆ្នាំ មុន[កាលបរិច្ឆេទនៃការដាក់ពាក្យនៅសមាជិកយូប៉ូវក(ពាក្យស្នើសុំដំបូង)]

**ភាពខុសប្លែកនិងសិទ្ធិអាទិភាព**

១.៤ ចំពោះការគោរពតាមលក្ខខណ្ឌភាពខុសប្លែក សិទ្ធិអាទិភាពមានអានុភាពដូចខាងក្រោម: ការដាក់ពាក្យស្នើសុំចំពោះពូជដំណាំផ្សេងទៀតក្នុងដែនដីណាមួយ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូងនៅសមាជិកមួយនៃយូប៉ូវ (សមាជិកយូប៉ូវ ក) នឹងមិនធ្វើឱ្យពូជដំណាំដែលមានស្រាប់ទាំងនេះត្រូវបានស្គាល់ជាទូទៅ ចំពោះការដាក់ពាក្យស្នើសុំបន្ទាប់។ ដូច្នេះបទប្បញ្ញត្តិមាត្រា៧ ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ នឹងមានអានុភាពដូចខាងក្រោម:

| |
|---|
| ពាក្យស្នើសុំបន្ទាប់:ភាពខុសប្លែក<br>ពាក្យស្នើសុំដំបូង:សមាជិក ក<br>ការដាក់ពាក្យស្នើសុំបន្ទាប់: សមាជិក ខ<br>ពូជដំណាំត្រូវចាត់ទុកថាមានភាពខុសប្លែកពីគេលុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ[កិច្ចការពារពូជដំណាំនៅសមាជិកយូប៉ូវ ក]។ ដោយឡែក ការដាក់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬ ការបញ្ចូលពូជដំណាំផ្សេងក្នុងបញ្ជីពូជដំណាំជាផ្លូវការ ក្នុងប្រទេសណាមួយត្រូវចាត់ទុកថាបាន ធ្វើឱ្យពូជដំណាំផ្សេងទៀត ស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យ លុះត្រាតែការដាក់ពាក្យនេះ ឈានដល់ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬ ឈានដល់ការបញ្ចូលពូជដំណាំផ្សេងទៀតនេះក្នុងបញ្ជីពូជដំណាំជាផ្លូវការ តាមករណីនីមួយៗ។ |

១.៥ ក្នុងករណីជាច្រើន សិទ្ធិអាទិភាព នឹងមិនបង្កើតឱ្យមានវិបាកផ្សេងៗទាក់ទងនឹងភាពខុសប្លែក ដោយសារពូជដំណាផ្សេង ដែលជាកម្មវត្ថុនៃពាក្យស្នើសុំដាក់ក្នុងដែនដីណាមួយបន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង ត្រូវបានចាត់ទុកថាពូជដំណាំដែលជាកម្មវត្ថុនៃពាក្យស្នើសុំដំបូង ជាពូជដំណាំដែលគេស្គាល់ជាទូទៅចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង។

១.៦ ប៉ុន្តែសិទ្ធិអាទិភាព បង្កើតឱ្យមានវិបាកដោយឡែកមួយក្នុងករណីដែលពាក្យស្នើសុំដំបូងដាក់ក្នុងសមាជិកយូប៉ូវ ក មិនឈានដល់ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬឈានដល់ការបញ្ចូលក្នុងបញ្ជីពូជដំណាំជាផ្លូវការ (ដូចជាការបដិសេធន៍ ឬការដកពាក្យស្នើសុំដំបូង) ក្នុងករណីនេះ ហើយប្រសិនបើសិទ្ធិអាទិភាពត្រូវបានអះអាងដោយជោគជ័យក្នុង

ពាក្យស្នើសុំបន្ទាប់ ពូជដំណាំនឹងនៅតែត្រូវបានចាត់ទុកថា ជាពូជដំណាំដែលគេស្គាល់ជាទូទៅចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង។ បើគ្មានសិទ្ធិអាទិភាព ពូជដំណាំនឹងក្លាយជាពូជដំណាំដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំបន្ទាប់ (ប្រសិនបើពាក្យស្នើសុំបន្ទាប់ឈានដល់ការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ឬឈានដល់ការបញ្ចូលក្នុងបញ្ជីពូជដំណាំជាផ្លូវការ)។

ការដាក់ឈ្មោះពូជដំណាំនិងសិទ្ធិអាទិភាព

១.៧ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង ប្រសិនបើពាក្យស្នើសុំស្នើឱ្យមានការដាក់ឈ្មោះពូជដំណាំ ការដាក់ឈ្មោះពូជដំណាំដែលបានស្នើនេះ នឹងត្រូវចាត់ទុកជាផ្នែកនៃ "សិទ្ធិអាទិភាព" ក្នុងគោលបំណងនៃលក្ខខណ្ឌការដាក់ឈ្មោះពូជដំណាំ(សូមមើល មាត្រា ២០(២)និង(៤)នៃច្បាប់ឆ្នាំ១៩៩១ និងមាត្រា១៣(២)និង(៤)នៃច្បាប់ឆ្នាំ១៩៧៨)។ ដូច្នេះ សម្រាប់គោលបំណងនៃលក្ខខណ្ឌការដាក់ឈ្មោះពូជដំណាំ ក្នុងពាក្យស្នើសុំបន្ទាប់ចំពោះពូជដំណាំតែមួយ ប្រសិនបើការដាក់ឈ្មោះដូចគ្នាត្រូវបានស្នើ ពាក្យស្នើសុំបន្ទាប់នឹងត្រូវចាត់ទុកថាដូចបានដាក់តាមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង (សូមមើល "កំណត់ពន្យល់ស្តីពីការដាក់ឈ្មោះពូជដំណាំតាមអនុសញ្ញាយូប៉ូវ" (ឯកសារUPOV/INF/12 -កំណត់ពន្យល់៩(ខ)និង(គ))ពាក់ព័ន្ធនឹងសិទ្ធិមុននិងការចុះបញ្ជីការដាក់ឈ្មោះពូជដំណាំ)។

**មាត្រា១១(២)**

(២) [ការអះអាងសិទ្ធិ] ដើម្បីទទួលអត្ថប្រយោជន៍ពីសិទ្ធិអាទិភាព អ្នកបង្កាត់ពូជដំណាំត្រូវអះអាងសិទ្ធិអាទិភាពនៃពាក្យស្នើសុំដំបូង ក្នុងពាក្យស្នើសុំបន្ទាប់។ អាជ្ញាធរដែលទទួលពាក្យស្នើសុំបន្ទាប់ក្នុងរយៈពេលតិចជាង៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំបន្ទាប់ អាចស្នើសុំឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ឯកសារចម្លងនៃពាក្យស្នើសុំដំបូង ដោយបញ្ជាក់ថាជាឯកសារត្រឹមត្រូវដោយអាជ្ញាធរដែលទទួលពាក្យស្នើសុំនោះ។ គំរូ ឬភស្តុតាងផ្សេងទៀតដែលពូជដំណាំជាកម្មវត្ថុនៃពាក្យស្នើសុំទាំងពីរ ត្រូវតែដូចគ្នា។

២.១ ដើម្បីទទួលអត្ថប្រយោជន៍ពីសិទ្ធិអាទិភាព អ្នកបង្កាត់ពូជដំណាំត្រូវអះអាងសិទ្ធិអាទិ-ភាពនៃពាក្យស្នើសុំដំបូង ក្នុងពាក្យស្នើសុំបន្ទាប់។ ប្រសិនបើអ្នកបង្កាត់ពូជដំណាំមិនបានអះអាងអាទិភាពទេ ពាក្យស្នើសុំបន្ទាប់នឹងត្រូវចាត់ទុកថាបានដាក់ត្រឹមកាលបរិច្ឆេទនៃពាក្យស្នើសុំបន្ទាប់។

២.២ អនុសញ្ញាយូប៉ូវ ចែងថា អ្នកបង្កាត់ពូជដំណាំ ត្រូវមានរយៈពេលយ៉ាងហោចណាស់៣

(បី)ខែ រាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំបន្ទាប់ ដើម្បីផ្ញើច្បាប់ចម្លងនៃឯកសារដែលជាពាក្យស្នើសុំដំបូង។ រយៈពេលពិតប្រាកដ(មិនតិចជាង៣(បី)ខែ) ត្រូវកំណត់ក្នុងច្បាប់នៃសមាជិករបស់សហភាពដែលពាក់ព័ន្ធ។

២.៣ ទម្រង់គំរូយូប៉ូវ ចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ (ឯកសារTGP/5 "បទពិសោធន៍និងកិច្ចសហប្រតិបត្តិការណ៍ក្នុងការធ្វើពិសោធន៍DUS" ផ្នែកទី២ ចំនុច៧) ផ្តល់មូលដ្ឋានដល់ អ្នកបង្កាត់ពូជដើម្បីអះអាងអាទិភាពដូចខាងក្រោម:

> ៧. អាទិភាពត្រូវអះអាងចំពោះពាក្យស្នើសុំដែលបានដាក់នៅ(រដ្ឋ/អង្គការអន្តររដ្ឋាភិបាល) (ពាក្យស្នើសុំដំបូង) ____________ UPOV-ក១:៧(i) នៅ(កាលបរិច្ឆេទ) ____________ UPOV-ក១:៧(ii)
>
> តាមការដាក់ឈ្មោះ ____________ UPOV-ក១:៧(iii)
>
> ច្បាប់ចម្លងផ្លូវការមួយច្បាប់នៃពាក្យស្នើសុំដំបូង ដែលមានកាលបរិច្ឆេទដាក់ពាក្យ ត្រូវស្នើជាកាបញ្ជាក់[៤]អាទិភាព។ UPOV-ក១:៧(iv)
>
> [៤] ក្នុងរយៈពេលកំណត់(អប្បបរមា៣(បី)ខែ)

**មាត្រា១១(៣)**

(៣) [ឯកសារ និងបំណែកពូជ] អ្នកបង្កាត់ពូជដំណាំត្រូវបានផ្តល់រយៈពេល២(ពីរ)ឆ្នាំ បន្ទាប់ពីផុតរយៈពេលអាទិភាព ឬនៅពេលដែលពាក្យស្នើសុំដំបូងត្រូវបានបដិសេធន៍ឬដកចេញ ត្រូវបានផ្តល់ឱ្យរយៈពេលសមរម្យមួយ បន្ទាប់ពីការបដិសេធន៍ឬការដកពាក្យស្នើសុំ ដើម្បីផ្តល់ដល់អាជ្ញាធរនៃភាគីហត្ថលេខីដែលទទួលពាក្យស្នើសុំបន្ទាប់ នូវព័ត៌មានចាំបាច់ ឯកសារ ឬ បំណែកពូជផ្សេងៗ ដែលទាមទារក្នុងការត្រួតពិនិត្យ តាមមាត្រា១២ ដូចដែលតម្រូវដោយច្បាប់នៃភាគីហត្ថលេខី។

## ការផុតកំណត់រយៈពេលអាទិភាព

៣.១ អ្នកបង្កាត់ពូជដំណាំត្រូវបានអនុញ្ញាតឱ្យមានរយៈពេល២(ពីរ)ឆ្នាំ បន្ទាប់ពីផុតកំណត់រយៈពេលអាទិភាព (ឧទាហរណ៍ ២(ពីរ)ឆ្នាំនិង១២(ដប់ពីរ)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដំបូង) ដើម្បីផ្តល់ដល់អាជ្ញាធរនូវព័ត៌មាន ឯកសារ ឬបំណែកពូជចាំបាច់ដែលទាមទារក្នុងគោលបំណងត្រួតពិនិត្យ។

| | | |
|---|---|---|
| សមាជិកយូប៉ូវ ក | ពាក្យស្នើសុំដំបូង<br>កាលបរិច្ឆេទដាក់ពាក្យៈ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០៤ | |
| សមាជិកយូប៉ូវ ខ | ពាក្យស្នើសុំបន្ទាប់<br>កាលបរិច្ឆេទដាក់ពាក្យៈ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០០៥(អាទិភាពត្រូវបានអះអាង) | ក្នុងគោលបំណងត្រួតពិនិត្យតាមមាត្រា១២ អ្នកបង្កាត់ពូជដំណាំ ត្រូវបានអនុញ្ញាតឱ្យមានរយៈពេល ២(ពីរ)ឆ្នាំ បន្ទាប់ពីផុតកំណត់រយៈពេលអាទិភាព ដើម្បីផ្តល់ដល់អាជ្ញាធរនូវព័ត៌មាន ឯកសារ ឬ បំណែកពូជចាំបាច់: ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០៧ |

## ការបដិសេធន៍ឬការដកពាក្យស្នើសុំដំបូង

៣.២ អនុសញ្ញាយូប៉ូវ ចែងថា នៅពេលដែលពាក្យស្នើសុំដំបូងត្រូវបានបដិសេធន៍ឬដកចេញ អ្នកបង្កាត់ពូជដំណាំ ត្រូវបានអនុញ្ញាតឱ្យមាន "រយៈពេលសមរម្យ" បន្ទាប់ពីការបដិសេធន៍ឬការដកនេះ ដើម្បីផ្តល់ព័ត៌មាន ឯកសារ ឬបំណែកពូជ ចាំបាច់ដែលទាមទារក្នុងគោលបំណងត្រួតពិនិត្យ។ ដើម្បីសម្រេចលើ "រយៈពេលសមរម្យ" អាជ្ញាធរអាចពិចារណាលើកត្តានានា ដែលអាចមានឥទ្ធិពលលើរយៈពេលដែលត្រូវការរបស់អ្នកបង្កាត់

ពូជដំណាំ សម្រាប់ការបញ្ជូន ព័ត៌មាន ឯកសារ ឬបំណែកពូជ។ ដូច្នេះរយៈពេលដោយឡែកមិនអាចកំណត់ក្នុងច្បាប់បានឡើយ។

ឧទាហរណ៍ជាសម្មតិកម្មខាងក្រោម ផ្តល់ការបង្ហាញពីទិដ្ឋភាពផ្សេងគ្នាពាក់ព័ន្ធនឹងសិទ្ធិអាទិភាព:

| | | |
|---|---|---|
| សមាជិកយូប៉ូវ ក | ពាក្យស្នើសុំដំបូង កាលបរិច្ឆេទដាក់ពាក្យ: ថ្ងៃទី១៥ខែមីនាឆ្នាំ ២០០៤ | |
| សមាជិកយូប៉ូវ ខ | ពាក្យស្នើសុំបន្ទាប់ កាលបរិច្ឆេទដាក់ពាក្យ: ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០០៥(អាទិភាពត្រូវបានអះអាង) | អាទិភាពត្រូវបានទទួលស្គាល់ (កាលបរិច្ឆេទនៃពាក្យស្នើសុំនៅ ខ ក្នុងរយៈពេលអះអាងអាទិភាព ហើយអាទិភាពត្រូវបានអះអាងក្នុងពាក្យស្នើសុំដាក់នៅ ខ)។<br>ពាក្យស្នើសុំនៅសមាជិកយូប៉ូវ ខ ត្រូវចាត់ទុកថាបានដាក់នៅកាលបរិច្ឆេទដាក់នៅសមាជិកយូប៉ូវ ក ឧទាហរណ៍ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៤ |
| សមាជិកយូប៉ូវ គ | ពាក្យស្នើសុំបន្ទាប់ កាលបរិច្ឆេទដាក់ពាក្យ: ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០០៥( អាទិភាពមិនត្រូវបានអះអាង) | គ្មានអាទិភាព (កាលបរិច្ឆេទនៃពាក្យស្នើសុំនៅគ ក្នុងរយៈពេលអះអាងអាទិភាព ប៉ុន្តែ អាទិភាពមិនត្រូវបានអះអាងក្នុងពាក្យស្នើសុំដាក់ក្នុង គ) (សូមមើលកថាខណ្ឌទី(២))។<br>កាលបរិច្ឆេទដាក់ពាក្យនៅសមាជិកយូប៉ូវ គ គឺ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០០៥ |
| សមាជិកយូប៉ូវ ឃ | ពាក្យស្នើសុំបន្ទាប់ កាលបរិច្ឆេទដាក់ពាក្យ: ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៥( អាទិភាពត្រូវបានអះអាង) | គ្មានអាទិភាព( កាលបរិច្ឆេទនៃពាក្យស្នើសុំនៅ ឃ ហួសរយៈពេលអះអាងអាទិភាព)។<br>កាលបរិច្ឆេទដាក់ពាក្យនៅសមាជិកយូប៉ូវ ឃ គឺថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ |

## កំណត់ពន្យល់ចំពោះមាត្រា១២ ការត្រួតពិនិត្យពាក្យស្នើសុំ

សេចក្តីសម្រេចណាដែលផ្តល់សិទ្ធិឱ្យអ្នកបង្កាត់ពូជដំណាំ ត្រូវទាមទារឱ្យត្រួតពិនិត្យអនុលោមភាពជាមួយលក្ខខណ្ឌនៃមាត្រា៥ដល់មាត្រា៩។ ពេលកំពុងត្រួតពិនិត្យ អាជ្ញាធរអាចបណ្តុះពូជដំណាំ ឬធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀត ឱ្យគេបណ្តុះពូជដំណាំ ឬឱ្យគេធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀត ឬពិចារណាលើលទ្ធផលនៃការពិសោធន៍បណ្តុះ ឬការសាកល្បងផ្សេងទៀត ដែលបានធ្វើរួចហើយ។ក្នុងគោលបំណងត្រួតពិនិត្យ អាជ្ញាធរអាចទាមទារឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ព័ត៌មាន ឯកសារ ឬបំណែកពូជ ចាំបាច់នានា។

### ១. ភាពថ្មី

១.១ អនុសញ្ញាយូប៉ូវ តម្រូវឱ្យត្រួតពិនិត្យការបំពេញលក្ខខណ្ឌថ្មីដូចខាងក្រោម:

១.២ ដូចបានពន្យល់ក្នុងអនុសញ្ញាយូប៉ូវ ក្នុងគោលបំណងត្រួតពិនិត្យ អាជ្ញាធរអាចតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់រាល់ ព័ត៌មាន ឯកសារ ឬបំណែកពូជ ចាំបាច់នានា។ ចំពោះបញ្ហានេះ អាជ្ញាធរអាចស្នើឱ្យអ្នកបង្កាត់ពូជផ្តល់រាល់ព័ត៌មានចាំបាច់នានាសម្រាប់ត្រួតពិនិត្យភាពថ្មី ក្នុងទម្រង់ពាក្យស្នើសុំ។ ទម្រង់គំរូយូប៉ូវ ចំពោះពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ (ឯកសារ TGP/5 “បទពិសោធន៍និងកិច្ចសហប្រតិបត្តិការណ៍ក្នុងការធ្វើពិសោធន៍DUS” ផ្នែកទី២ ចំនុច៨) ផ្តល់ការស្នើព័ត៌មានដូចខាងក្រោម:

៨. ពូជដំណាំត្រូវបាន[លក់ឬដាក់បង្ហាញទៅបុគ្គលដទៃទៀត ដោយឬមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ ក្នុងគោលបំណងធ្វើអាជីវកម្មពូជដំណាំ][៥] / [ដាក់លក់ឬចរាចរដោយមានការព្រមព្រៀងពីអ្នកបង្កាត់ពូជដំណាំ][៦] (អាជ្ញាធរអាចលុបចោលបានតាមករណីសមស្រប)

ក្នុង[ដែនដីនៃពាក្យស្នើសុំ]: ____________________

*[ យូប៉ូវ-ក១:៨(៩១)(a)]/[យូប៉ូវ-ក១:៨(៧៨)(a)]*

☐ មិនទាន់ដាក់លក់ ☐ ជាលើកដំបូង(កាលបរិច្ឆេទ) ____________________

*[យូប៉ូវ-ក១:៨(៩១)(b)]/ [យូប៉ូវ-ក១:៨(៩១)(c)(i)]/ [យូប៉ូវ-ក១:៨(៩១)(c)(ii)]/*
*[យូប៉ូវ-ក១:៨(៧៨)(b)] [យូប៉ូវ-ក១:៨(៧៨)(c)(i)] [យូប៉ូវ-ក១:៨(៧៨)(c)(ii)]*

កំពុងដាក់ឈ្មោះ ____________________

*[យូប៉ូវ-ក១:៨(៩១)(c)(iii)]/ [យូប៉ូវ-ក១:៨(៧៨)(c)(iii)]*

និងក្នុងដែនដីផ្សេងទៀត: ____________________

*[យូប៉ូវ-ក១:៨(៩១)(d)(i)]/ [យូប៉ូវ-ក១:៨(៧៨)(d)(i)]*

☐ មិនទាន់ដាក់លក់ ☐ ជាលើកដំបូង (ដែនដី និងកាលបរិច្ឆេទ) ____________________

*[យូប៉ូវ-ក១:៨(៩១)(d)(ii)]/ [យូប៉ូវ-ក១:៨(៩១)(d)(iii)]/ [យូប៉ូវ-ក១:៨(៩១)(d)(iv)]/ [យូប៉ូវ-ក១:៨(៩១)(d)(v)]/*
*[យូប៉ូវ-ក១:៨(៧៨)(d)(ii)] [យូប៉ូវ-ក១:៨(៧៨)(d)(iii)] [យូប៉ូវ-ក១:៨(៧៨)(d)(iv)] [យូប៉ូវ-ក១:៨(៧៨)(d)(v)]*

កំពុងដាក់ឈ្មោះ ____________________

*[យូប៉ូវ-ក១:៨(៩១)(d)(vi)]/ [យូប៉ូវ-ក១:៨(៧៨)(d)(vi)]/*

---

[៥] .មាត្រា៦(១)នៃច្បាប់ឆ្នាំ១៩៩១។

[៦] មាត្រា៦(១)(ខ)នៃច្បាប់ឆ្នាំ១៩៧៨។

១.៣ មាត្រា៣០(១)(*iii*) នៃច្បាប់ឆ្នាំ១៩៩១ តម្រូវឱ្យ សមាជិកនីមួយៗនៃសហភាពធានាថា សាធារណជន ត្រូវបានជូនដំណឹងតាមរយៈការបោះពុម្ពផ្សាយជាទៀងទាត់នូវព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំនិងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។ ដំណើរការនៃការបោះពុម្ពផ្សាយព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំ អនុញ្ញាតឱ្យមានការជំទាស់ទៅអាជ្ញាធរ ទាក់ទងនឹងការគោរពតាមលក្ខខណ្ឌភាពថ្មី។

**២. ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព(DUS)**

មគ្គុទ្ទេសក៍ស្តីពីការត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព អាចរកបានក្នុងឯកសារនានាដូចខាងក្រោម:

២.១ "សេចក្តីណែនាំទូទៅសម្រាប់ត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព និងការអភិវឌ្ឍន៍សេចក្តីអធិប្បាយដែលបានធ្វើសុខដុមនីយកម្មពូជថ្មីនៃដំណាំ" (ឯកសារ TG/1/3 "សេចក្តីណែនាំទូទៅ")

២.២ "ការរៀបចំសម្រាប់ធ្វើពិសោធន៍DUS"(ឯកសារTGP/6)។

**៣. បទពិសោធន៍និងកិច្ចសហប្រតិបត្តិការក្នុងការធ្វើពិសោធន៍DUS**

៣.១ កិច្ចសហប្រតិបត្តិការទាក់ទងនឹងការធ្វើពិសោធន៍DUS មានផលប្រយោជន៍យ៉ាងច្រើនចំពោះប្រព័ន្ធយូប៉ូវ។ អនុសញ្ញាយូប៉ូវ(មាត្រា១២នៃច្បាប់ឆ្នាំ១៩៩១) តម្រូវឱ្យពូជដំណាំមួយត្រូវត្រួតពិនិត្យការបំពេញតាមលក្ខណៈវិនិច្ឆ័យ ភាពខុសប្លែក ឯកសណ្ឋានភាពនិងស្ថេរភាព។ ច្បាប់ឆ្នាំ១៩៩១ បញ្ជាក់ថា "ក្នុងដំណើរការត្រួតពិនិត្យ អាជ្ញាធរ អាចបណ្តុះពូជដំណាំឬធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀត ឱ្យគេបណ្តុះពូជដំណាំឬឱ្យគេធ្វើពិសោធន៍ចាំបាច់ផ្សេងៗទៀតឬពិចារណាលើលទ្ធផលនៃការពិសោធន៍ការបណ្តុះ ឬការសាកល្បងផ្សេងទៀតដែលបានធ្វើរួចហើយ"។ ការតាក់តែងឃ្លានេះបង្ហាញថា អាជ្ញាធរនៃសមាជិកសហភាព ជាឧទាហរណ៍ អាចប្រើប្រាស់ការរៀបចំណាមួយដូចខាងក្រោម:

(ក) អាជ្ញាធរធ្វើការបណ្តុះសាកល្បង ឬ ធ្វើពិសោធន៍ផ្សេងទៀតដោយខ្លួនឯង

(ខ) អាជ្ញាធរ រៀបចំឱ្យភាគីណាមួយផ្សេងទៀត/ភាគីច្រើនផ្សេងទៀត ធ្វើការបណ្តុះសាកល្បង ឬធ្វើពិសោធន៍ផ្សេងទៀត

ក្នុងការរៀបចំនេះ ភាគីណាមួយផ្សេងទៀត អាចរួមមាន ដូចជា អាជ្ញាធរណាមួយផ្សេងទៀត ស្ថាប័នឯករាជ្យ ឬអ្នកបង្កាត់ពូជដំណាំ។

(គ) អាជ្ញាធរត្រូវពិចារណាលើលទ្ធផលនៃការបណ្តុះសាកល្បង ពិសោធន៍ផ្សេងទៀត ដែលបានធ្វើរួចហើយ។

លទ្ធភាពនេះអនុញ្ញាតឱ្យសមាជិកនៃសហភាព ទទួលយករបាយការណ៍DUS ស្តីពីពូជដំណាំដែលបានត្រួតពិនិត្យរួចហើយដោយសមាជិកណាមួយផ្សេងទៀតនៃសហភាព។ វិធីសាស្ត្រនេះ ជំរុញឱ្យក្លាយជាមធ្យោបាយយ៉ាងសំខាន់ក្នុងការបន្ថយរយៈពេលជាអប្បបរ-មាសម្រាប់ការត្រួតពិនិត្យDUS និងបន្ថយជាអប្បបរមាចំណាយនៃត្រួតពិនិត្យDUSដោយកាត់បន្ថយការជាន់គ្នា។

៣.២ ដើម្បីសម្រួលកិច្ចសហប្រតិបត្តិការក្នុងការធ្វើពិសោធន៍DUS ដែលត្រូវចាត់ទុកថាត្រឹមត្រូវដោយសមាជិកទាំងឡាយនៃសហភាព យូប៉ូវបានបង្កើតឯកសារ TGP/5 “បទពិសោធន៍ និងកិច្ចសហប្រតិបត្តិការក្នុងការធ្វើពិសោធន៍DUS”) ដែលមានផ្នែកនានាដូចខាងក្រោម:

| | |
|---|---|
| សេចក្តីផ្តើម | សេចក្តីផ្តើម |
| ផ្នែកទី១ | កិច្ចព្រមព្រៀងរដ្ឋបាលគំរូចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការធ្វើពិសោធន៍ពូជដំណាំ |
| ផ្នែកទី ២ | ទម្រង់គំរូយូប៉ូវ សម្រាប់ពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ |
| ផ្នែកទី ៣ | បញ្ជីសំនួរបច្ចេកទេសដែលត្រូវបំពេញទាក់ទងនឹងពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំ |
| ផ្នែកទី ៤ | ទម្រង់គំរូយូប៉ូវ សម្រាប់កំណត់គំរូពូជដំណាំ |
| ផ្នែកទី ៥ | សំណើយូប៉ូវ សុំឱ្យត្រួតពិនិត្យលទ្ធផល និង<br>ចម្លើយយូប៉ូវ ចំពោះសំណើសុំឱ្យត្រួតពិនិត្យលទ្ធផល |
| ផ្នែកទី ៦ | របាយការណ៍យូប៉ូវ ស្តីពីការត្រួតពិនិត្យបច្ចេកទេស និង<br>សេចក្តីអធិប្បាយពូជដំណាំយូប៉ូវ |
| ផ្នែកទី ៧ | របាយការណ៍បណ្តោះអាសន្នរបស់យូប៉ូវ ស្តីពីការត្រួតពិនិត្យបច្ចេកទេស |
| ផ្នែកទី ៨ | កិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យ |
| ផ្នែកទី ៩ | បញ្ជីនៃប្រភេទពូជនានាដែលបានទទួលពីចំណេះដឹងនៃការអនុវត្តន៍ ឬដែលត្រូវបង្កើតឡើងសម្រាប់មគ្គុទ្ទេសក៍នៃការធ្វើពិសោធន៍ជាតិ |
| ផ្នែកទី ១០ | សេចក្តីជូនដំណឹងនៃចរិតលក្ខណៈបន្ថែម |
| ផ្នែកទី ១១ | ឧទាហរណ៍នៃគោលនយោបាយ និងកិច្ចសន្យាស្តីពីបំណែកពូជដែលអ្នកបង្កាត់ពូជដំណាំបានបញ្ជូនមក |

៣.៣ ផ្នែកទី ១ “កិច្ចព្រមព្រៀងរដ្ឋបាលគំរូចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការធ្វើពិសោធន៍ពូជដំណាំ”ផ្តល់កិច្ចព្រមព្រៀងគំរូចំពោះកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរនានា។

៣.៤ កិច្ចព្រមព្រៀងរដ្ឋបាលផ្អែកលើកិច្ចព្រមព្រៀងរដ្ឋបាលគំរូ មិនមែនជាបុរេលក្ខខណ្ឌចំពោះគ្រប់ទិដ្ឋភាពនៃកិច្ចសហប្រតិបត្តិការ ហើយ ជាពិសេស ការប្រើប្រាស់ដោយសមាជិកទាំងឡាយនៃសហភាពនូវរបាយការណ៍DUS ដែលមានស្រាប់ដែលផ្តល់ឱ្យដោយអាជ្ញាធរនានារបស់សមាជិកផ្សេងទៀតនៃសហភាព មិនតម្រូវជាចាំបាច់ឱ្យប្រើប្រាស់កិច្ចព្រមព្រៀងនេះឡើយ។ ប៉ុន្តែក្នុងករណីដែលកិច្ចព្រមព្រៀងនេះមិនបានធ្វើ សមាជិកនៃសហភាពដែលស្នើសុំរបាយការណ៍DUS ត្រូវជំរុញឱ្យប្រើប្រាស់ទម្រង់គំរូក្នុងផ្នែកទី៥ “សំណើ

របស់យូប៉ូវ សុំឱ្យត្រួតពិនិត្យលទ្ធផល និងចំលើយរបស់យូប៉ូវ ចំពោះសំណើសុំត្រួតពិនិត្យលទ្ធផល”។

## កំណត់ពន្យល់ចំពោះមាត្រា១៣ កិច្ចការពារបណ្តោះអាសន្ន

ភាគីហត្ថលេខីនីមួយៗ ត្រូវចាត់វិធានការដើម្បីរក្សាប្រយោជន៍របស់អ្នកបង្កាត់ពូជដំណាំក្នុងចន្លោះពេលដាក់ពាក្យស្នើសុំឬពេលបោះពុម្ពផ្សាយពាក្យស្នើសុំសិទ្ធិអ្នកបង្កាត់ពូជដំណាំនិងការផ្តល់សិទ្ធិ។វិធានការទាំងនេះត្រូវមានអានុភាពផ្តល់ឱ្យម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំយ៉ាងហោចណាស់សិទ្ធិទទួលបានលាភការសមរម្យ ក្នុងរយៈពេលខាងលើ ពីបុគ្គលណាដែលបានធ្វើសកម្មភាពពេលដែលបានផ្តល់សិទ្ធិ ហើយដែលត្រូវការការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ ដូចមានចែងក្នុងមាត្រា១៤។ ភាគីហត្ថលេខីអាចចែងថាវិធានការខាងលើមានអានុភាពតែក្នុងទំនាក់ទំនងជាមួយបុគ្គលដែលអ្នកបង្កាត់ពូជដំណាំ បានជូនដំណឹងអំពីការដាក់ពាក្យស្នើសុំ។

### រយៈពេល

១.២ អនុសញ្ញាយូប៉ូវ ចែងថា រយៈពេលការពារ(មាត្រា១៩នៃច្បាប់ឆ្នាំ១៩៩១ និងមាត្រា៨នៃច្បាប់ឆ្នាំ១៩៧៨) ត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវតម្រូវថាកិច្ចការពារបណ្តោះអាសន្ន ត្រូវបានផ្តល់ឱ្យអ្នកបង្កាត់ពូជដំណាំក្នុងអំឡុងពេលរវាងការដាក់ពាក្យ ឬ ការបោះពុម្ពផ្សាយពាក្យស្នើសុំផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការផ្តល់សិទ្ធិ។

១.២ សមាជិកនៃសហភាព អាចចែងក្នុងច្បាប់របស់ខ្លួនថា វិធានការនៃកិច្ចការពារបណ្តោះអាសន្ន (សូមមើលកំណត់នានាខាងក្រោមស្តីពី“វិធានការ”) ត្រូវមានអានុភាពអនុវត្តតែចំពោះបុគ្គលដែលអ្នកបង្កាត់ពូជដំណាំបានជូនដំណឹងពីការដាក់ពាក្យស្នើសុំ។ ការជូនដំណឹងនេះ អាចចាត់ទុកថាត្រូវបានបំពេញចំពោះបុគ្គលទាំងអស់ នៅពេលដែលច្បាប់រក្សាកាលបរិច្ឆេទនៃកាលបោះពុម្ពផ្សាយ ជាកាលបរិច្ឆេទដំបូង ចំពោះកិច្ចការពាកបណ្តោះអាសន្ន ពីព្រោះការបោះពុម្ពផ្សាយជាទូទៅ ត្រូវបានទទួលស្គាល់ថាជាយន្តការនៃការជូនដំណឹងទៅភាគីទីបី។

### វិធានការនានា

២.១ មាត្រា១៣ ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ចែងថា សមាជិកយូប៉ូវ ដែលចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៩១ ត្រូវចែងពីវិធានការដែលកំណត់ ដើម្បីការពារផលប្រយោជន៍អ្នកបង្កាត់ពូជដំណាំក្នុងអំឡុងពេលរវាងការដាក់ពាក្យឬការបោះពុម្ពផ្សាយពាក្យស្នើសុំ និងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។ វិធានការទាំងនេះ តម្រូវឱ្យម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

“យ៉ាងហោចណាស់” មានសិទ្ធិទទួលបានលាភការសមធម៌ពីបុគ្គលណាមួយ ក្នុងអំឡុងពេលនោះ ដែលបានអនុវត្តសកម្មភាព ដែលតម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជ

ដំណាំដូចមានចែងក្នុងមាត្រា១៤ ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ នៅពេលដែលសិទ្ធិត្រូវបានផ្តល់ឱ្យ។

២.២ អត្ថបទដែលប្រើពាក្យ “យ៉ាងហោចណាស់” បញ្ជាក់ជាអាទិ៍ថា បទប្បញ្ញត្តិស្តីពីកិច្ចការពារបណ្តោះអាសន្ន ក្នុងច្បាប់ដែលគ្រប់គ្រងសិទ្ធិអ្នកបង្កាត់ពូជដំណាំ អាចចែងឱ្យម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំមានសិទ្ធិ ជាអ្នកបង្កាត់ពូជដំណាំពេញលេញ។

២.៣ កិច្ចការពារបណ្តោះអាសន្ន មានសុពលភាពតែចំពោះសកម្មភាពដែលតម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ "នៅពេលសិទ្ធិត្រូវបានផ្តល់ឱ្យ" ឧទាហរណ៍ ប្រសិនបើសិទ្ធិមិនត្រូវបានផ្តល់ឱ្យ កិច្ចការពារបណ្តោះអាសន្ន មិនអាចអនុវត្តបានឡើយ។

២.៤ បទប្បញ្ញត្តិជាឧទាហរណ៍ដូចខាងក្រោមមានគោលដៅផ្តល់ជំនួយដល់រដ្ឋ/អង្គការអន្តររដ្ឋាភិបាល ដែលចង់ព្រាងបទប្បញ្ញត្តិស្តីពីកិច្ចការពារបណ្តោះអាសន្នក្នុងច្បាប់របស់ខ្លួនឱ្យស្របនឹងច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ:

### មាត្រា[១៣][៩]

### កិច្ចការពារបណ្តោះអាសន្ន

[(១)]កិច្ចការពារបណ្តោះអាសន្នត្រូវបានផ្តល់ឱ្យដើម្បីការពារផលប្រយោជន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំក្នុងអំឡុងពេលរវាង [ការដាក់ពាក្យ] / [ការបោះពុម្ពផ្សាយ]នៃពាក្យស្នើសុំផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការផ្តល់សិទ្ធិនេះ។

----------------------

ឧទាហរណ៍ ក

[(២)] ម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំ [ត្រូវយ៉ាងហោចណាស់មានសិទ្ធិទទួលបានលាភការសមធម៌] ពីបុគ្គលណាមួយ ក្នុងអំឡុងពេលដូចមានចែងក្នុងកថាខណ្ឌ១ដែលអនុ-

[៩] អត្ថបទដែលមានគូសពិណក្នុងដង្កៀប ត្រូវបានបង្កើតឡើងសម្រាប់អ្នកព្រាងក្នុងការរៀបចំច្បាប់និងរក អត្ថបទដែលត្រូវបំពេញ តាមការចាំបាច់ ដោយបង់លេខតាមបទប្បញ្ញត្តិនានាដែលអាចត្រូវផ្លាស់ប្តូរ ឬកំណត់អត្តសញ្ញាណបទប្បញ្ញត្តិនានានៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ដែលចែងអំពីជម្រើស។

វត្តសកម្មភាពដែលតម្រូវឱ្យមានការយល់ព្រមពីអ្នកបង្កាត់ពូជដំណាំ ដូចមានចែងក្នុងមាត្រា [១៤] នៅពេលសិទ្ធិត្រូវបានផ្តល់ឱ្យ។

ឧទាហរណ៍ ខ

[(២)] អ្នកដាក់ពាក្យស្នើសុំ ត្រូវចាត់ទុកជាម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំទាក់ទងនឹងបុគ្គលណាមួយ ក្នុងអំឡុងពេលដូចមានចែងក្នុងកថាខណ្ឌទី[(១)] ដែលបានអនុវត្តសកម្មភាពដែលតម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ ដូចមានចែងក្នុងមាត្រា[(១៤)] នៅពេលសិទ្ធិត្រូវបានផ្តល់ឱ្យ។ អាចផ្តួចផ្តើមបណ្តឹងផ្លូវច្បាប់ ចំពោះកិច្ចការពារបណ្តោះអាសន្ន តែបន្ទាប់ពីសិទ្ធិត្រូវបានផ្តល់ឱ្យ។

------------------------

[(៣)] [កិច្ចការពារបណ្តោះអាសន្ន ត្រូវមានអានុភាពអនុវត្តតែចំពោះបុគ្គលដែលអ្នកបង្កាត់ពូជដំណាំបានជូនដំណឹងពីការដាក់ពាក្យស្នើសុំតែប៉ុណ្ណោះ]។

កថាខណ្ឌទី(៣) នៃបទប្បញ្ញត្តិជាឧទាហរណ៍ខាងលើ មិនចាំបាច់ឡើយ ក្នុងកថាខណ្ឌទី(១) ប្រសិនបើច្បាប់បានរក្សាកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយជាកាលបរិច្ឆេទដំបូងចំពោះកិច្ចការពារបណ្តោះអាសន្ន( សូមមើលកំណត់១.២ ខាងលើ ស្តីពី“រយៈពេល”)។

## កំណត់ពន្យល់ចំពោះមាត្រា១៤ វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

## មាត្រា១៤(១)

(១) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាន] (ក)លើកលែងតែមាត្រា១៥និងមាត្រា១៦ សកម្មភាពខាងក្រោមទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ ត្រូវមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ:

(i) ការផលិតឬការផលិតឡើងវិញ(ចំនួនច្រើន)

(ii) ការដាក់លក្ខខណ្ឌក្នុងគោលបំណងនៃការដាំដុះ

(iii) ការដាក់លក់

(iv) ការលក់ឬចរាចរផ្សេងទៀត

(v) ការនាំចេញ

(vi) ការនាំចូល

(vii) ការស្តុកទុកសម្រាប់គោលបំណងណាមួយដូចមានចែងក្នុងចំនុច(i) ដល់ (vi) ខាងលើ។

(ខ)អ្នកបង្កាត់ពូជដំណាំអាចផ្តល់ការអនុញ្ញាត ដោយភ្ជាប់នូវលក្ខខណ្ឌនិងការកម្រិតសិទ្ធិ។

១. អនុសញ្ញាយូប៉ូវបង្កើតសិទ្ធិឱ្យអ្នកបង្កាត់ពូជដំណាំដើម្បីអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌនិងការកម្រិតសិទ្ធិ ចំពោះសកម្មភាពទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាន។ លក្ខខណ្ឌនិងការកម្រិតសិទ្ធិដែលអ្នកបង្កាត់ពូជអាចអនុញ្ញាតចំពោះសកម្មភាពទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាន ជាបញ្ហាដែលអ្នកបង្កាត់ពូជដំណាំត្រូវសម្រេចចិត្ត។

២.សម្រាប់គោលបំណងនៃការបកស្រាយ ឧទាហរណ៍នៃលក្ខខណ្ឌនិងការកម្រិតសិទ្ធិដែលអ្នកបង្កាត់ពូជដំណាំអាចបញ្ចូល:

(i) លាភការ-កម្រិតនៃលាភការ (ដូចជា ភ្ជាប់ទៅនឹងបរិមាណបំណែកពូជដែលអាចយកទៅដាំដុះបាន តំបន់ដែលបណ្តុះបំណែកពូជដែលអាចយកទៅដាំដុះបាន ចំនួនឬតម្លៃនៃបំណែកពូជដែលបានផលិតពីបណែកពូជដែលអាចយកទៅដាំដុះបាន ។ល។) រយៈពេលនិងរបៀបបង់ប្រាក់។ល។

(ii) រយៈពេលអនុញ្ញាត

(iii) វិធីដែលអាចអនុវត្តចំពោះសកម្មភាពដែលទទួលបានការអនុញ្ញាត (ដូចជាវិធីផលិតឬផលិតឡើងវិញ ផ្លូវនាំចេញ ។ល។)

(iv) គុណភាពនិងបរិមាណបំណែកពូជដែលត្រូវផលិត

(v) ដែនដីដែលអនុញ្ញាតឱ្យនាំចេញ

(vi) លក្ខខណ្ឌ ដែលបុគ្គលទទួលបានការអនុញ្ញាតអាចផ្តល់អាជ្ញាប័ណ្ណ/អាជ្ញាប័ណ្ណបន្តទៅភាគីផ្សេងទៀត ដើម្បីធ្វើសកម្មភាពដែលទទួលបានការអនុញ្ញាក្នុងនាមខ្លួន។ល។

**មាត្រា១៤(២)**

(២) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន ] លើកលែងតែមាត្រា១៥ និងមាត្រា១៦ សកម្មភាពដូចមានចែងក្នុងចំនុច(i)ដល់(vii)នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូលនិងផ្នែកនៃដំណាំដែលទទួលបានតាមរយៈការប្រើប្រាស់ ដោយគ្មានការអនុញ្ញាតនៃបំណែកពូជដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបានខាងលើ។

**មាត្រា១៤(៣)និង(៤) [បទប្បញ្ញត្តិជាជម្រើស]**

(៣) [សកម្មភាពទាក់ទងនឹងផលិតផលមួយចំនួន] លើកលែងតែមាត្រា១៥ និងមាត្រា១៦ ភាគីហត្ថលេខីនីមួយៗ អាចចែងថា សកម្មភាពដូចមានចែងក្នុងចំនុច (i)ដល់(vii)នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងផលិតផលដែលបង្កើតឡើងដោយផ្ទាល់ពីបំណែកពូជដែលប្រមូលផលបាននៃពូជដំណាំដែលបានការពារ ក្នុងបទប្បញ្ញត្តិនៃកថាខណ្ឌទី(២) តាមរយៈការប្រើប្រាស់ដោយគ្មានការអនុញ្ញាត នៃបំណែកពូជដែលប្រមូលផលបាននេះ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន ទាក់ទងនឹងបំណែកពូជ ដែលប្រមូលផលបាននេះ។

(៤) [សកម្មភាពបន្ថែមដែលអាចមាន] លើកលែងតែមាត្រា១៥ និងមាត្រា១៦ ភាគីហត្ថលេខីនីមួយៗ អាចចែងពីសកម្មភាពផ្សេងក្រៅពីសកម្មភាពដែលមានចែងក្នុងចំនុច(i) ដល់ (vii) នៃកថាខណ្ឌទី(១)(ក) ក៏តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំផងដែរ។

## កំណត់ពន្យល់ចំពោះ "ពូជដំណាំដែលមានស្រឡាយសំខាន់"
## មាត្រា១៤(៥)

### ជំពូកទី ១ : បទប្បញ្ញត្តិនៃពូជដំណាំដែលមានស្រឡាយសំខាន់

(ក) បទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ

### សិទ្ធិអ្នកបង្កាត់ពូជដំណាំ
### មាត្រា១៤
### វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

[…]

(៥) [ ពូជដំណាំដែលមានស្រឡាយសំខាន់ និងពូជដំណាំផ្សេងទៀតមួយចំនួន] (ក) បទប្បញ្ញត្តិនៃកថាខណ្ឌទី(១ដល់ទី(៤)* ត្រូវអនុវត្តផងដែរទាក់ទងនឹង:

---

* បទប្បញ្ញត្តិក្នុងមាត្រា១៤(១)ដល់(៤) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ:

(១) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាន] (ក)លើកលែងតែមាត្រា១៥និងមាត្រា១៦ សកម្មភាពខាងក្រោមទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ ត្រូវមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ:

(i) ការផលិតឬការផលិតឡើងវិញ(ចំនួនច្រើន)

(ii) ការដាក់លក្ខខណ្ឌក្នុងគោលបំណងនៃការដាំដុះ

(iii) ការដាក់លក់

(iv) ការលក់ឬចរាចរផ្សេងទៀត

(v) ការនាំចេញ

(vi) ការនាំចូល

(vii) ការស្តុកទុកសម្រាប់គោលបំណងណាមួយដូចមានចែងក្នុងចំនុច (i) ដល់ (vi) ខាងលើ។

(ខ) អ្នកបង្កាត់ពូជដំណាំអាចផ្តល់ការអនុញ្ញាត ដោយភ្ជាប់នូវលក្ខខណ្ឌនិងការកម្រិតសិទ្ធិ។

(២) [ សកម្មភាពទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន ] លើកលែងតែមាត្រា១៥ និងមាត្រា១៦ សកម្មភាពដូចមានចែងក្នុងចំនុច(i)ដល់(vii)នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូលនិងផ្នែកនៃដំណាំ ដែលទទួលបានតាមរយៈការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនៃបំណែកពូជដែលអាចយកទៅដាំដុះបាននៃពូជដំណាំដែលបានការពារ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលអាចយកទៅដាំដុះបានខាងលើ។

(៣) [សកម្មភាពទាក់ទងនឹងផលិតផលមួយចំនួន] លើកលែងតែមាត្រា១៥ និងមាត្រា១៦ ភាគីហត្ថលេខីនីមួយៗអាចចែងថា សកម្មភាពដូចមានចែងក្នុងចំនុច(i)ដល់(vii)នៃកថាខណ្ឌទី(១)(ក) ទាក់ទងនឹងផលិតផលដែលបង្កើតឡើងដោយផ្ទាល់ពីបំណែកពូជដែលប្រមូលផលបាននៃពូជដំណាំដែលបានការពារក្នុងបទប្បញ្ញត្តិនៃកថាខណ្ឌទី(២) តាមរយៈការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនៃបំណែកពូជដែលប្រមូលផលបាននេះ តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់

*Continued on next page*

(i) ពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំដែលបានការពារ នៅពេលដែលពូជដំណាំដែលបានការពារ មិនមែនជាពូជដំណាំដែលមានស្រឡាយសំខាន់នោះទេ

[...]

ខ) សម្រាប់គោលបំណងនៃអនុកថាខណ្ឌ(ក)(i) ពូជដំណាំត្រូវចាត់ទុកថាមានស្រឡាយសំខាន់ពីពូជដំណាំមួយផ្សេងទៀត ("ពូជដំណាំដើម") នៅពេលដែលៈ

(i) ពូជដំណាំដែលមានស្រឡាយលើសលុបពីពូជដំណាំដើម ឬពីពូជដំណាំមួយដែលវាជាស្រឡាយលើសលុបពីពូជដំណាំដើម តែនៅរក្សាការបង្ហាញចរិតលក្ខណៈសំខាន់ជាលទ្ធផលនៃគំរូហ្សែនឬបន្សំគំរូហ្សែននៃពូជដំណាំដើម

(ii) ពូជដំណាំអាចញែកដាច់ពីគ្នាស្រឡះពីពូជដំណាំដើម និង

(iii) លើកលែងតែភាពខុសគ្នាដែលកើតពីអំពើនៃការបំប្លែង ពូជដំណាំដូចនឹងពូជដំណាំដើម ក្នុងការបង្ហាញចរិតលក្ខណៈសំខាន់ ជាលទ្ធផលនៃគំរូហ្សែន ឬបន្សំគំរូហ្សែននៃពូជដំណាំដើម។

(គ) ពូជបំលែងសំខាន់ៗដែលអាចទទួលបាន ដូចជា តាមការជ្រើសរើសដោយធម្មជាតិឬដោយការបំបែកកោសិកា ឬដោយបំរែបំរួលហ្សែន ការជ្រើសរើសពូជបំរែបំរួលមួយៗចេញពីពូជដំណាំដែលគេបង្កើតឡើង ត្រូវធ្វើតាមរយៈការបង្កាត់ត្រឡប់ឬការបំប្លែងតាមរយៈវិស្វកម្មហ្សែន។

(ខ) ការកំណត់ពូជដំណាំដែលមានស្រឡាយសំខាន់

១. អនុសញ្ញាមិនបានបញ្ជាក់ឱ្យច្បាស់ពីពាក្យ ដូចជា "ដែលមានស្រឡាយលើសលុប" ឬ "ចរិតលក្ខណៈសំខាន់"នោះទេ។ ប៉ុន្តែអនុសញ្ញាផ្តល់ឧទាហរណ៍មួយចំនួននៃវិធីដែលអាចទទួលបានពូជដំណាំដែលមានស្រឡាយសំខាន់(មាត្រា១៤(៥)(គ): "ពូជដំណាំដែលមាន

---

ពូជដំណាំ លើកលែងតែអ្នកបង្កាត់ពូជដំណាំមានឱកាសសមរម្យ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនទាក់ទងនឹងបំណែកពូជដែលប្រមូលផលបាននេះ។

(៥) [សកម្មភាពបន្ថែមដែលអាចមាន] លើកលែងតែមាត្រា១៥ និងមាត្រា១៦ ភាគីហត្ថលេខីនីមួយៗអាចចែងពីសកម្មភាពផ្សេងក្រៅពីសកម្មភាពដែលមានចែង ក្នុងចំនុច (i) ដល់ (vii) នៃកថាខណ្ឌទី(១)(ក) ក៏តម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំផងដែរ។

ស្រឡាយសំខាន់ដែលអាចទទួលបាន ដូចជា តាមការជ្រើសរើសដោយធម្មជាតិឬដោយការបំបែកកោសិកា ឬដោយបំរែបំរួលហ្សែន ការជ្រើសរើសពូជបំរែបំរួលមួយៗ ចេញពីពូជដំណាំដែលគេបង្កើតឡើង ត្រូវធ្វើតាមរយៈការបង្កាត់ត្រឡប់ឬការបំប្លែងតាមរយៈវិស្វកម្មហ្សែន។

២. ការប្រើប្រាស់ពាក្យ “អាច” ក្នុងមាត្រា ១៤(៥)(គ) បង្ហាញថា វិធីទាំងនេះ អាចមិនចាំបាច់នាំឱ្យមានពូជដំណាំដែលមានស្រឡាយសំខាន់។ ជាងនេះទៅទៀត អនុសញ្ញាបញ្ជាក់ថា ទាំងនេះជាឧទាហរណ៍ និងមិនបដិសេធន៍លទ្ធភាពនៃពូជដំណាំដែលមានស្រឡាយសំខាន់ ទទួលបានតាមវិធីផ្សេងទៀតនោះឡើយ។

៣. ពូជដំណាំដែលមានស្រឡាយសំខាន់ ត្រូវបានទទួល ទោះដោយផ្ទាល់ ឬដោយប្រយោលពីពូជដំណាំមួយដែលត្រូវហៅថា “ពូជដំណាំដើម”ក្តី។ ឧទាហរណ៍ក្នុងរូបទី១ ពូជដំណាំ **ខ** ជាពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំ **ក** និងដែលមានស្រឡាយលើសលុបពីពូជដំណាំ **ក**។ ពូជដំណាំដែលមានស្រឡាយសំខាន់ អាចទទួលបានដោយប្រយោលផងដែរពីពូជដំណាំដើម។ ឧទាហរណ៍ក្នុងរូបទី២ ពូជដំណាំ **គ** មានស្រឡាយសំខាន់ពីពូជដំណាំដើម ‘**ក**’ ប៉ុន្តែ មានស្រឡាយលើសលុបពីពូជដំណាំ **ខ** ។

៤. ដោយមិនគិតថាតើ ពូជដំណាំ **គ** ត្រូវទទួលបានឬមិនទទួលបានដោយផ្ទាល់ពីពូជដំណាំ **ក** ពូជដំណាំនេះ ជាពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំ **ក** ប្រសិនបើពូជដំណាំនេះ បានបំពេញនិយមន័យដែលចែងក្នុងមាត្រា១៤(៥)(ខ)។

៥. ឧទាហរណ៍មួយផ្សេងទៀតនៃវិធីមិនផ្ទាល់ ដែលអាចទទួលបានពូជណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំដើម អាចត្រូវបានប្រើប្រាស់ពូជបង្កាត់ទំនើបដើម្បីទទួលបានពូជដំណាំមួយដែលមានស្រឡាយសំខាន់ពីខ្សែមេបាណាមួយនៃពូជបង្កាត់ទំនើប។

៦. ទំនាក់ទំនងរវាង ពូជដំណាំដើម(ពូជដំណាំ **ក**) និងពូជដំណាំដែលមានស្រឡាយសំខាន់ (ពូជដំណាំ **ខ** និង **គ**) គឺមិនគិតថាតើសិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវបានផ្តល់ឱ្យពូជដំណាំ **ក** **ខ** ឬ **គ** ឡើយ។ ពូជដំណាំ **ក** នឹងនៅតែជាពូជដំណាំដើម ចំពោះពូជដំណាំ **ខ** និង **គ** ហើយពូជដំណាំ**ខ**និង**គ** នឹងនៅតែជាពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំ**ក**ដដែល។ ប៉ុន្តែ ប្រសិនពូជដំណាំដើម ត្រូវបានការពារ នោះនឹងធ្វើឱ្យមានវិបាកមួយចំនួនទាក់ទងនឹងពូជដំណាំដែលមានស្រឡាយសំខាន់ **ខ** និង **គ** (សូមមើល ផ្នែក(គ))។

រូបទី ១ : ពូជដំណាំ **ក** មិនមែនជាពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំណាមួយផ្សេងទៀត

**ពូជដំណាំដើម 'ក'**

*បង្កាត់ដោយអ្នកបង្កាត់ពូជដំណាំទី១*

-មិនមែនមានស្រឡាយសំខាន់ពីពូជដំណាំណាមួយផ្សេងទៀត

↓

**ពូជដំណាំដែលមានស្រឡាយសំខាន់ 'ខ'**

*បង្កាត់ដោយអ្នកបង្កាត់ពូជដំណាំទី២*

-ជាស្រឡាយលើសលុបពី'**ក**'

-រក្សាការបង្ហាញចរិតលក្ខណៈសំខាន់នៃ'**ក**'

-ខុសគ្នាស្រឡះពី'**ក**'

- ដូច '**ក**' ក្នុងចរិតលក្ខណៈពិសេស

(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង)

រូបទី២: ពូជដំណាំដែលមានស្រឡាយសំខាន់ '**គ**' ដែលមានស្រឡាយលើសលុបពីពូជដំណាំដែលមានស្រឡាយសំខាន់ '**ខ**'

**ពូជដំណាំដើម 'ក'**

*បង្កាត់ដោយអ្នកបង្កាត់ពូជដំណាំទី១*

-មិនមានស្រឡាយសំខាន់ពីពូជដំណាំណាមួយផ្សេងទៀត

⇩

**ពូជដំណាំដែលមានស្រឡាយសំខាន់ 'ខ'**

បង្កាត់ដោយអ្នកបង្កាត់ពូជដំណាំទី២

- មានស្រឡាយលើសលុបពី '**ក**'
- រក្សាការបង្ហាញចរិតលក្ខណៈពិសេសនៃ '**ក**'
- ខុសគ្នាស្រឡះពី '**ក**'
- ដូច '**ក**' ក្នុងចរិតលក្ខណៈសំខាន់ៗ

(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង

⇩

**ពូជដំណាំដែលមានស្រឡាយសំខាន់ 'គ'**

បង្កាត់ដោយអ្នកបង្កាត់ពូជដំណាំទី៣

- មានស្រឡាយលើសលុបពី '**ខ**'
- រក្សាការបង្ហាញចរិតលក្ខណៈពិសេសនៃ '**ក**'
- ខុសគ្នាស្រឡះពី '**ក**'
- ដូច '**ក**' ក្នុងចរិតលក្ខណៈសំខាន់ៗ

(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង)

(គ) វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំចំពោះពូជដំណាំដើមនិងពូជដំណាំដែលមានស្រឡាយសំខាន់

**មាត្រា១៤(៥)(ក)(i)**

(៥) [ ពូជដំណាំដែលមានស្រឡាយសំខាន់ និងពូជដំណាំផ្សេងទៀតមួយចំនួន] (ក) បទប្បញ្ញត្តិនៃកថាខណ្ឌទី(១) ដល់ទី(៤) ត្រូវអនុវត្តផងដែរទាក់ទងនឹង:

(i) ពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំដែលបានការពារ នៅពេលដែលពូជដំណាំដែលបានការពារ មិនមែនជាពូជដំណាំដែលមានស្រឡាយសំខាន់នោះទេ

៧. ពូជដំណាំដែលមានស្រឡាយសំខាន់អាចទទួលបានសិទ្ធិអ្នកបង្កាត់ពូជដំណាំក្នុងវិធីដូចគ្នានឹងពូជដំណាំណាមួយ ប្រសិនបើពូជដំណាំទាំងនេះបំពេញលក្ខខណ្ឌដែលបានកំណត់ក្នុងអនុសញ្ញានេះ(សូមមើលមាត្រា៥ ច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាយូប៉ូវ)។ ប្រសិនបើពូជដំណាំដែលមានស្រឡាយសំខាន់ ត្រូវបានការពារ ចាំបាច់ត្រូវមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំដែលមានស្រឡាយសំខាន់ដូចមានចែងក្នុងមាត្រា១៤(១)នៃអនុសញ្ញាយូប៉ូវ។ ប៉ុន្តែ បទប្បញ្ញត្តិនៃមាត្រា១៤(៥)(ក)(i) ពង្រីកវិសាលភាពសិទ្ធិដែលបានកំណត់ក្នុងមាត្រា១៤(១)ដល់(៤)នៃពូជដំណាំដើមដែលបានការពារ ទៅដល់ពូជដំណាំដែលមានស្រឡាយសំខាន់។ ដូច្នេះ ប្រសិនបើពូជដំណាំ **ក** ជាពូជដំណាំដើមដែលបានការពារ អំពើនានាក្នុងមាត្រា១៤(១)ដល់(៤)ពាក់ព័ន្ធនឹងពូជដំណាំដែលមានស្រឡាយសំខាន់ ទាមទារឱ្យមានការអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំ **ក**។ ក្នុងឯកសារនេះ ពាក្យ "ការធ្វើពាណិជ្ជកម្ម" ត្រូវបានប្រើប្រាស់គ្របដណ្តប់លើអំពើនានាក្នុងមាត្រា១៤(១)ដល់(៤)។ ដូច្នេះ នៅពេលដែលបានទទួលសិទ្ធិអ្នកបង្កាត់ពូជដំណាំ ទាំងលើពូជដំណាំដើម(ពូជដំណាំ**ក**) និងពូជដំណាំដែលមានស្រឡាយសំខាន់(ពូជដំណាំ**ខ**) ទាមទារឱ្យមានការអនុញ្ញាត ទាំងពីអ្នកបង្កាត់ពូជដំណាំដើម(ពូជដំណាំ **ក**)និងអ្នកបង្កាត់ពូជដំណាំដែលមានស្រឡាយសំខាន់(ពូជដំណាំ**ខ**) ចំពោះការធ្វើពាណិជ្ជកម្មពូជដំណាំដែលមានស្រឡាយសំខាន់(ពូជដំណាំ **ខ**)។

៨. នៅពេលលែងមានសិទ្ធិអ្នកបង្កាត់ពូជដំណាំលើពូជដំណាំដើម(ពូជដំណាំ**ក**) លែងទាមទារឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំដើម ចំពោះការធ្វើពាណិជ្ជកម្មពូជដំណាំ **ខ**។ ក្នុងស្ថានភាពនេះ ហើយប្រសិនបើសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលមានស្រឡាយសំខាន់នៅតែមានសុពលភាព ត្រូវទាមទារឱ្យមានការអនុញ្ញាតតែពីអ្នកបង្កាត់ពូជដំណាំដែលមាន

ស្រទ្បាយសំខាន់ប៉ុណ្ណោះចំពោះការធ្វើអាជីវកម្មពូជដំណាំ**ខ**។ ជាងនេះទៅទៀត ប្រសិនបើពូជដំណាំដើម មិនដែលត្រូវបានការពារ ត្រូវទាមទារឱ្យមានការអនុញ្ញាតតែពីអ្នកបង្កាត់ពូជដំណាំដែលមានស្រទ្បាយសំខាន់តែប៉ុណ្ណោះ ចំពោះការធ្វើពាណិជ្ជកម្មពូជដំណាំ**ខ** ។

**សង្ខេប**

៩. រូបទី៣និងទី៤ សង្ខេបអំពីស្ថានភាពដែលបានបកស្រាយខាងលើ។ ចាំបាច់ត្រូវកត់សម្គាល់ថា វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវពង្រីកតែចំពោះពូជដំណាំដែលមានស្រទ្បាយសំខាន់ដែលទាក់ទងនឹងពូជដំណាំដើមដែលត្រូវបានការពារតែប៉ុណ្ណោះ។ ក្នុងទិដ្ឋភាពនេះ គួរកត់សម្គាល់ផងដែរថា ពូជដំណាំដែលមានស្រទ្បាយសំខាន់ពីពូជដំណាំណាមួយផ្សេងទៀត មិនអាចជាពូជដំណាំដើមបានទេ(សូមមើលមាត្រា១៤(៥)(ក)(**i**))។ ដូច្នេះ ក្នុងរូបទី៣ សិទ្ធិអ្នកបង្កាត់ពូជដំណាំទី១ ពង្រីកចំពោះពូជដំណាំដែលមានស្រទ្បាយសំខាន់**ខ**(**EDV B**) និង ពូជដំណាំដែលមានស្រទ្បាយសំខាន់**គ** (**EDV C**)។ ប៉ុន្តែទោះជាពូជដំណាំដែលមានស្រទ្បាយសំខាន់**គ**(**EDV C**) មានស្រទ្បាយលើសលុបពីពូជដំណាំដែលមានស្រទ្បាយសំខាន់**ខ**(**EDV B**)ក៏ដោយ អ្នកបង្កាត់ពូជដំណាំទី២ គ្មានសិទ្ធិពាក់ព័ន្ធនឹងពូជដំណាំដែលមានស្រទ្បាយសំខាន់**គ**(**EDV C**)ទេ។ ទិដ្ឋភាពសំខាន់មួយទៀតនៃបទប្បញ្ញត្តិស្តីពីស្រទ្បាយសំខាន់គឺថា គ្មានការពង្រីកសិទ្ធិចំពោះពូជដំណាំដែលមានស្រទ្បាយសំខាន់ ប្រសិនបើ ពូជដំណាំដើម មិនត្រូវបានការពារ។ ដូច្នេះ ក្នុងរូបទី៤ ប្រសិនបើពូជដំណាំ **ក** មិនត្រូវបានការពារ ឬប្រសិនបើ **ក** លែងទទួលបានកិច្ចការពារ(ដូចជា ដោយសារផុតកំណត់រយៈពេលការពារ ឬ លុបចោលឬមោឃភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ) ការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំទី១ លែងទាមទារតទៅទៀតដើម្បីអាចធ្វើពាណិជ្ជកម្មពូជដំណាំ **ខ** និង **គ**។

**រូបទី៣: ពូជដំណាំដើមដែលបានការពារ និងពូជដំណាំដែលមានស្រឡាយសំខាន់ (EDV)ដែលបានការពារ**

**ពូជដំណាំដើម ‘ក’**
**(ដែលបានការពារ)**
បង្កាត់និងការពារដោយ**អ្នកបង្កាត់ពូជដំណាំទី១**

↓

**ពូជដំណាំដែលមានស្រឡាយសំខាន់ ‘ខ’**
បង្កាត់និង**ការពារ**ដោយ**អ្នកបង្កាត់ពូជដំណាំទី២**
-មានស្រឡាយលើសលុបពី ‘**ក**’
-រក្សាចរិតលក្ខណៈសំខាន់នៃ ‘**ក**’
- ខុសគ្នាស្រឡះពី ‘**ក**’
- ដូច ‘**ក**’ ក្នុងចរិតលក្ខណៈសំខាន់
(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង

→ ការធ្វើពាណិជ្ជកម្ម*: ទាមទារការអនុញ្ញាតពី **អ្នកបង្កាត់ពូជដំណាំទី១និងទី២**

↓

**ពូជដំណាំដែលមានស្រឡាយសំខាន់ ‘គ’**
បង្កាត់និង**ការពារ**ដោយ**អ្នកបង្កាត់ពូជដំណាំទី៣**
- មានស្រឡាយលើសលុបពី ‘**ក**’ ឬ ‘**ខ**’
- រក្សាការបង្ហាញចរិតលក្ខណៈសំខាន់នៃ ‘**ក**’
-ខុសគ្នាស្រឡះពី ‘**ក**’
- ដូច ‘**ក**’ ក្នុងចរិតលក្ខណៈសំខាន់
(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង)

→ ការធ្វើពាណិជ្ជកម្ម*: ទាមទារការអនុញ្ញាតពី **អ្នកបង្កាត់ពូជដំណាំទី១និងទី៣** (មិនទាមទារការអនុញ្ញាតពីអ្នកបង្កាតពូជដំណាំទី២)

**រូបទី៤: ពូជដំណាំដើម <u>មិនបានការពារ</u> និងពូជដំណាំដែលមានស្រឡាយសំខាន់ ដែលបានការពារ**

**ពូជដំណាំដើម 'ក'**

**(<u>មិន</u>បានការពារ)**

បង្កាត់ដោយ**អ្នកបង្កាត់ពូជដំណាំទី១**

↓

**ពូជដំណាំដែលមានស្រឡាយសំខាន់ ខ**

បង្កាត់និង**ការពារ**ដោយ**អ្នកបង្កាត់ពូជដំណាំទី២**

- មានស្រឡាយលើសលុបពី **'ក'**
- រក្សាការបង្ហាញចរិតលក្ខណៈសំខាន់នៃ **'ក'**
- ខុសគ្នាស្រឡះពី **'ក'**
- ដូច **'ក'** ក្នុងចរិតលក្ខណៈសំខាន់

(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង)

⇒ ការធ្វើពាណិជ្ជកម្ម*: ទាមទារការអនុញ្ញាតពី **អ្នកបង្កាត់ពូជដំណាំទី២** (**<u>មិន</u>**ទាមទារការអនុញ្ញាតពីអ្នកបង្កាតពូជដំណាំទី១)

↓

**ពូជដំណាំដែលមានស្រឡាយសំខាន់ គ**

បង្កាត់និង**ការពារ**ដោយ**អ្នកបង្កាត់ពូជដំណាំទី៣**

- មានស្រឡាយលើសលុបពី **'ក'** ឬ **'ខ'**
- រក្សាការបង្ហាញចរិតលក្ខណៈសំខាន់នៃ **'ក'**
- ខុសគ្នាស្រឡះពី **'ក'**
- ដូច **'ក'** ក្នុងចរិតលក្ខណៈសំខាន់

(លើកលែងតែភាពខុសគ្នាពីអំពើនៃការបំប្លែង)

⇒ ការធ្វើពាណិជ្ជកម្ម*: ទាមទារការអនុញ្ញាតពី **អ្នកបង្កាត់ពូជដំណាំទី៣** (**<u>មិន</u>**ទាមទារការអនុញ្ញាតពីអ្នកបង្កាតពូជដំណាំទី១និងទី២)

---

* "ការធ្វើពាណិជ្ជកម្ម" រួមមានអំពើនានាពាក់ព័ន្ធនឹងពូជដំណាំដែលបានការពារ ដែលទាមទារឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ តាមមាត្រា១៤(១)ដល់(៤) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ។

(ឃ) អន្តរកាលពីច្បាប់មុនទៅច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ

១០. សមាជិកនៃសហភាពដែលបានធ្វើវិសោធនកម្មច្បាប់របស់ខ្លួនឱ្យស្របតាមច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ អាចផ្តល់អត្ថប្រយោជន៍នៃច្បាប់ឆ្នាំ១៩៩១ ដល់ពូជដំណាំនានាដែលបានការពារតាមច្បាប់មុន។ ដូចនេះ សមាជិកនៃសហភាពមានលទ្ធភាពផ្តល់វិសាលភាពនៃកិច្ចការពារដូចមានចែងក្នុងមាត្រា១៤(៥) ដល់ពូជដំណាំនានាដែលត្រូវបានផ្តល់កិច្ចការពារតាមច្បាប់មុន។ ប៉ុន្តែគួរកត់សម្គាល់ថា ការផ្តល់វិសាលភាពថ្មីនៃសិទ្ធិលើពូជដំណាំដើមដែលបានការពារពីមុន អាចដាក់លក្ខខណ្ឌថ្មីពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្ម*ពូជដំណាំដែលមានស្រឡាយសំខាន់ ដែលពីមុនមិនទាមទារឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ។

១១. មធ្យោបាយមួយដូចខាងក្រោមដើម្បីដោះស្រាយស្ថានភាពនេះ : ចំពោះពូជដំណាំដែលកិច្ចការពារត្រូវបានផ្តល់ឱ្យតាមច្បាប់មុន ហើយដែលនៅមានរយៈពេលការពារតាមច្បាប់ថ្មី ត្រូវកម្រិតវិសាលភាពនៃសិទ្ធិលើពូជដំណាំដើមដែលបានការពារ ចំពោះពូជដំណាំដែលមានស្រឡាយសំខាន់ដែលមាន ហើយមិនបានស្គាល់ជាទូទៅនៅពេលដែលច្បាប់ថ្មីមានអនុភាពអនុវត្ត។ ចំពោះពូជដំណាំដែលមាន ហើយត្រូវបានគេស្គាល់ជាទូទៅ សេចក្តីណែនាំទូទៅសម្រាប់ត្រួតពិនិត្យភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព និងការអភិវឌ្ឍន៍សេចក្តីអធិប្បាយដែលបានធ្វើសុខដុមនីយកម្មនៃពូជថ្មីនៃដំណាំ(ឯកសារ TG/1/3) ពន្យល់ដូចខាងក្រោម:

"៥.២.២ <u>ការស្គាល់ជាទូទៅ</u>

៥.២.២.១ ទិដ្ឋភាពជាក់លាក់ដែលគួរត្រូវបានចាត់ទុកជាការស្គាល់ជាទូទៅ រួមមានជាអាទិ៍:

(ក) ការធ្វើពាណិជ្ជកម្មបំណែកពូជដែលអាចយកទៅដាំដុះបានឬបំណែកពូជដែលប្រមូលផលបាន ឬការបោះពុម្ពផ្សាយសេចក្តីអធិប្បាយលម្អិត

(ខ) ការដាក់ពាក្យស្នើសុំផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំឬសុំបញ្ចូលពូជដំណាំក្នុងបញ្ជីផ្លូវការពូជដំណាំ ក្នុងប្រទេសណាមួយ ដែលត្រូវចាត់ទុកថាពូជដំណាំត្រូវបានគេស្គាល់ជាទូទៅចាប់ពីកាលបរិច្ឆេទនៃពាក្យស្នើសុំ ឱ្យតែពាក្យស្នើសុំឈានដល់ការផ្តល់សិទ្ធិអ្នកបង្កាត់

*ការធ្វើពាណិជ្ជកម្មរួមមានអំពើនានាពាក់ព័ន្ធនឹងពូជដំណាំដែលបានការពារដែលទាមទារឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ តាមមាត្រា១៤(១)ដល់(៤) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ។

ពូជដំណាំ ឬ ឈានដល់ការបញ្ចូលពូជដំណាំក្នុងការបញ្ជីផ្លូវការនៃពូជដំណាំ តាមករណីនីមួយៗ។

(គ) អត្ថិភាពនៃបំណែកពូជដំណាំដែលមានជីវិតក្នុងការប្រមូលផ្ដុំដំណាំដែលសាធារណជនអាចរកបាន

“៥.២.២.២ ការស្គាល់ជាទូទៅ មិនកម្រិតចំពោះព្រំដែនជាតិ ឬព្រំដែនភូមិសាស្ត្រឡើយ” ។

**ផ្នែកទី ២: ការវាយតម្លៃពូជដំណាំដែលមានស្រឡាយសំខាន់**

១២. សេចក្តីសម្រេចលើការផ្តល់ឬមិនផ្តល់កិច្ចការពារពូជដំណាំ មិនត្រូវលើកមកពិចារណាថាពូជដំណាំ មានស្រឡាយសំខាន់ឬក៏អត់នោះទេ។ ពូជដំណាំនឹងត្រូវបានការពារ ប្រសិនបើបានបំពេញលក្ខខណ្ឌនៃកិច្ចការពារដូចបានកំណត់ក្នុងមាត្រា៥ នៃអនុសញ្ញាយូប៉ូវ (ថ្មីភាពខុសប្លែក ឯកសណ្ឋានភាព ស្ថេរភាព ការដាក់ឈ្មោះពូជដំណាំ ការបំពេញតាមលក្ខខណ្ឌទម្រង់ និងការបង់កម្រៃ)។ បន្ទាប់មក ប្រសិនបើមានការសន្និដ្ឋានថា ពូជដំណាំនេះជាពូជដំណាំដែលមានស្រឡាយសំខាន់ អ្នកបង្កាត់ពូជដំណាំដែលមានស្រឡាយសំខាន់នោះនៅតែមានសិទ្ធិទាំងអស់ដែលទទួលបានតាមអនុសញ្ញាយូប៉ូវ។ ប៉ុន្តែអ្នកបង្កាត់ពូជដំណាំដើមដែលបានការពារ នឹងមានសិទ្ធិផងដែរចំពោះពូជដំណាំនោះ ដោយមិនគិតថាពូជដំណាំដែលមានស្រឡាយសំខាន់ត្រូវបានការពារឬមិនបានការពារនោះទេ។

១៣. ក្នុងការកំណត់ថាពូជដំណាំមួយជាពូជដំណាំដែលមានស្រឡាយសំខាន់ សមាជិកទាំងឡាយនៃយូប៉ូវ បានបញ្ចេញទស្សនៈរួមថា អត្ថិភាពនៃទំនាក់ទំនងស្រឡាយសំខាន់រវាងពូជដំណាំដែលបានការពារទាំងឡាយ ជាបញ្ហារបស់ម្ចាស់សិទ្ធិអ្នកបង្កាត់ពូជដំណាំដែលពាក់ព័ន្ធ។

១៤. យូប៉ូវ បានបង្កើតផ្នែកមួយក្នុង គេហទំព័ររបស់ខ្លួន( ប្រព័ន្ធយូប៉ូវ: ធនធានច្បាប់: យុត្តិសាស្ត្រ)នៅពេលដែលរឿងក្តីពាក់ព័ន្ធនឹងសិទ្ធិអ្នកបង្កាត់ពូជដំណាំ រួមមានរឿងក្តី ដែលពាក់ព័ន្ធនឹងពូជដំណាំដែលមានស្រឡាយសំខាន់ត្រូវបានបោះពុម្ពផ្សាយក្នុងគេហទំព័រនេះ។

## កំណត់កំណត់ចំពោះមាត្រា១៥ ការលើកលែងចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ

### មាត្រា១៥(១)(i)

(១) [ការលើកលែងដោយបង្ខំ] សិទ្ធិអ្នកបង្កាត់ពូជដំណាំ គ្មានវិសាលភាពដល់

(i) សកម្មភាពដែលធ្វើឡើងដោយឯកជននិងគ្មានបំណងពាណិជ្ជកម្ម

កំណត់ពន្យល់នានាដូចខាងក្រោម មានបំណងបង្ហាញពីសកម្មភាពមួយចំនួនដែលអាចស្ថិតក្រោមការលើកលែងនិងសកម្មភាពមួយចំនួនដែលមិនស្ថិតក្រោមការលើកលែង:

១.១ សកម្មភាពដែលអាចមិនស្ថិតក្នុងវិសាលភាពនៃការលើកលែង

១.១.១ ការប្រើពាក្យនៃមាត្រា១៥(១)(i) បង្ហាញថា សកម្មភាពដែលធ្វើឡើងដោយឯកជននិងគ្មានបំណងពាណិជ្ជកម្ម ត្រូវស្ថិតក្រោមការលើកលែង។ ដូច្នេះសកម្មភាពមិនមែនឯកជនទោះបីគ្មានបំណងពាណិជ្ជកម្មក៏ដោយ អាចនៅក្រៅវិសាលភាពនៃការលើកលែង។

១.១.២ ជាងនេះទៅទៀត ការប្រើពាក្យបង្ហាញថា សកម្មភាពឯកជនដែលធ្វើឡើងក្នុងបំណងពាណិជ្ជកម្ម មិនស្ថិតក្រោមការលើកលែងនេះទេ។ ដូច្នេះកសិករដែលរក្សាទុកពូជដំណាំរបស់ខ្លួនដោយខ្លួនឯងផ្ទាល់ អាចចាត់ទុកជាសកម្មភាពឯកជន ប៉ុន្តែអាចចាត់ទុកមិនស្ថិតក្រោមការលើកលែងនេះ ប្រសិនបើការរក្សាទុកពូជដំណាំនេះ សម្រាប់បំណងពាណិជ្ជកម្ម។ ការលើកលែងជាជម្រើសដោយឡែក(សូមមើល មាត្រា១៥(២)) ត្រូវបានបង្កើតឡើងក្នុងអនុសញ្ញា ដើម្បីកំណត់ពីពូជដំណាំត្រូវបានរក្សាទុកដោយកសិករ (សូមមើល កំណត់ពន្យល់-មាត្រា១៥(២))។

១.២ សកម្មភាពដែលអាចស្ថិតក្រោមវិសាលភាពនៃការលើកលែង

ការប្រើពាក្យនៃមាត្រា១៥(១)(i) បង្ហាញថា អាចអនុញ្ញាត ដូចជា ការដាំដុះពូជដំណាំដោយអ្នកចូលចិត្តថៃសួនសម្រាប់ប្រើប្រាស់ផ្តាច់មុខក្នុងសួនរបស់ខ្លួន (ដូចជា បំណែកពូជដំណាំមិនបានផ្តល់ទៅអ្នកដទៃ) ដោយសាបញ្ហានេះអាចបង្កើតជាសកម្មភាពដែលមានលក្ខណៈឯកជននិងមិនមានគោលបំណងពាណិជ្ជកម្ម។ ដូចគ្នានេះដែរ ចំពោះការដាំដុះពូជដំណាំដោយកសិករម្នាក់សម្រាប់តែការផលិតដំណាំសម្រាប់បរិភោគ ដែលត្រូវប្រើប្រាស់ទាំងស្រុងដោយកសិករនិងអ្នកក្នុងបន្ទុកកសិករនោះ អាចត្រូវបានចាត់ទុកថាចូលក្នុងអត្ថន័យនៃសកម្មភាពដែលធ្វើឡើងដោយឯកជននិងគ្មានគោលបំណងពាណិជ្ជកម្ម។ ដូច្នេះ សកម្មភាពទាំងឡាយ រួមទាំងកសិកម្មលក្ខណៈគ្រួសារជាដើម នៅពេលដែលសកម្មភាពទាំងនេះ

ជាសកម្មភាពដែលធ្វើឡើងដោយឯកជននិងគ្មានបំណងពាណិជ្ជកម្ម អាចត្រូវបានចាត់ទុកថានៅក្រៅវិសាលភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំ ហើយកសិករដែលអនុវត្តសកម្មភាពទាំងនេះ ទទួលបានអត្ថប្រយោជន៍ដោយសេរីពីពូជដំណាំថ្មីដែលបានការពារ។

## មាត្រា១៥(១)(iii)

(១) [ការលើកលែងដោយបង្ខំ] សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់[...]

(iii) សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងបង្កាត់ពូជដំណាំផ្សេងទៀត និងសកម្មភាពដូចមានចែងក្នុងមាត្រា១៤(១)ដល់(៤) ទាក់ទងនឹងពូជដំណាំផ្សេងទៀត លើកលែងតែអនុវត្តបទប្បញ្ញត្តិនៃមាត្រា១៤(៥) ។

"ការលើកលែងរបស់អ្នកបង្កាត់ពូជដំណាំ"

១.៣ ការលើកលែងតាមមាត្រា១៥(១)(iii) ចែងថា សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់ "សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងបង្កាត់ពូជដំណាំផ្សេងទៀត" និងលើកលែងតែអនុវត្តបទប្បញ្ញត្តិនៃមាត្រា១៤(៥) សកម្មភាពដូចមានចែងក្នុងមាត្រា១៤(១)ដល់(៤) ទាក់ទងនឹងពូជដំណាំផ្សេងទៀត។ នេះជាធាតុមូលដ្ឋាននៃប្រព័ន្ធយូប៉ូវដើម្បីការពារពូជដំណាំដែលត្រូវស្គាល់ថាជាការលើកលែងរបស់អ្នកបង្កាត់ពូជដំណាំ នៅពេលដែលគ្មានការកម្រិតលើការប្រើប្រាស់ពូជដំណាំ ដែលបានការពារសម្រាប់គោលបំណងបង្កាត់ពូជថ្មីនៃដំណាំ។

១.៤ ផ្នែកទី២នៃមាត្រា១៥(១)(iii) "និងលើកលែងតែអនុវត្តបទប្បញ្ញត្តិនៃមាត្រា១៤(៥) សកម្មភាពដូចមានចែងក្នុងមាត្រា១៤(១)ដល់(៤) ទាក់ទងនឹងពូជដំណាំផ្សេងទៀត"បញ្ជាក់ថាលើកលែងតែចំពោះពូជដំណាំក្នុងមាត្រា១៤(៥) ដូចជា ពូជដំណាំដែលមានស្រលាយសំខាន់ ពូជដំណាំដែលមិនខុសស្រឡះពីពូជដំណាំដែលបានការពារ និងពូជដំណាំដែលការផលិតរបស់វាទាមទារការប្រើប្រាស់ម្តងហើយម្តងទៀតនៃពូជដំណាំ ដែលបានការពារ ការធ្វើពាណិជ្ជកម្ម[៥]ពូជដំណាំថ្មីដែលទទួលបាន មិនទាមទារឱ្យមានការអនុញ្ញាតពីម្ចាស់ពូជដំណាំដែលបានការពារហើយដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតពូជដំណាំថ្មីទាំងនេះ។

១.៥ គំនូសខាងក្រោម បង្ហាញពីស្ថានភាពជាសម្មតិកម្មមួយនៅពេលដែលអ្នកបង្កាត់ពូជដំណាំប្រើប្រាស់ពូជដំណាំដែលបានការពារ **ក** និងពូជដំណាំដែលមិនបានការពារ **ខ** សម្រាប់បង្កាត់ពូជដំណាំថ្មី **គ**។ គំនូសនេះបង្ហាញថា មិនទាមទារឱ្យមានការអនុញ្ញាតដើម្បីបង្កាត់ពូជដំណាំ **គ** ទេ។ ជាងនេះទៅទៀត ការធ្វើពាណិជ្ជកម្មពូជដំណាំ **គ** មិនទាមទារការ

[៥] ក្នុងឯកសារនេះពាក្យ "ការធ្វើពាណិជ្ជកម្ម" ត្រូវបានប្រើប្រាស់ដើម្បីគ្របដណ្តប់លើសកម្មភាពទាំងឡាយដែលមានក្នុងមាត្រា១៤(i)ដល់(iv)នៃច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ។

អនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ **ក** លើកលែងតែនៅពេលដែលពូជដំណាំ **គ** ជាពូជដំណាំដែលមានស្រឡាយសំខាន់ ឬ ជាពូជដំណាំ ដែលទាមទារឱ្យប្រើប្រាស់ម្តងហើយម្តងទៀតនៃពូជដំណាំដែលបានការពារ **ក** ឬ ជាពូជដំណាំដែលមិនខុសស្រឡះពីពូជដំណាំដែលបានការពារ **ក** (សូមមើល មាត្រា១៤(៥) ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ)។

គំនូសចំពោះ “ការលើកលែងរបស់អ្នកបង្កាត់ពូជដំណាំ”




*លើកលែងចំពោះ:

(i) ពូជដំណាំដែលមានស្រឡាយសំខាន់ពីពូជដំណាំដែលបានការពារ នៅពេលដែលពូជដំណាំដែលបានការពារមិនមែនជាពូជដំណាំដែលមានស្រឡាយសំខាន់នោះទេ

(ii) ពូជដំណាំដែលមិនខុសគ្នាស្រឡះតាមមាត្រា៧ ពីពូជដំណាំដែលបានការពារ និង

(iii) ពូជដំណាំដែលការផលិតទាមទារឱ្យប្រើប្រាស់ពូជដំណាំដែលបានការពារម្តងហើយម្តងទៀត។

## មាត្រា១៥(២)

(២) [ការលើកលែងតាមជម្រើស] ថ្វីបើមានចែងក្នុងមាត្រា១៤[៦]ក៏ដោយ ក៏ភាគីហត្ថលេខីនីមួយៗ អាចក្នុងកម្រិតសមរម្យនិងលើកលែងតែដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ កម្រិតសិទ្ធិអ្នកបង្កាត់ពូជដំណាំទាក់ទងនឹងពូជដំណាំណាមួយ ដើម្បីអនុញ្ញាតឱ្យកសិករប្រើប្រាស់ដោយខ្លួនឯង សម្រាប់គោលបំណង ដាំដុះបន្តនូវផលិតផលដែលប្រមូលផលបានពីពូជដំណាំដែលបានការពារ ឬពូជដំណាំដែលគ្រប់គ្រងដោយមាត្រា១៤(៥)(ក)(i)ឬ(ii) ។

២.១ ការសម្រេចអនុវត្តការលើកលែងជាជម្រើស

២.១.១មាត្រា១៥(២) ជាបទប្បញ្ញត្តិ "ជាជម្រើស" ដូចបញ្ជាក់ដោយប្រើពាក្យ "...ភាគីហត្ថលេខីនីមួយៗ <u>អាច</u>..."។ ដូច្នេះ ជាបញ្ហារបស់សមាជិកនីមួយៗ ក្នុងការសម្រេចថា ត្រឹមត្រូវដែរឬទេក្នុងការបញ្ចូលជម្រើសដូចមានចែងក្នុងមាត្រា១៥(២)។ គោលបំណងនៃកថាខណ្ឌខាងក្រោម គឺផ្តល់មគ្គុទ្ទេសក៍ដល់សមាជិកនៃសហភាពដែលសម្រេចបញ្ចូលការលើកលែងជាជម្រើសក្នុងច្បាប់របស់ខ្លួន។

២.១.២ នៅពេលពិចារណារបៀបដែលអាចអនុវត្ត ការលើកលែងជាជម្រើស សន្និសីទការទូតឆ្នាំ១៩៩១ (សូមមើលទំព័រ៦៣ នៃការបោះពុម្ពផ្សាយយូប៉ូវ លេខ ៣៤៦(E) "កំណត់ត្រាសន្និសីទការទូតសម្រាប់កែប្រែអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ") បានផ្តល់អនុសាសន៍ដូចខាងក្រោម:

"សន្និសីទការទូតផ្តល់អនុសាសន៍ថា បទប្បញ្ញត្តិក្នុងមាត្រា១៥(២)នៃអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៦១ ដែលបានកែប្រែនៅទីក្រុងហ្សឺណែវ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧២ ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៧៨និង ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ១៩៩១ មិនគួរយល់ថាជាចេតនាបើកចំហលទ្ធភាពពង្រីកការអនុវត្តន៍ ដែលជាទូទៅ ហៅថា 'អភ័យឯកសិទ្ធិកសិករ' ចំពោះវិស័យកសិកម្ម ឬ ផលិតកម្មសាកវប្បកម្ម ដែលអភ័យឯកសិទ្ធិនេះ មិនមែនជាការអនុវត្តន៍ទូទៅក្នុងដែនដីនៃភាគីហត្ថលេខីដែលពាក់ព័ន្ធ"។

[៦] មាត្រា១៤"វិសាលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ"។

២.១.៣ អនុសាសន៍សន្និសីទការទូត បង្ហាញថា ការលើកលែងជាជម្រើស សំដៅទៅរកផលដំណាំទាំងនេះនៅពេលដែលមានការអនុវត្តន៍ទូទៅរបស់កសិករ ដែលការរក្សាទុកបំណែកពូជដែលប្រមូលផលបានសម្រាប់ការដាំដុះបន្ត ចំពោះសមាជិកសហភាពដែលពាក់ព័ន្ធ។

២.១.៤ មាត្រា១៥(២) ចែងថា "ភាគីហត្ថលេខីនីមួយៗ អាច,[...] កម្រិតសិទ្ធិអ្នកបង្កាត់ពូជដំណាំទាក់ទងនឹងពូជដំណាំណាមួយ ដើម្បីអនុញ្ញាតឱ្យកសិករប្រើប្រាស់ដោយខ្លួនឯង សម្រាប់គោលបំណងដាំដុះបន្តនូវផលិតផលដែលប្រមូលផលបានពីពូជដំណាំដែលបានការពារ ឬពូជដំណាំដែលគ្រប់គ្រងដោយមាត្រា១៤(៥)(ក)(i)ឬ(ii)។(ការគូសបន្ទាត់ពីក្រោមបន្ថែមដើម្បីសង្កត់ន័យ)

២.១.៥ ការប្រើពាក្យនេះបង្ហាញថា ការលើកលែងជាជម្រើសអាចត្រូវបានចាត់ទុកថាទាក់ទងនឹងផលដំណាំដែលបានជ្រើសរើស នៅពេលដែលផលិតផលដែលប្រមូលផលបាន ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដាំដុះ ដូចជាធញ្ញជាតិគ្រាប់តូច នៅពេលដែលគ្រាប់ធញ្ញជាតិដែលប្រមូលផលបានអាចប្រើដូចគ្នាជាពូជ ដូចជាបំណែកពូជដែលអាចយកទៅដាំដុះបាន។ រួមជាមួយអនុសាសន៍ទាក់ទងនឹងមាត្រា១៥(២)នៃសន្និសីទការទូតឆ្នាំ១៩៩១(សូមមើលខាងលើ) ការប្រើពាក្យ ក៏បង្ហាញផងដែរថា អាចចាត់ទុកថាមិនសមរម្យក្នុងការបញ្ចូលការលើកលែងជាជម្រើសចំពោះវិស័យកសិកម្មឬវិស័យសាកវប្បកម្ម ដូចជាដំណាំផ្លែឈើ ដំណាំលម្អនិងបន្លែ នៅពេលដែលការលើកលែងជាជម្រើសមិនមែនជាការអនុវត្តទូទៅចំពោះ បំណែកពូជដែលប្រមូលផលបាន ដែលត្រូវប្រើប្រាស់ជាបំណែកពូជដែលអាចយកទៅដាំដុះបាន។

២.២ "ការកម្រិតសមរម្យនិងកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ"

២.២.១ អនុផ្នែក(ខ) ពន្យល់ថា ការលើកលែងជាជម្រើសអាចត្រូវបានបញ្ចូលចំពោះផលដំណាំដែលបានជ្រើសរើស។ ចំពោះផលដំណាំនេះ អនុសញ្ញាយូប៉ូវ មាត្រា១៥(២) ចែងថា:

"ថ្វីបើមានចែងក្នុងមាត្រា១៤ក៏ដោយ ក៏ភាគីហត្ថលេខីនីមួយៗអាច ក្នុងកម្រិតសមរម្យនិងលើកលែងតែដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំកម្រិតសិទ្ធិអ្នកបង្កាត់ពូជដំណាំ[...]" (គូសបន្ទាត់ពីក្រោមបន្ថែមដើម្បីសង្កត់ន័យ)

២.២.២ ចំពោះផលដំណាំទាំងនេះ នៅពេលដែលមានការបញ្ចូលការលើកលែងជាជម្រើស ទាក់ទងនឹងការណែនាំពីការកម្រិតសមរម្យ និងកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំក្នុងច្បាប់ស្តីពីសិទ្ធិអ្នកបង្កាត់ពូជដំណាំ កត្តា ឬ បណ្តុំនៃកត្តាជាអាទិ៍ដូចខាងក្រោម អាចត្រូវបានពិចារណា។

**ប្រភេទពូជដំណាំ**

២.២.៣ នៅពេលដែលសម្រេចបញ្ចូលការលើកលែងជាជម្រើសចំពោះផលដំណាំ ឬប្រភេទពូជជាក់លាក់ណាមួយ អាចបញ្ជាក់តែប្រភេទពូជដំណាំមួយចំនួនដែលការលើកលែងនេះអាចអនុវត្ត។ ឧទាហរណ៍ អាជ្ញាធរអាចសម្រេចមិនពង្រីកការលើកលែងជាជម្រើសចំពោះប្រភេទពូជដំណាំមួយចំនួន ដូចជា ពូជបង្កាត់ទំនើប ឬពូជដំណាំសំយោគ។ នេះអនុញ្ញាតឱ្យអាជ្ញាធរអាចពិចារណាថាតើ មានការអនុវត្តជាទូទៅ របស់កសិករដែលរក្សាទុកបំណែកពូជដែលប្រមូលផលបានសម្រាប់ការដាំដុះបន្ត ហើយថា តើជាការសមរម្យទេ ដើម្បីបញ្ចូលការលើកលែងជាជម្រើសចំពោះប្រភេទពូជដំណាំទាំងនេះ។

**ទំហំដែលកាន់កាប់/តំបន់ផលដំណាំ/តម្លៃផលដំណាំ**

២.២.៤ ឧទាហរណ៍នៃកត្តានានាដែលអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់ការកម្រិតសមរម្យ និងដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ គឺទំហំដែលកសិករកាន់កាប់ តំបន់នៃផលដំណាំដែលពាក់ព័ន្ធនឹងការដាំដុះដោយកសិករ ឬតម្លៃផលដំណាំដែលប្រមូលផលបាន។ ដូច្នេះកសិកម្មខ្នាតតូចដែលកាន់កាប់តិចតួច(ឬតំបន់តូចនៃផលដំណាំ) អាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ពូជដំណាំដែលរក្សាទុកដោយកសិករ ត្រឹមកម្រិតមួយផ្សេង ហើយក្នុងកម្រិតលាភការមួយផ្សេង ចំពោះអ្នកបង្កាត់ពូជដំណាំ ជាងកសិកម្មខ្នាតធំ។ប៉ុន្តែទំហំនៃការកាន់កាប់(ឬតំបន់ផលដំណាំ) ដែលកំណត់ថាជាកសិកម្មខ្នាតតូច អាចមានប្រភេទផ្សេងៗពីគ្នា នៅពេលពិចារណាលើការកម្រិតសមរម្យ និងកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំចំពោះសមាជិកនីមួយៗនៃសហភាព។

ឧទាហរណ៍

ក្នុងប្រទេស ក កសិករដែលកាន់កាប់(ឬតំបន់ផលដំណាំ)តិចជាង១០ហិកតា អាចទទួលបានតែ៥%(ប្រាំភាគរយ)នៃផលិតផល X។ ដូច្នេះ ក្នុងប្រទេស ក ការកំណត់កម្រិត ១០ហិកតា ចំពោះកសិកម្មខ្នាតតូចហើយអនុញ្ញាតឱ្យកសិកម្មខ្នាតតូចបន្ថយការបង់លាភការ ឬមិនបាច់បង់លាភការ ចំពោះដំណាំX អាចមានតែផលប៉ះពាល់តិចតួចដល់លាភការទាំង

មូលរបស់អ្នកបង្កាត់ពូជដំណាំប៉ុណ្ណោះ។ ផ្ទុយមកវិញ ក្នុងប្រទេស ខ កសិករដែលកាន់កាប់(ឬតំបន់ផលដំណាំ)តិចជាង១០ហិចតានៃដំណាំX អាចទទួលបាន៩០%(ភាគរយ)នៃផលិតផល។ ដូច្នេះក្នុងប្រទេស ខ ការកំណត់កម្រិត១០ហិចតាសម្រាប់កសិកម្មខ្នាតតូចនិងការអនុញ្ញាតកសិកម្មខ្នាតតូចឱ្យបង់កម្រៃមួយដែលបានកាត់បន្ថយ ឬលាភការសូន្យចំពោះផលដំណាំX នឹងមានផលប៉ះពាល់ច្រើនដល់លាភការទាំងមូលរបស់អ្នកបង្កាត់ពូជដំណាំ។ ការវាយតម្លៃថាតើគំនិតនេះគួរស្ថិតនៅក្នុងការកម្រិតសមរម្យ និងជាកម្មវត្ថុនៃកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ នឹងទាមទារការពិចារណាទាក់ទងនឹងច្បាប់ពាក់ព័ន្ធចំពោះសមាជិកនៃសហភាពដែលពាក់ព័ន្ធ។

## សមាមាត្រ ឬ ចំនួនផលដំណាំដែលប្រមូលផលបាន

២.២.៥ ឧទាហរណ៍នៃកត្តាមួយផ្សេងទៀតដែលអាចត្រូវបានពិចារណាទាក់ទងនឹងការកម្រិតសិទ្ធិសមរម្យនិងកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំគឺសមាមាត្រ ឬចំនួនផលដំណាំពាក់ព័ន្ធ ដែលអាចជាកម្មវត្ថុនៃការលើកលែងជាជម្រើស។ ដូច្នេះជាឧទាហរណ៍ សមាជិកមួយនៃសហភាពមានជម្រើសក្នុងការកំណត់ភាគរយអតិបរមានៃផលដំណាំដែលប្រមូលផលបានដែលកសិករអាចប្រើប្រាស់សម្រាប់ដាំដុះបន្ត។ ភាគរយដែលបានកំណត់អាចប្រែប្រួលទៅតាមទំហំនៃកសិដ្ឋាន(ឬតំបន់ផលដំណាំ) និង/ឬកម្រិតលាភការដូចភាគរយនៃស្តង់ដារលាភការ ដែលបានកំណត់ចំពោះ សមាមាត្រនៃពូជដំណាំដែលរក្សាទុកសម្រាប់កសិកម្ម ដែលកសិករប្រើប្រាស់។ ជាងនេះទៅទៀត ចំនួននៃផលដំណាំដែលប្រមូលផលបានដែលអនុវត្តការលើកលែងជាជម្រើស អាចត្រូវបានកំណត់ចំពោះបរិមាណបំណែកពូជដែលអាចយកទៅដាំដុះបាននៃពូជដំណាំ ដែលបានការពារដែលកសិករទទួលបានពីដំបូង កំណត់ដោយចំនួនដែលស្របទៅនឹងដំណាំដែលកសិករកាន់កាប់ ឬ ដោយចំនួនដែលត្រូវបានប្រើប្រាស់សមស្របដោយកសិករនិងអ្នកក្នុងបន្ទុករបស់ខ្លួន។ ចំនួននេះអាចត្រូវបានបង្ហាញផងដែរ ជាទំហំដីអតិបរមាដែលអាចត្រូវបានដាំដុះដោយប្រើប្រាស់ផលដំណាំដែលប្រមូលផលបាន។

## ការផ្លាស់ប្តូរស្ថានភាព

២.២.៦ កិច្ចការពារពូជដំណាំជម្រុញឱ្យមានការបង្ហាញពូជថ្មីនៃដំណាំ ហើយ កិច្ចការពារនេះផ្ទាល់អាចឈានដល់ការផ្លាស់ប្តូរកម្រិតបំណែកពូជដែលប្រមូលផលបានដែលត្រូវប្រើប្រាស់សម្រាប់ដាំដុះបន្ត(ពូជដំណាំរក្សាទុកសម្រាប់កសិកម្ម)នៃផលដំណាំពាក់ព័ន្ធ។ ជាងនេះទៅទៀត ការវិវត្តន៍ការអនុវត្តន៍កសិកម្មនិងវិធិសាស្រ្តបង្កាត់និងវិធីសាស្រ្តដាំដុះ ក៏ដូចជាការ

អភិវឌ្ឍន៍សេដ្ឋកិច្ច អាចនាំទៅរកការផ្លាស់ប្តូរកម្រិតបំណែកពូជដែលប្រមូលផលបាន ដែលត្រូវប្រើប្រាស់សម្រាប់ការដាំដុះបន្ត។ ដូច្នេះ សមាជិកមួយនៃសហភាពអាច ដូចជាកម្រិតពូជដំណាំរក្សាទុកដោយកសិករ ទាក់ទងនឹងកម្រិតទាំងនោះដែលជាការអនុវត្តន៍ទូទៅមុនមានកិច្ចការពារពូជដំណាំ។

**លាភការ**

២.២.៧ ចំពោះផលដំណាំនានាដែលមានការលើកលែងជាជម្រើស លក្ខខណ្ឌដើម្បីផ្តល់លាភការដល់អ្នកបង្កាត់ពូជដំណាំអាចត្រូវបានចាត់ទុកជាមធ្យោបាយការពារសិទ្ធិស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ។

២.៣ ការកាន់កាប់របស់កសិករ

២.៣.១ ការលើកលែងជាជម្រើសត្រូវបានកម្រិតចំពោះការអនុញ្ញាតដូចខាងក្រោមៈ

"កសិករដើម្បីប្រើប្រាស់ សម្រាប់គោលបំណងដាំដុះ ដោយខ្លួនឯងនូវផលិតផលដែលប្រមូលផលបានដែលទទួលបានពីការដាំដុះដោយខ្លួនឯង នូវពូជដំណាំដែលបានការពារឬពូជដំណាំមួយដែលគ្រប់គ្រងដោយមាត្រា១៤(៥)(ក)(i)ឬ(ii)"។ (គូសបន្ទាត់ពីក្រោមបន្ថែមដើម្បីសង្កត់ន័យ)

២.៣.២ ការប្រើពាក្យរបស់អនុសញ្ញា បញ្ជាក់ថា ការលើកលែងជាជម្រើស ទាក់ទងនឹងការប្រើប្រាស់ផលិតផលដែលកសិករប្រមូលផលបានដោយខ្លួនឯង។ ដូច្នេះជាឧទាហរណ៍ ការលើលែងជាជម្រើស គ្មានវិសាលភាពលើបំណែកពូជដែលអាចយកទៅដាំដុះបាន ដែលត្រូវបានផលិតដោយកសិករផ្សេងទៀតផ្ទាល់ទេ។

២.៤ ការអនុវត្តន៍ការលើកលែងជាជម្រើសក្នុងមាត្រា១៥(២)

២.៤.១ ការបញ្ចូលការលើកលែងជាជម្រើសក្នុងច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ទទួលស្គាល់ថា មានការអនុវត្តន៍ទូទៅរបស់កសិករដែលរក្សាទុកផលិតផលដែលប្រមូលផលបានសម្រាប់គោលបំណងដាំដុះចំពោះផលដំណាំមួយចំនួន ហើយបទប្បញ្ញត្តិនេះអនុញ្ញាតឱ្យសមាជិកនីមួយៗនៃសហភាពពិចារណាពីការអនុវត្តន៍នេះ និងបញ្ហានានាដែលពាក់ព័ន្ធដោយឈរលើមូលដ្ឋាន**ពីដំណាំមួយទៅដំណាំមួយ** នៅពេលផ្តល់កិច្ចការពារពូជដំណាំ។ ការប្រើប្រាស់ពាក្យ ក្នុងការកម្រិតសិទ្ធិសមរម្យនិងកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកបង្កាត់ពូជដំណាំ ស្របនឹងវិធីសាស្ត្រដែលធ្វើឡើងតាមរបៀបដែលមិនប៉ះពាល់ដល់ការ

លើកទឹកចិត្តដែលអនុសញ្ញាយូប៉ូវបានផ្តល់ឱ្យចំពោះអ្នកបង្កាត់ពូជដំណាំក្នុងការអភិវឌ្ឍពូជថ្មីនៃដំណាំ ប្រសិនបើមានការអនុវត្តន៍ការលើកលែងជាជម្រើស ។

២.៤.២ ត្រូវបញ្ជាក់ថា វាជាបញ្ហារបស់សមាជិកនីមួយៗនៃសហភាពដើម្បីសម្រេចថាតើខ្លួនចង់អនុវត្តនិងសម្រេចពីរបៀបអនុវត្តមាត្រា១៥(២)។ ក្នុងចំណោមកត្តានានាដែលត្រូវពិចារណា មានឥទ្ធិពលលើការបង្កាត់ ចំណាយនិងយន្តការតម្រូវឱ្យអនុវត្តន៍និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចទាំងមូលចំពោះកសិកម្ម។ ការពិភាក្សាជាមួយភាគីពាក់ព័ន្ធ ជាពិសេសជាមួយអ្នកបង្កាត់ពូជដំណាំនិងកសិករ ដើម្បីវាយតម្លៃអានុភាពទាំងនេះ អាចជាមធ្យោបាយមួយដ៏សំខាន់ដើម្បីធានាអនុវត្តន៍ឱ្យបានជោគជ័យ។

២.៤.៣ តាមការវិវត្តន៍នៃពេលវេលា កត្តានានា ដូចជាការវិវត្តន៍ការអនុវត្តន៍កសិកម្ម និងការវិវត្តន៍វិធីសាស្រ្តបង្កាត់ពូជនិងដាំដុះ ក៏ដូចជាការអភិវឌ្ឍន៍សេដ្ឋកិច្ច អាចទាមទារឱ្យមានការផ្លាស់ប្តូរយន្តការអនុវត្តណាមួយនៃការលើកលែងជាជម្រើស ដើម្បីធានាថាអត្ថប្រយោជន៍ល្អបំផុតពីកិច្ចការពារពូជដំណាំត្រូវបានទទួលដោយសមាជិកនៃសហភាពពាក់ព័ន្ធ។ ដូច្នេះអាច មានអត្ថប្រយោជន៍ក្នុងក្របខ័ណ្ឌច្បាប់មួយចំនួន ដើម្បីបញ្ចូលបទប្បញ្ញត្តិដែលធ្វើឱ្យការធ្វើបច្ចុប្បន្នភាពនេះអាចអនុវត្តបាន។

២.៤.៤ លើសពីនេះ អាជ្ញាធរនានាដែលព្រាងច្បាប់ត្រូវបានអញ្ជើញឱ្យទាក់ទងទៅការិយាល័យនៃសហភាពចំពោះព័ត៌មានពីឧទាហរណ៍នៃច្បាប់របស់សមាជិកនៃសហភាព ដែលអាចទាក់ទងច្រើនបំផុតទៅនឹងកាលៈទេសៈដោយឡែករបស់ខ្លួន។

## កំណត់ពន្យល់ចំពោះមាត្រា១៦ ការរលត់សិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [ការរលត់សិទ្ធិ] សិទ្ធិអ្នកបង្កាត់ពូជដំណាំគ្មានវិសាលភាពដល់សកម្មភាពពាក់ព័ន្ធនឹងបំណែកពូជណាមួយនៃពូជដំណាំដែលបានការពារ ឬ នៃពូជដំណាំដែលគ្រប់គ្រងដោយបទប្បញ្ញត្តិនៃមាត្រា១៤(៥) ដែលបានលក់ឬចរាចរដោយអ្នកបង្កាត់ពូជដំណាំ ឬ ដោយមានការយល់ព្រមពីខ្លួនក្នុងដែនដីនៃភាគីហត្ថលេខីដែលពាក់ព័ន្ធ ឬ បំណែកពូជណាមួយដែលមានស្រឡាយពីបំណែកពូជនេះ លើកលែងតែសកម្មភាពទាំងនេះ :

(i) ទាក់ទងនឹងការដាំដុះបន្តនៃពូជដំណានេះ ឬ

(ii) ទាក់ទងនឹងការនាំចេញបំណែកនៃពូជដំណាំ ដែលអាចបណ្តុះពូជដំណាំបានទៅប្រទេសមួយ ដែលមិនការពារពូជដំណាំនៃអំបូរឬប្រភេទពូជរុក្ខជាតិដែលជាពូជដំណាំ លើកលែងតែបំណែកពូជនាំចេញមានគោល-បំណងសម្រាប់ប្រើប្រាស់ចុងក្រោយ។

(២) [ អត្ថន័យនៃ"បំណែកពូជ"] សម្រាប់គោលបំណងនៃកថាខណ្ឌទី(១) ទាក់ទងនឹងពូជដំណាំ "បំណែកពូជ" មានន័យថា:

(i) បំណែកពូជនៃប្រភេទណាមួយដែលអាចយកទៅដាំដុះបាន

(ii) បំណែកពូជដែលប្រមូលផលបាន រួមទាំងដំណាំទាំងមូល និង ផ្នែកនៃដំណាំ និង

(iii) ផលិតផលណាមួយ ដែលបង្កើតឡើងដោយផ្ទាល់ពីបំណែកពូជ ដែលប្រមូលផលបាន។

(៣) ["ដែនដី" ក្នុងករណីមួយចំនួន] សម្រាប់គោលបំណងក្នុងកថាខណ្ឌ(១) ភាគីហត្ថលេខីទាំងអស់ ដែលជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលមួយដូចគ្នា នៅពេលដែលវិធានរបស់អង្គការតម្រូវ អាចចាត់វិធានការរួមគ្នាដើម្បីប្រៀបប្រដូចសកម្មភាពដែលប្រព្រឹត្តិលើដែនដីនៃរដ្ឋសមាជិករបស់អង្គការនោះ ទៅនឹងសកម្មភាពដែលធ្វើឡើងក្នុងដែនដីរបស់ខ្លួនផ្ទាល់ ហើយបើធ្វើបែបនេះ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ។

**កំណត់ពន្យល់ចំពោះមាត្រា១៧ ការកម្រិតលើការអនុវត្តន៍សិទ្ធិអ្នកបង្កាត់ពូជដំណាំ**

(១) [ផលប្រយោជន៍សាធារណៈ] លើកលែងតែមានចែងច្បាស់ក្នុងអនុសញ្ញានេះ គ្មានភាគីហត្ថលេខីណាមួយអាចកម្រិតសេរីភាពអនុវត្តសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដោយមូលហេតុផ្សេងក្រៅពីផលប្រយោជន៍សាធារណៈឡើយ។

(២) [ លាភការសមរម្យ ] នៅពេលដែលការកម្រិតបែបនេះមានអនុភាពអនុញ្ញាតឱ្យតតិយជនដើម្បីធ្វើសកម្មភាពណាមួយ ដែលតម្រូវឱ្យមានការអនុញ្ញាតពីអ្នកបង្កាត់ពូជដំណាំ ភាគីហត្ថលេខីពាក់ព័ន្ធត្រូវចាត់រាល់វិធានការចាំបាច់ដើម្បីធានាថា អ្នកបង្កាត់ពូជដំណាំទទួលបានលាភការសមរម្យ។

## កំណត់ពន្យល់ចំពោះមាត្រា១៨ វិធានការគ្រប់គ្រងពាណិជ្ជកម្ម

សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវឯករាជ្យពីវិធានការរបស់ភាគីហត្ថលេខីក្នុងការគ្រប់គ្រងលើដែនដីរបស់ខ្លួននូវ ការផលិត ការបញ្ជាក់និងចរាចរបំណែកពូជដំណាំ ឬការនាំចូលឬការនាំចេញបំណែកពូជនេះ។ ប៉ុន្តែ វិធានការទាំងនេះមិនត្រូវប៉ះពាល់ដល់ការអនុវត្តន៍បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះឡើយ។

ក្នុងកិច្ចប្រជុំសាមញ្ញទី៣៧របស់ខ្លួន ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៣ ទាក់ទងនឹងបទប្បញ្ញត្តិតាមមាត្រា១៨ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ ក្រុមប្រឹក្សាយូប៉ូវ អនុម័ត "ការឆ្លើយតបរបស់យូប៉ូវចំពោះសេចក្តីជូនដំណឹងថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៣ ពីលេខាធិការប្រតិបត្តិនៃអនុសញ្ញាស្តីពីជីវៈចម្រុះ (CBD)" (http://www.upov.int/news/en/2003/pdf/cbd response oct 23 2003.pdf) កថាខណ្ឌ(៩) ត្រូវបានស្រង់ឡើងវិញដូចខាងក្រោម:

> "៩.ក្នុងក្របខណ្ឌគោលនយោបាយទូទៅរបស់ខ្លួន ប្រសិនបើប្រទេសមួយ សម្រេចបង្កើតយន្តការចំពោះការបង្ហាញប្រទេសដើម ឬភូមិសាស្ត្រដើមនៃសមាសធាតុហ្សែន យន្តការនេះមិនត្រូវដាក់ក្នុងន័យចង្អៀត ដែលជាលក្ខខណ្ឌការពារពូជ ដំណាំនោះទេ។ យន្តការដោយឡែកពីច្បាប់ការពារពូជដំណាំ ដូចជាការប្រើប្រាស់សម្រាប់លក្ខខណ្ឌភូតគាមអនាម័យ អាចត្រូវបានអនុវត្តឱ្យមានឯកសណ្ឋានភាពចំពោះសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មពូជដំណាំ រួមទាំងគុណភាពពូជដំណាំ ឬចរាចរផ្សេងទៀតដែលទាក់ទងនឹងបទប្បញ្ញត្តិនេះជាដើម"។

### កំណត់ពន្យល់ចំពោះមាត្រា១៩ រយៈពេលការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ

(១) [ រយៈពេលនៃកិច្ចការពារ] សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវផ្តល់ឱ្យក្នុងរយៈពេលកំណត់មួយ។

(២) [រយៈពេលអប្បបរមា] រយៈពេលនេះមិនត្រូវខ្លីជាង២០(ម្ភៃ)ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។ ចំពោះដំណាំឈើ និងដំណាំវល្លិ រយៈពេលនេះមិនត្រូវខ្លីជាង២៥ (ម្ភៃប្រាំ)ឆ្នាំរាប់ចាប់ពីការបរិច្ឆេទទទួលបានសិទ្ធិនេះ។

១.១ រយៈពេលការពារ មិនត្រូវខ្លីជាង២០(ម្ភៃ)ឆ្នាំនិងមិនត្រូវខ្លីជាង២៥(ម្ភៃប្រាំ)ឆ្នាំ ចំពោះដំណាំឈើនិងដំណាំវល្លិ។

១.២ រយៈពេលការពារចាប់រាប់ពីកាលបរិច្ឆេទនៃការផ្តល់ ( សូមមើលផងដែរ កំណត់ពន្យល់-មាត្រា ១៣ “កិច្ចការពារបណ្តោះអាសន្ន”)។

## កំណត់ពន្យល់ចំពោះមាត្រា២០ ការដាក់ឈ្មោះពូជដំណាំ

## មាត្រា២០(១)

(១) [ការកំណត់ពូជដំណាំដោយការដាក់ឈ្មោះ ការប្រើប្រាស់ការដាក់ឈ្មោះ] (ក) ពូជដំណាំត្រូវតំណត់ដោយការដាក់ឈ្មោះ ដែលនឹងក្លាយជាការកំណត់ប្រភេទពូជដំណាំ។

(ខ) លើកលែងតែកថាខណ្ឌទី(៤) សមាជិកនីមួយៗនៃសហភាពត្រូវធានាថា សិទ្ធិចំពោះការកំណត់ដែលបានចុះបញ្ជីជាការដាក់ឈ្មោះពូជដំណាំ មិនត្រូវរារាំងការប្រើប្រាស់ដោយសេរីនៃការដាក់ឈ្មោះពូជដំណាំ ទោះបីបន្ទាប់ពីផុតសុពលភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំក៏ដោយ។

១.១ មាត្រា៥(២)ច្បាប់ឆ្នាំ១៩៩១នៃអនុសញ្ញាយូប៉ូវ តម្រូវថា ពូជដំណាំត្រូវកំណត់ដោយការដាក់ឈ្មោះ។លើកលែងតែមានសិទ្ធិពីមុន កថាខណ្ឌ(១) ចែងពីការដាក់ឈ្មោះដែលជាការកំណត់ប្រភេទពូជដំណាំ គ្មានសិទ្ធិក្នុងការកំណត់ណាមួយ ត្រូវរារាំងការប្រើប្រាស់ដោយសេរីនៃការដាក់ឈ្មោះពូជដំណាំ ទោះបីបន្ទាប់ពីផុតសុពលភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំក៏ដោយ។ កាតព្វកិច្ចតាមកថាខណ្ឌ(១) ត្រូវពិចារណារួមជាមួយកាតព្វកិច្ចប្រើប្រាស់ការដាក់ឈ្មោះពូជ ដំណាំ ចំពោះការដាក់លក់ឬចរាចរបំណែកពូជដែលអាចយកទៅដាំដុះបាន(សូមមើលកថាខណ្ឌ(៧))។

១.២ កាតព្វកិច្ចតាមកថាខណ្ឌ(១) ដើម្បីអនុញ្ញាឱ្យប្រើប្រាស់ការដាក់ឈ្មោះ ទាក់ទងនឹងពូជដំណាំ ទោះបីបន្ទាប់ពីផុតសុពលភាពសិទ្ធិអ្នកបង្កាត់ពូជដំណាំក៏ដោយ មានទំនាក់ទំនងជាមួយគ្នា ប្រសិនបើ អ្នកបង្កាត់ពូជដំណាំក៏ជាម្ចាស់ម៉ាកដែលដូចគ្នាទៅនឹងការដាក់ឈ្មោះពូជដំណាំ។ គួរកត់សម្គាល់ថានៅពេលដែល អាជ្ញាធរម៉ាក ចុះបញ្ជីឈ្មោះមួយជាម៉ាក ការប្រើប្រាស់ឈ្មោះនេះ ជាការដាក់ឈ្មោះពូជដំណាំអាចបំលែងម៉ាកទៅជាឈ្មោះទូទៅមួយ។ ក្នុងករណីនេះ ម៉ាកអាចត្រូវបានលុបចោល[៧]។ ដើម្បីឱ្យច្បាស់និងពិតប្រាកដ ទាក់ទងនឹង

---

[៧] ការបោះពុម្ពផ្សាយរបស់ WIPOលេខ៤៨៩ "កូនសៀវភៅកម្មសិទ្ធិបញ្ញារបស់WIPO"

"ការប្រើប្រាស់ម៉ាកឱ្យបានត្រឹមត្រូវ

"២.៣៩៧ ការមិនប្រើប្រាស់អាចឈានដល់ការបាត់បង់សិទ្ធិលើម៉ាក ហើយការប្រើប្រាស់មិនត្រឹមត្រូវក៏មានលទ្ធផលដូចគ្នាផងដែរ។ ម៉ាកមួយអាចត្រូវបានលុបចេញពីបញ្ជី ប្រសិនបើម្ចាស់ម៉ាកដែលបានចុះបញ្ជីធ្វើការបំលែងឬសម្រួលឱ្យមានការបំលែងទៅជាឈ្មោះទូទៅសម្រាប់ទំនិញឬសេវាកម្មណាមួយទាក់ទងនឹងម៉ាកដែលបានចុះបញ្ជី ដូច្នេះក្នុងចរន្តពាណិជ្ជកម្ម និងក្នុងក្រសែភ្នែកអ្នកប្រើប្រាស់មួយចំនួននិងក្នុងក្រសែភ្នែកសាធារណជនទូទៅ ចំនុចសំខាន់របស់ម៉ាក ត្រូវបានបាត់បង់។

*Continued on next page*

ការដាក់ឈ្មោះពូជដំណាំ អាជ្ញាធរត្រូវបដិសេធន៍ការដាក់ឈ្មោះពូជដំណាំណាដែលដូចនឹងម៉ាកដែលអ្នកបង្កាត់ពូជដំណាំមានសិទ្ធិ។ អ្នកបង្កាត់ពូជដំណាំអាចមានជម្រើសលះបង់ចោលសិទ្ធិលើម៉ាក មុនបញ្ជូនឈ្មោះដែលស្នើ ដើម្បីជៀសវាងការបដិសេធន៍សំណើរបស់ខ្លួន។

---

" ២.៣៩៨ ជាមូលដ្ឋាន កត្តា២(ពីរ)អាចបណ្តាលឱ្យក្លាយជាពាក្យទូទៅ: ពោលគឺ ការប្រើប្រាស់មិនត្រឹមត្រូវដោយម្ចាស់ធ្វើការបំលែងម៉ាកទៅជាពាក្យទូទៅ និង ការប្រើប្រាស់មិនត្រឹមត្រូវដោយភាគីទីបីដែលម្ចាស់ទទួលយក។[...]

"២.៤០០ វិធានជាមូលដ្ឋានគឺថា ម៉ាក មិនត្រូវប្រើប្រាស់ ជាឬជំនួសការកំណត់ផលិតផល។[...]

"២.៤០៤ ប៉ុន្តែបើគ្រាន់តែគោរពតាមវិធានទាំងនេះមិនគ្រប់គ្រាន់ទេ:ម្ចាស់ម៉ាកត្រូវធានាផងដែរថាភាគីទីបីនិងសាធារណជនមិនប្រើប្រាស់ម៉ាករបស់ខ្លួនខុស។ វាមានសារៈសំខាន់ណាស់ថា ម៉ាកមិនត្រូវបានប្រើប្រាស់ជាឬជំនួសឱ្យការពិព័ណ៌នាផលិតផលដែលមានក្នុង វចនានុក្រម ការបោះពុម្ពផ្សាយជាផ្លូវការ ព្រឹត្តិប័ត្រ។ល។"

## មាត្រា២០(២)

(២) [ចរិតលក្ខណៈនៃការដាក់ឈ្មោះ] ការដាក់ឈ្មោះត្រូវតែអាចសម្គាល់ពូជដំណាំបាន។ការដាក់ឈ្មោះមិនត្រូវមានសញ្ញាតែមួយ លើកលែងតែសញ្ញានេះជា ការអនុវត្តន៍ពីមុន ក្នុងការកំណត់ពូជដំណាំ។ ការដាក់ឈ្មោះមិនត្រូវនាំឱ្យយល់ខុសឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជដំណាំ ឡើយ។ ជាពិសេសការដាក់ឈ្មោះត្រូវខុសពី រាល់ការដាក់ឈ្មោះលើពូជដំណាំដែលមានរួចហើយ ក្នុងប្រភេទពូជដំណាំតែមួយឬក្នុងប្រភេទដែលទាក់ទងជិតស្និទ្ធក្នុងដែនដីសមាជិកណាមួយនៃសហភាព។

២.១ អត្តសញ្ញាណ

បទប្បញ្ញត្តិតាមកថាខណ្ឌ(២) បញ្ជាក់ពីតួនាទី “អត្តសញ្ញាណ” នៃការដាក់ឈ្មោះ។ ត្រូវចាំថា កម្មវត្ថុចំបងនៃការដាក់ឈ្មោះ គឺដើម្បីកំណត់អត្តសញ្ញាណពូជដំណាំ។ គួរផ្តល់ឱ្យមានភាពដែលអាចបត់បែនបានក្នុងកម្រិតសមរម្យ ដើម្បីបញ្ចូលជាការអនុវត្តន៍នានាក្នុងការកំណត់ពូជដំណាំ។

២.២ សញ្ញាតែមួយ

២.២.១ កថាខណ្ឌ(២) ចែងថា ការដាក់ឈ្មោះ មិនត្រូវមានសញ្ញាតែមួយ លើកលែងតែសញ្ញានេះ ជាការអនុវត្តន៍ពីមុន ក្នុងការកំណត់ពូជដំណាំ។ ពាក្យ “សញ្ញាតែមួយ” យោងទៅការដាក់ឈ្មោះពូជដំណាំដែលមានតែលេខប៉ុណ្ណោះ(ដូចជា៩១១៥០)។ ដូចនេះការដាក់ឈ្មោះដែលមានទាំងអក្សរនិងតួលេខ មិនមែនជាកម្មវត្ថុនៃលក្ខខណ្ឌ “ការអនុវត្តន៍ពីមុន” ទេ ( ដូចជាAX៣៥០)។

២.២.២ ក្នុងករណីនៃការដាក់ឈ្មោះដែលមាន “សញ្ញាតែមួយ” ធាតុដែលមិនកំណត់ត្រឹមហ្នឹងដូចខាងក្រោម អាចជួយឱ្យអាជ្ញាធរទាំងឡាយ យល់ពីអ្វីដែលអាចចាត់ទុកជា “ការអនុវត្តន៍ពីមុន”:

(ក) ចំពោះពូជដំណាំដែលត្រូវបានប្រើប្រាស់ក្នុងមជ្ឈដ្ឋានអ្នកជំនាញដែលមានកម្រិតការអនុវត្តន៍ពីមុន គួរឆ្លុះបញ្ចាំងមជ្ឈដ្ឋានអ្នកជំនាញនោះ( ដូចជាស្រឡាយចេញពីពូជតែមួយ)

(ខ) ការអនុវត្តន៍លើទីផ្សារដែលបានទទួលយក ចំពោះប្រភេទពូជដំណាំជាក់លាក់

ណាមួយ(ដូចជា ពូជបង្កាត់ទំនើប(Hybrids)) និងប្រភេទជាក់លាក់ណាមួយ ( ដូចជាប្រភេទ Medicago,Helianthus)។

២.៣ នាំឱ្យយល់ខុសឬ បណ្ដាលឱ្យភ័ន្តច្រឡំ

កថាខណ្ឌ(២) ចែងថា ការដាក់ឈ្មោះមិត្រូវនាំឱ្យ “យល់ខុស ឬបណ្ដាលឱ្យភ័ន្តច្រឡំទៅនឹង ចរិតលក្ខណៈ តម្លៃ ឬអត្តសញ្ញាពូជដំណាំ ឬអត្តសញ្ញាណអ្នកបង្កាត់ពូជដំណាំឡើយ”។ ទិដ្ឋភាពទាំងនេះ ត្រូវបានពិចារណាដូចខាងក្រោម។

២.៣.១ ចរិតលក្ខណៈពូជដំណាំ

ការដាក់ឈ្មោះ មិនគួរៈ

(ក) បង្ហាញឱ្យឃើញថា ពូជដំណាំមានចរិតលក្ខណៈពិសេស ដែលភាពពិត ពូជដំណាំគ្មានចរិតលក្ខណៈនេះឡើយ

ឧទាហរណ៍: ការដាក់ឈ្មោះពូជដំណាំមួយថា "តឿ" ចំពោះពូជដំណាំដែលមានកំពស់ធម្មតា នៅពេលដែលលក្ខណៈតឿមានក្នុងប្រភេទពូជ ប៉ុន្តែមិនជារបស់ពូជដំណាំនេះ។

(ខ) យោងតាមចរិតលក្ខណៈជាក់លាក់នៃពូជដំណាំ ក្នុងរបៀបមួយដែលធ្វើឱ្យយល់ថាមានតែពូជដំណាំនេះទេដែលមានចរិតលក្ខណៈទាំងនេះ ប៉ុន្តែតាមការពិត ពូជដំណាំផ្សេងទៀតក្នុងប្រភេទពូជនេះ ក៏មានឬអាចមានចរិតលក្ខណៈដូចគ្នា។ ជាឧទាហរណ៍ នៅពេលដែលការដាក់ឈ្មោះមានតែពាក្យពិព័ណ៌នា ដែលពិព័ណ៌នាពីលក្ខណៈពូជដំណាំដែលពូជដំណាំផ្សេងទៀតក្នុងប្រភេទពូជ ក៏មានផងដែរ

ឧទាហរណ៍ទី១: ដាក់ឈ្មោះថា "ផ្អែម" ចំពោះពូជដំណាំផ្លែឈើ។

ឧទាហរណ៍ទី២: ដាក់ឈ្មោះថា "ធំពណ៌ស" ចំពោះពូជដំណាំផ្កាមួយប្រភេទ។

(គ) ធ្វើឱ្យយល់ថា ពូជដំណាំមានស្រឡាយពី ឬ ទាក់ទងនឹងពូជដំណាំផ្សេងទៀត តែតាមការពិតមិនមែនសោះ។

ឧទាហរណ៍: ការដាក់ឈ្មោះដែលប្រហាក់ប្រហែលពូជដំណាំផ្សេងទៀតក្នុងប្រភេទតែមួយ ឬ ទាក់ទងយ៉ាងជិតស្និទ្ធនឹងប្រភេទនេះ ដូចជា " Southern cross 1" "Southern cross 2" ។ល។ ដែលធ្វើឱ្យយល់ថា ពូជដំណាំទាំងនេះ ជាស៊េរីនៃពូជដំណាំដែលទាក់ទងគ្នា រួមនឹងចរិតលក្ខណៈប្រហាក់ប្រហែលគ្នា តែតាមការពិត មិនដូច្នេះទេ។

២.៣.២ តម្លៃនៃពូជដំណាំ

ការដាក់ឈ្មោះមិនត្រូវមានការកំណត់លក្ខណៈប្រៀបធៀបខ្ពស់ជាងឬខ្ពស់បំផុតឡើយ។

ឧទាហរណ៍: ការដាក់ឈ្មោះដែលរួមមានពាក្យដូចជា "ល្អបំផុត" "ដែលលើសគេ" "ផ្អែមជាង"។

២.៣.៣ អត្តសញ្ញាណពូជដំណាំ

(ក) ជាអនុសាសន៍ទូទៅ ភាពខុសគ្នាតែមួយតួអក្សរឬមួយលេខ អាចត្រូវបានចាត់ទុកថាអាចនាំឱ្យយល់ខុស ឬបណ្តាលឱ្យភ័ន្តច្រឡំទៅនឹងអត្តសញ្ញាណពូជដំណាំ លើកលែងតែនៅពេលដែល:

(i) ភាពខុសគ្នានៃតួអក្សរមួយ បង្ហាញឱ្យឃើញភាពខុសគ្នាច្បាស់ផ្នែកចក្ខុ ឬសំលេង ដូចជា ប្រសិនបើភាពខុសគ្នាពាក់ព័ន្ធនឹងតួអក្សរនៅដើមពាក្យ ឧទាហរណ៍ ទី១: ក្នុងភាសាអង់គ្លេស ពាក្យ Harry និង Larry មិនអាចបណ្តាលឱ្យច្រឡំគ្នាឡើយ។ ប៉ុន្តែ ពាក្យ Bough និង Bow អាចបណ្តាលឱ្យច្រឡំគ្នា (សំលេង)។ ឧទាហរណ៍ទី២: ក្នុងភាសាជប៉ុននិងកូរ៉េ គ្មានខុសគ្នារវាងសំលេង “L” និង “R” ដូចនេះ ពាក្យ “Lion” និង“Raion” ពិតជាដូចគ្នា ទោះបីពាក្យទាំងនេះ ខុសគ្នាសម្រាប់អ្នកមានភាសាអង់គ្លេសជាភាសាកំណើតក៏ដោយ

(ii) ការដាក់ឈ្មោះរួមមានបង្គុំនៃអក្សរនិងតួលេខ

(iii) ការដាក់ឈ្មោះ “មានសញ្ញាតែមួយ”។

(ខ) ការប្រើប្រាស់ការដាក់ឈ្មោះដែលប្រហាក់ប្រហែលគ្នានឹងការប្រើប្រាស់ចំពោះប្រភេទឬអំបូរ ពូជដំណាំផ្សេងទៀត ក្នុងចំណាត់ថ្នាក់ឈ្មោះតែមួយ( សូមមើល ផ្នែក២.៥) អាចបណ្តាលឱ្យភ័ន្តច្រឡំ។

(គ) ដើម្បីឱ្យច្បាស់និងពិតប្រាកដទាក់ទងនឹងការដាក់ឈ្មោះពូជដំណាំ ការប្រើប្រាស់ឡើងវិញនៃការដាក់ឈ្មោះ ជាទូទៅ មិនត្រូវបានជម្រុញ ដោយសារ ការប្រើប្រាស់ឡើងវិញនៃការដាក់ឈ្មោះ ទោះបីជាទាក់ទងនឹងពូជដំណាំដែលលែងមានក៏ដោយ (មើលផ្នែក ២.៤.២) ក៏អាចបណ្តាលឱ្យភ័ន្តច្រឡំដែរ។ ក្នុងករណីកម្រិតមួយចំនួន ការលើកលែងអាចទទួលយកបាន ដូចជាពូជដំណាំមួយដែលមិនដែលធ្វើពាណិជ្ជកម្ម ឬធ្វើពាណិជ្ជកម្មតែក្នុងរបៀបកម្រិតមួយសម្រាប់រយ:ពេលខ្លីបំផុត។ ក្នុងករណីទាំងនេះ រយ:ពេលសមរម្យបន្ទាប់ពីឈប់ធ្វើពាណិជ្ជកម្មពូជដំណាំ អាចតម្រូវមុនការប្រើប្រាស់ឡើងវិញនៃការដាក់ឈ្មោះដើម្បីជៀសវាងការភ័ន្តច្រឡំទៅនឹងអត្តសញ្ញាណនិង/ឬ ចរិតលក្ខណៈពូជដំណាំ។

២.៣.៤ អត្តសញ្ញាណអ្នកបង្កាត់ពូជដំណាំ

ការដាក់ឈ្មោះពូជដំណាំ មិនត្រូវនាំឱ្យយល់ខុសឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងអត្ត

សញ្ញាណអ្នកបង្កាត់ពូជដំណាំ។

២.៤ ខុសពីពូជដំណាំដែលមានស្រាប់ក្នុងប្រភេទពូជដំណាំតែមួយ ឬ ក្នុងប្រភេទពូជដែលទាក់ទងគ្នាយ៉ាងជិតស្និទ្ធ

២.៤.១ កថាខណ្ឌ(២) ចែងថា ការដាក់ឈ្មោះ ត្រូវខុសពីរាល់ការដាក់ឈ្មោះលើពូជដំណាំដែលមានរួចហើយ ក្នុងប្រភេទពូជដំណាំតែមួយឬក្នុងប្រភេទពូជដែលទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។

២.៤.២ ការពន្យល់ខាងក្រោម សម្រាប់គោលបំណងនៃការដាក់ឈ្មោះពូជដំណាំ ហើយដោយមិនធ្វើឱ្យប៉ះពាល់ដល់អត្ថន័យនៃ “ពូជដំណាំដែលគេស្គាល់ជាទូទៅ” ក្នុងមាត្រា៧នៃច្បាប់ឆ្នាំ១៩៩១។ ជាទូទៅ ការប្រើប្រាស់ឡើងវិញនៃការដាក់ឈ្មោះ មិនត្រូវបានជម្រុញប៉ុន្តែក្នុងកាលៈទេសៈដែលមិនអាចជៀសវាងបាន(សូមមើលផ្នែក២.៣.៣(គ)) ការដាក់ឈ្មោះពូជដំណាំចាស់ អាច ជាគោលការណ៍ ត្រូវបានចុះបញ្ជីសម្រាប់ពូជដំណាំថ្មី។

២.៥ ចំណាត់ថ្នាក់ការដាក់ឈ្មោះពូជដំណាំ: ការដាក់ឈ្មោះពូជដំណាំមួយ មិនគួរត្រូវបានប្រើប្រាស់ច្រើនជាងម្តងក្នុងចំណាត់ថ្នាក់តែមួយ

២.៥.១ សម្រាប់គោលបំណងនៃការផ្តល់មគ្គុទ្ទេសក៍លើឃ្លាទី៣(សូមមើលផ្នែក២.៣.៣(ខ)) និងឃ្លាទី៤ កថាខណ្ឌ២នៃមាត្រា២០នៃច្បាប់ឆ្នាំ១៩៩១ ចំណាត់ថ្នាក់ការដាក់ឈ្មោះពូជដំណាំ ត្រូវបានបង្កើតឡើង។ ការដាក់ឈ្មោះពូជដំណាំមិនគួរត្រូវបានប្រើប្រាស់ច្រើនជាងម្តងក្នុងចំណាត់ថ្នាក់តែមួយ។ ចំណាត់ថ្នាក់ទាំងឡាយត្រូវបានបង្កើតឡើងបែបនោះដើម្បីឱ្យប្រភេទរុក្ខជាតិក្នុងចំណាត់ថ្នាក់តែមួយត្រូវបានចាត់ទុកថាទាក់ទងជិតស្និទ្ធនិង/ឬ នាំឱ្យយល់ខុសឬបណ្តាលឱ្យភ័ន្តច្រឡំទៅនឹងអត្តសញ្ញាណពូជដំណាំ។

២.៥.២ ជាអនុសាសន៍ ប្រព័ន្ធទិន្នន័យពូជដំណាំយូប៉ូវ (“UPOV-ROM”) គួរត្រូវបានប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ ប្រសិនបើ ក្នុងដែនដីសមាជិកណាមួយនៃសហភាព ការដាក់ឈ្មោះដែលបានស្នើ ខុសពីការដាក់ឈ្មោះពូជដំណាំដែលមានស្រាប់នៃអំបូរតែមួយ ឬប្រសិនបើសមរម្យ ខុសពីចំណាត់ថ្នាក់ការដាក់ឈ្មោះពូជដំណាំ(សូមមើល កំណត់ពន្យល់-មាត្រា២០(២)បញ្ជីចំណាត់ថ្នាក់)។ ត្រូវយកចិត្តទុកដាក់ចំពោះ កំណត់សម្គាល់ទូទៅនិងការ

បដិសេធន៍នៃ UPOV-ROM ដើម្បីធានាថា ព័ត៌មានដែលមានក្នុង UPOV-ROM ត្រូវបាន ពិចារណាតាមវិធីសមរម្យ។

[ចំណាត់ថ្នាក់នៃការដាក់ឈ្មោះរបស់យូប៉ូវមានដូចខាងក្រោម]

## ចំណាត់ថ្នាក់ការដាក់ឈ្មោះពូជដំណាំយូប៉ូវៈ ការដាក់ឈ្មោះពូជដំណាំមួយ មិនគួរត្រូវបាន ប្រើប្រាស់ច្រើនជាងម្តងក្នុងចំណាត់ថ្នាក់តែមួយ

សម្រាប់គោលបំណងនៃការផ្តល់មគ្គុទ្ទេសក៍ លើឃ្លាទី៣និងទី៤នៃកថាខណ្ឌ២នៃមាត្រា២០ ច្បាប់ឆ្នាំ១៩៩១ ចំណាត់ថ្នាក់ការដាក់ឈ្មោះពូជដំណាំ ត្រូវបានបង្កើតឡើង។ ការដាក់ឈ្មោះពូជដំណាំមួយ មិនគួរត្រូវបានប្រើប្រាស់ច្រើនជាងម្តងក្នុងចំណាត់ថ្នាក់តែមួយ។ ចំណាត់ថ្នាក់ទាំងឡាយ ត្រូវបានបង្កើតឡើងបែបនោះ ដើម្បីឱ្យប្រភេទរុក្ខជាតិក្នុងចំណាត់ថ្នាក់តែមួយត្រូវបានចាត់ទុកថាទាក់ទងជិតស្និទ្ធនិង/ឬ នាំឱ្យយល់ខុសឬបណ្តាលឱ្យភ័ន្តច្រឡំទៅនឹងអត្តសញ្ញាណពូជដំណាំ។

ចំណាត់ថ្នាក់នានានៃការដាក់ឈ្មោះពូជដំណាំ មានដូចខាងក្រោមៈ

(ក) វិធានទូទៅ(អំបូរមួយ/ថ្នាក់មួយ)ៈ ចំពោះអំបូរនិងប្រភេទពូជដែលមិនស្ថិតក្រោមបញ្ជីចំណាត់ថ្នាក់ខាងក្រោម អំបូរមួយត្រូវបានចាត់ទុកថាជាថ្នាក់មួយ

(ខ) ការលើកលែងចំពោះវិធានទូទៅ (បញ្ជីចំណាត់ថ្នាក់)ៈ

(i) ថ្នាក់នានាក្នុងអំបូរមួយៈ បញ្ជីចំណាត់ថ្នាក់ៈ ផ្នែកទី១

(ii) ថ្នាក់នានាដែលមានច្រើនជាងមួយអំបូរៈ បញ្ជីចំណាត់ថ្នាក់ៈផ្នែកទី២។

### បញ្ជីចំណាត់ថ្នាក់

### ផ្នែកទី១

### ថ្នាក់នានាក្នុងអំបូរមួយ

| | ឈ្មោះរុក្ខជាតិ | លេខកូដយូប៉ូវ |
|---|---|---|
| ថ្នាក់១.១ | Brassica oleracea | BRASS_OLE |
| ថ្នាក់១.២ | Brassica ក្រៅពី Brassica oleracea | ក្រៅពី BRASS_OLE |
| ថ្នាក់២.១ | Beta vulgaris L. var. alba DC.,<br>Beta vulgaris L. var. altissima | BETAA_VUL_GVA;<br>BETAA_VUL_GVS |
| ថ្នាក់២.២ | Beta vulgaris ssp. vulgaris var. conditiva Alef. (syn.: B. vulgaris L. var. rubra L.), B. vulgaris L. var. cicla L., B. vulgaris L. ssp. vulgaris var. vulgaris | BETAA_VUL_GVC;<br>BETAA_VUL_GVF |

| | ឈ្មោះរុក្ខជាតិ | លេខកូដយូប៉ូវ |
|---|---|---|

| | | |
|---|---|---|
| ថ្នាក់២.៣ | Beta ក្រៅពីថ្នាក់២.១និង២.២ | ក្រៅពីថ្នាក់២.១និង២.២ |

| | | |
|---|---|---|
| ថ្នាក់៣.១ | Cucumis sativus | CUCUM_SAT |
| ថ្នាក់៣.២ | Cucumis melo | CUCUM_MEL |
| ថ្នាក់៣.៣ | Cucumis ក្រៅពី ថ្នាក់៣.១និង៣.២ | ក្រៅពីថ្នាក់៣.១និង៣.២ |

| | | |
|---|---|---|
| ថ្នាក់៤.១ | Solanum tuberosum L. | SOLAN_TUB |
| ថ្នាក់៤.២ | Tomato & Tomato rootstocks | |
| | Solanum lycopersicum L.<br>(synonym: Lycopersicon esculentum Mill.) | SOLAN_LYC |
| | Solanum cheesmaniae (L. Ridley) Fosberg<br>(Lycopersicon cheesmaniae L. Riley) | SOLAN_CHE |
| | Solanum chilense (Dunal) Reiche<br>(Lycopersicon chilense Dunal) | SOLAN_CHI |
| | Solanum chmielewskii (C.M. Rick et al.) D.M. Spooner et al.<br>(Lycopersicon chmielewskii C. M. Rick et al.) | SOLAN_CHM |
| | Solanum galapagense S.C. Darwin & Peralta<br>(Lycopersicon cheesmaniae f. minor (Hook. f.) C. H. Müll.)<br>(Lycopersicon cheesmaniae var. minor (Hook. f.) D. M. Porter) | SOLAN_GAL |
| | Solanum habrochaites S. Knapp & D.M. Spooner<br>(Lycopersicon agrimoniifolium Dunal)<br>(Lycopersicon hirsutum Dunal)<br>(Lycopersicon hirsutum f. glabratum C. H. Müll.) | SOLAN_HAB |
| | Solanum pennellii Correll<br>(Lycopersicon pennellii (Correll) D'Arcy) | SOLAN_PEN |
| | Solanum peruvianum L.<br>(Lycopersicon dentatum Dunal)<br>(Lycopersicon peruvianum (L.) Mill.) | SOLAN_PER |
| | Solanum pimpinellifolium L.<br>(Lycopersicon pimpinellifolium (L.) Mill.)<br>(Lycopersicon racemigerum Lange) | SOLAN_PIM |
| | និងពូជបង្កាត់ទំនើបរវាងប្រភេទពូជទាំងនេះ | |
| ថ្នាក់៤.៣ | Solanum melongena L. | SOLAN_MEL |

| | ឈ្មោះរុក្ខជាតិ | លេខកូដយូប៉ូវ |
|---|---|---|
| ថ្នាក់៤.៤ | Solanum ក្រៅពីថ្នាក់៤.១ ៤.២ និង ៤.៣ | ក្រៅពីថ្នាក់៤.១ ៤.២ និង ៤.៣ |

## បញ្ជីចំណាត់ថ្នាក់(បន្ត)

## ផ្នែកទី២

## ថ្នាក់នានាដែលមានច្រើនជាងមួយអំបូរ

| | ឈ្មោះរុក្ខជាតិ | លេខកូដយូប៉ូវ |
|---|---|---|
| ថ្នាក់២០១ | Secale, Triticale, Triticum | SECAL; TRITL; TRITI |
| ថ្នាក់២០២ | Megathyrsus, Panicum, Setaria, Steinchisma | MEGAT; PANIC; SETAR; STEIN |
| ថ្នាក់២០៣* | Agrostis, Dactylis, Festuca, Festulolium, Lolium, Phalaris, Phleum and Poa | AGROS; DCTLS; FESTU; FESTL; LOLIU; PHALR; PHLEU; POAAA |
| ថ្នាក២០៤* | Lotus, Medicago, Ornithopus, Onobrychis, Trifolium | LOTUS; MEDIC; ORNTP; ONOBR; TRFOL |
| ថ្នាក់២០៥ | Cichorium, Lactuca | CICHO; LACTU |
| ថ្នាក់២០៦ | Petunia and Calibrachoa | PETUN; CALIB |
| ថ្នាក់២០៧ | Chrysanthemum and Ajania | CHRYS; AJANI |
| ថ្នាក់២០៨ | (Statice) Goniolimon, Limonium, Psylliostachys | GONIO; LIMON; PSYLL |
| ថ្នាក់២០៩ | (Waxflower) Chamelaucium, Verticordia | CHMLC; VERTI; VECHM |
| ថ្នាក់២១០ | Jamesbrittania and Sutera | JAMES; SUTER |

* ថ្នាក២០៣និង២០៤ មិនត្រូវបានបង្កើតឡើងតែលើមូលដ្ឋាននៃប្រភេទដែលទាក់ទងជិតស្និទ្ធិនោះទេ។

| | | |
|---|---|---|
| ថ្នាក់២១១ | (Mushrooms) | |
| | Agaricus | AGARI |
| | Agrocybe | AGROC |
| | Auricularia | AURIC |
| | Dictyophora | DICTP |
| | Flammulina | FLAMM |
| | Ganoderma | GANOD |
| | Grifola | GRIFO |
| | Hericium | HERIC |
| | Hypsizigus | HYPSI |
| | Lentinula | LENTI |
| | Lepista | LEPIS |
| | Lyophyllum | LYOPH |
| | Meripilus | MERIP |
| | Mycoleptodonoides | MYCOL |
| | Naematoloma | NAEMA |
| | Panellus | PANEL |
| | Pholiota | PHLIO |
| | Pleurotus | PLEUR |
| | Polyporus | POLYO |
| | Sparassis | SPARA |
| | Tricholoma | MACRO |
| ថ្នាក់២១២ | Verbena L. and Glandularia J. F. Gmel. | VERBE; GLAND |

### មាត្រា២០(៣)

(៣) [ការចុះបញ្ជីការដាក់ឈ្មោះ] ការដាក់ឈ្មោះពូជដំណាំត្រូវស្នើដោយអ្នកបង្កាត់ពូជដំណាំទៅអាជ្ញាធរ។ ប្រសិនបើអាជ្ញាធររកឃើញថាការដាក់ឈ្មោះមិនបានបំពេញលក្ខ-ខណ្ឌតម្រូវនៃកថាខណ្ឌទី(២) អាជ្ញាធរត្រូវបដិសេធន៍ការចុះបញ្ជីហើយតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំស្នើការដាក់ឈ្មោះមួយផ្សេងទៀត ក្នុងរយៈពេលកំណត់មួយ។ ការដាក់ឈ្មោះត្រូវចុះបញ្ជីដោយអាជ្ញាធរក្នុងពេលតែមួយស្របគ្នានឹងការផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។

៣.១ ប្រសិនបើ អាជ្ញាធរ រកមិនឃើញមូលហេតុសម្រាប់បដិសេធន៍តាមកថាខណ្ឌ(២) ហើយដឹងថាគ្មានមូលហេតុសម្រាប់បដិសេធន៍តាមកថាខណ្ឌ(៤) ការដាក់ឈ្មោះដែលបានស្នើ ត្រូវចុះបញ្ជី បោះពុម្ពផ្សាយនិង ជូនដំណឹងទៅអាជ្ញាធរនៃសមាជិកផ្សេងទៀតរបស់សហភាព។

៣.២ ក្នុងករណីសិទ្ធិពីមុន(កថាខណ្ឌ(៤)) ឬ មូលហេតុផ្សេងទៀតសម្រាប់បដិសេធន៍ បុគ្គលមានប្រយោជន៍ណាមួយ អាចដាក់ពាក្យជំទាស់ការចុះបញ្ជី។ អាជ្ញាធរនៃសមាជិកផ្សេងទៀតរបស់សហភាព អាចផ្តល់ការសង្កេត( សូមមើលកំណត់ពន្យល់ចំពោះកថាខណ្ឌ(៦))។

៣.៣ ការជំទាស់និងការសង្កេតដែលពាក់ព័ន្ធ គួរត្រូវបានជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំ។អ្នកដាក់ពាក្យស្នើសុំ គួរត្រូវបានផ្តល់ឱកាសដើម្បីឆ្លើយតបទៅនឹងការសង្កេត។ ប្រសិនបើអាជ្ញាធរ ចាត់ទុកថាការដាក់ឈ្មោះមិនសមរម្យក្នុងដែនដីរបស់ខ្លួន អាជ្ញាធរនឹងតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំស្នើការដាក់ឈ្មោះមួយផ្សេងទៀត។ បើមិនបានដាក់សំណើក្នុងរយៈពេលកំណត់ គួរតែបដិសេធន៍ពាក្យស្នើសុំ។

៣.៤ ការត្រួតពិនិត្យការដាក់ឈ្មោះដែលបានស្នើនិងលក្ខខណ្ឌផ្សេងទៀតចំពោះកិច្ចការពារពូជដំណាំ ជានីតិវិធីដែលគួរចាត់ដំណាលគ្នាដើម្បីធានាថា ការដាក់ឈ្មោះអាចត្រូវបានចុះបញ្ជីនៅពេលផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ។

### មាត្រា២០(៤)

(៤) [សិទ្ធិពីមុននៃតតិយជន] សិទ្ធិពីមុននៃតតិយជនមិនត្រូវប៉ះពាល់ឡើយ។ ដោយមូលហេតុនៃសិទ្ធិពីមុន ប្រសិនបើការប្រើប្រាស់ការដាក់ឈ្មោះពូជដំណាំត្រូវហាមឃាត់

ចំពោះបុគ្គលណាមួយដែលតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី(៧) តម្រូវឱ្យប្រើប្រាស់ការដាក់ឈ្មោះនេះ អាជ្ញាធរ ត្រូវតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំស្នើការដាក់ឈ្មោះមួយផ្សេងទៀតសម្រាប់ពូជដំណាំនេះ។

៤. ក្នុងការសម្រេចលើភាពសមរម្យនៃការដាក់ឈ្មោះដែលបានស្នើ និងត្រួតពិនិត្យការជំទាស់និងការសង្កេតទាក់ទងនឹងសិទ្ធិពីមុននៃតតិយជន ចំនុចដូចខាងក្រោម មានចេតនាជួយអាជ្ញាធរទាំងឡាយ។

(ក) អាជ្ញាធរ មិនគួរទទួលយកការដាក់ឈ្មោះពូជដំណាំ ប្រសិនបើ សិទ្ធិពីមុន ដែលការអនុវត្តន៍អាចរារាំងការប្រើប្រាស់ការដាក់ឈ្មោះដែលបានស្នើ ត្រូវបានផ្តល់ឱ្យហើយចំពោះតតិយជនតាមច្បាប់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ម៉ាក ឬច្បាប់កម្មសិទ្ធិបញ្ញាផ្សេងទៀត។ ជាទំនួលខុសត្រូវរបស់ម្ចាស់សិទ្ធិពីមុន ដើម្បីអះអាងសិទ្ធិរបស់ខ្លួនតាមរយៈការជំទាស់ឬនីតិវិធីតុលាការដែលមាន។ ប៉ុន្តែអាជ្ញាធរទាំងឡាយត្រូវបានជម្រុញឱ្យធ្វើការស្រាវជ្រាវជាមុនក្នុងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធ(ដូចជាព្រឹត្តិប័ត្រផ្លូវការ) និងក្នុងប្រព័ន្ធទិន្នន័យ(ដូចជា UPOV-ROM) ដើម្បីកំណត់សិទ្ធិពីមុនចំពោះការដាក់ឈ្មោះពូជដំណាំ។ អាជ្ញាធរក៏អាចធ្វើការស្រាវជ្រាវផងដែរក្នុងបញ្ជីផ្សេងទៀត ដូចជាបញ្ជីម៉ាក មុនទទួលយកការដាក់ឈ្មោះពូជដំណាំ។

(ខ) សញ្ញាណនៃសិទ្ធិពីមុន គួរបញ្ចូលសិទ្ធិណាដែលនៅជាធរមាន ក្នុងដែនដីដែលពាក់ព័ន្ធ នៅពេលបោះពុម្ពផ្សាយការដាក់ឈ្មោះដែលបានស្នើ។ ចំពោះសិទ្ធិដែលមានរយៈពេលចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ កាលបរិច្ឆេទដាក់ពាក្យស្នើសុំគឺកាលបរិច្ឆេទដែលពាក់ព័ន្ធនឹងការពិចារណាសិទ្ធិពីមុន ឱ្យតែពាក្យស្នើសុំទាំងនោះឈានដល់ការទទួលបានសិទ្ធិ។

(គ) ក្នុងករណីមានទំនាស់រវាងការដាក់ឈ្មោះពូជដំណាំពីរ(សូមមើលកថាខណ្ឌ(២)) ក្នុងដែនដីតែមួយឬផ្សេងគ្នា ការដាក់ឈ្មោះដែលមានកាលបរិច្ឆេទបោះពុម្ពផ្សាយមុនគេ គួរត្រូវបានរក្សាទុក ហើយអាជ្ញាធរពាក់ព័ន្ធគួរស្នើឱ្យអ្នកបង្កាត់ពូជដំណាំដាក់ឈ្មោះមួយផ្សេងទៀត។ ការដាក់ឈ្មោះដែលបានស្នើរបស់អ្នកបង្កាត់ពូជដំណាំ ត្រូវបានបោះពុម្ពផ្សាយ ឬអាចត្រូវបានបោះពុម្ពផ្សាយនាកាលបរិច្ឆេទក្រោយ។

(ឃ) បន្ទាប់ពីផ្តល់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ប្រសិនបើរកឃើញថា មានសិទ្ធិពីមុនពាក់ព័ន្ធនឹងការដាក់ឈ្មោះ ដែលអាចនាំឱ្យមានការបដិសេធន៍ការដាក់ឈ្មោះ ការដាក់ឈ្មោះគួរ

ត្រូវបានលុបចោល ហើយ អ្នកបង្កាត់ពូជដំណាំគួរស្នើការដាក់ឈ្មោះពូជដំណាំដែលសមស្របមួយផ្សេងទៀត។ មាត្រា២២(១)(ខ)(iii) នៃច្បាប់ឆ្នាំ១៩៩១ ចែងថា ប្រសិនបើអ្នកបង្កាត់ពូជដំណាំមិនបានស្នើការដាក់ឈ្មោះដែលសមស្របមួយផ្សេងទៀតទេ អាជ្ញាធរអាចលុបចោលសិទ្ធិអ្នកបង្កាត់ពូជដំណាំបាន។

(ង) ចំនុចខាងក្រោម ផ្តល់មគ្គុទ្ទេសក៍មួយចំនួនស្តីពីអ្វីដែលបង្កើតជា "សិទ្ធិពីមុន" ការអនុវត្តន៍ដែលអាចរារាំងការប្រើប្រាស់ការដាក់ឈ្មោះដែលបានស្នើ:

(i) ម៉ាកមួយអាចត្រូវបានចាត់ទុកជាសិទ្ធិពីមុន នៅពេលដែលការដាក់ឈ្មោះដែលបានស្នើដូចគ្នានឹងម៉ាកដែលបានចុះបញ្ជីសម្រាប់ទំនិញដូចគ្នា។ ដើម្បីជាគោលបំណងនៃការអនុវត្តន៍ អត្តសញ្ញាណទំនិញនេះ កើតឡើងភាគច្រើនចំពោះម៉ាកដែលចុះបញ្ជីសម្រាប់ទំនិញក្នុងថ្នាក់៣១នៃចំណាត់ថ្នាក់ទីក្រុងនីស[៨] គួររំលឹកថា ទោះជាក្នុងប្រទេសមួយចំនួន ម៉ាកអាចត្រូវបានការពារផងដែរលើមូលដ្ឋាននៃការប្រើប្រាស់ដោយគ្មានចុះបញ្ជីក៏ដោយ។ ប្រសិនបើម៉ាកនិងការដាក់ឈ្មោះដែលបានស្នើ មិនដូចគ្នា ប៉ុន្តែប្រហាក់ប្រហែលគ្នា ម៉ាក ក្នុងករណីមួយចំនួនអាចបង្កើតសិទ្ធិពីមុន ដែលការអនុវត្តន៍អាចរារាំងការប្រើប្រាស់ការដាក់ឈ្មោះដែលបានស្នើ ហើយអ្នកបង្កាត់ពូជដំណាំអាចតម្រូវឱ្យស្នើការដាក់ឈ្មោះមួយផ្សេងទៀត។ ទោះបីបើមានភាពប្រហាក់ប្រហែលគ្នារវាងការដាក់ឈ្មោះដែលបានស្នើនិងម៉ាក ប្រសិនបើការអនុវត្តម៉ាកនឹងមិនរារាំងការប្រើប្រាស់ឈ្មោះដែលបានស្នើ ការដាក់ឈ្មោះនេះ អាចទទួលយកបាន។ ជាទូទៅការបដិសេធន៍ការដាក់ឈ្មោះ ដោយអាជ្ញាធរលើមូលដ្ឋាននៃភាពប្រហាក់ប្រហែលគ្នានឹងម៉ាក បណ្តាលមកពីការជំទាស់របស់ម្ចាស់ម៉ាក ការសង្កេតរបស់អាជ្ញាធរទទួលខុសត្រូវចុះបញ្ជីម៉ាក ឬ សេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច។ ក្នុងករណីគ្រាន់តែប្រហាក់ប្រហែលគ្នាឬមានភាពដូចគ្នា ដែលនាំឱ្យមានការភ័ន្តច្រឡំតិចតួច ដោយអ្នកប្រើប្រាស់ ការលះបង់ទៅឱ្យអ្នកបង្កាត់ពូជដំណាំដោយម្ចាស់សិទ្ធិម៉ាកពីមុន អាចជាដំណោះស្រាយមួយល្អ។

---

[៨] កិច្ចព្រមព្រៀងទីក្រុងនីសពាក់ព័ន្ធនឹងចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាកម្ម សម្រាប់គោលបំណងចុះបញ្ជីម៉ាក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៥៧ ដែលបានកែប្រែនៅទីក្នុងស្តុកខុល ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៦៧ និង នៅទីក្រុងឡាអេ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ១៩៧៧ និងបានធ្វើវិសោធនកម្ម ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ១៩៧៩។

(ii) ប្រសិនបើការដាក់ឈ្មោះដែលបានស្នើ ដូចនឹងឬប្រហាក់ប្រហែលគ្នានឹងម៉ាកល្បី ការដាក់ឈ្មោះនេះ អាចមិនសមស្រប ទោះបីជាម៉ាកល្បីនេះ អនុវត្តចំពោះទំនិញ ក្រៅពីទំនិញដែលមានក្នុងថ្នាក់៣១នៃចំណាត់ថ្នាក់ទីក្រុងនីស[៩]ក៏ដោយ

(iii) សិទ្ធិពីមុន អាចពាក់ព័ន្ធផងដែរនឹងពាណិជ្ជនាម[១០]និងឈ្មោះបុគ្គលល្បីៗ

(iv) ឈ្មោះនិងអក្សរកាត់នៃអង្គការអន្តររដ្ឋាភិបាល ដែលអនុសញ្ញាអន្តរជាតិមិនអនុញ្ញាតឱ្យប្រើប្រាស់ជាម៉ាកឬផ្នែកនៃម៉ាក មិនសមស្របជាការដាក់ឈ្មោះពូជដំណាំទេ[១១]

(v) សិទ្ធិពីមុនដែលពាក់ព័ន្ធនឹងការហៅតាមប្រភពដើមនិងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ(ដូចជា“Scotch”) អាចមានតាមច្បាប់ជាតិដោយឈរលើមូលដ្ឋាន Common Law ឬដោយការចុះបញ្ជី[១២]

(vi) ក្នុងករណីមួយចំនួន សិទ្ធិពីមុនតាមឈ្មោះទីតាំងភូមិសាស្ត្រ (ដូចជាឈ្មោះទីក្រុង ឬរដ្ឋ) អាចមាន ប៉ុន្តែ គ្មានវិធានទូទៅស្តីពីករណីទាំងនេះឡើយ ហើយការវាយតម្លៃគួរផ្អែកលើលក្ខណៈសាកល្បងតាមករណីនីមួយៗ។

---

[៩] ម៉ាកល្បី ត្រូវបានការពារដោយអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម(មាត្រា៦ស្ទួន) និងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងសិទ្ធិកម្មសិទ្ធិបញ្ញា(មាត្រា១៦.២និង៣ នៃកិច្ចព្រមព្រៀង TRIPS)។ សូមមើលផងដែរ អនុសាសន៍រួមរបស់WIPO ឆ្នាំ១៩៩៩ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីកិច្ចការម៉ាកល្បី។

[១០] មាត្រា៨នៃងអនុសញ្ញាទីក្រុងប៉ារីស

[១១] អនុសាសន៍នេះរួមមានឈ្មោះនិងអក្សរកាត់ដែលបានជូនដំណឹងតាមមាត្រា៦ស្ទួន៣នៃអនុសញ្ញាទីក្រុងប៉ារីស

[១២] មាត្រា២២ដល់មាត្រា២៤នៃកិច្ចព្រមព្រៀងTRIPSចែងពីកាតព្វកិច្ចសមាជិក WTOដើម្បីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ កិច្ចព្រមព្រៀងលីសបោនស្តីពីកិច្ចការពារការហៅតាមប្រភពដើមនិងការចុះបញ្ជីអន្តរជាតិ បង្កើតនីតិវិធីចុះបញ្ជីអន្តរជាតិចំពោះការហៅតាមប្រភពដើម ក្នុងរដ្ឋដែលជាភាគីកិច្ចព្រមព្រៀងនេះ។

## ត្រា២០(៥)

(៥) [ការដាក់ឈ្មោះដូចគ្នាក្នុងសមាជិកទាំងអស់នៃសហភាព] ពូជដំណាំមួយត្រូវបញ្ជូនទៅសមាជិកទាំងអស់នៃសហភាពក្រោមការដាក់ឈ្មោះតែមួយ។ អាជ្ញាធរនៃសមាជិកនីមួយៗរបស់សហភាពត្រូវចុះបញ្ជីការដាក់ឈ្មោះដែលបានបញ្ជូនមក លើកលែងតែយល់ថាការដាក់ឈ្មោះនេះមិនសមស្របក្នុងដែនដីរបស់ខ្លួន។ ក្នុងករណីនេះតម្រូវឱ្យអ្នកបង្កាត់ពូជដំណាំផ្តល់ការដាក់ឈ្មោះមួយផ្សេងទៀត។

៥.១ បទប្បញ្ញត្តិនេះ ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការដាក់ឈ្មោះពូជដំណាំតែមួយសម្រាប់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធយូប៉ូវ។

៥.២ កថាខណ្ឌ(៥) ផ្តល់ការណែនាំច្បាស់លាស់ទាំងសម្រាប់អ្នកបង្កាត់ពូជដំណាំនិងអាជ្ញាធរៈ

(ក) ទាក់ទងនឹងពាក្យស្នើសុំបន្ទាប់នៃពូជដំណាំតែមួយ អ្នកបង្កាត់ពូជដំណាំត្រូវបញ្ជូនទៅសមាជិកទាំងអស់នៃសហភាពនូវការដាក់ឈ្មោះ ដែលត្រូវបានបញ្ជូនជាមួយពាក្យស្នើសុំដំបូង។ ការលើកលែងចំពោះកាតព្វកិច្ចខាងលើ អាចសមស្របនៅពេលដែលការដាក់ឈ្មោះដែលបានស្នើ ត្រូវបានបដិសេធន៍ដោយអាជ្ញាធរមួយ មុនការដាក់ឈ្មោះត្រូវបានចុះបញ្ជីដោយសមាជិកផ្សេងទៀតណាមួយនៃសហភាព។ ក្នុងករណីនេះ អ្នកបង្កាត់ពូជដំណាំត្រូវបានលើកទឹកចិត្តឱ្យស្នើការដាក់ឈ្មោះថ្មី ទៅអាជ្ញាធរទាំងអស់ដើម្បីទទួលបាន ការដាក់ឈ្មោះតែមួយក្នុងដែនដីទាំងអស់។

(ខ) កាតព្វកិច្ចសំខាន់តាមកថាខណ្ឌ(៥) គឺថាអាជ្ញាធរគួរទទួលយកការដាក់ឈ្មោះដែលត្រូវបានបញ្ជូននិងចុះបញ្ជីជាមួយពាក្យស្នើសុំដំបូង លើកលែងតែការដាក់ឈ្មោះនេះមិនសមរម្យក្នុងដែនដីរបស់ខ្លួន(សូមមើលផ្នែក៥.៣)។ លើមូលដ្ឋាននេះទោះជាបទប្បញ្ញត្តិមួយចំនួនស្តីពីការដាក់ឈ្មោះពូជដំណាំ អនុញ្ញាតឱ្យអាជ្ញាធរបង្កើតមគ្គុទ្ទេសក៍ផ្ទាល់ខ្លួនពាក់ព័ន្ធនឹងការអនុវត្តន៍ពីមុន កាតព្វកិច្ចតាមកថាខណ្ឌ(៥) គួរត្រូវបានផ្តល់អាទិភាព លើកលែងតែ មានទំនាស់ផ្ទាល់ទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញាយូប៉ូវ។ ក្នុងករណីនេះត្រូវផ្តល់អនុសាសន៍ផងដែរដើម្បីជៀសវាងការបកស្រាយចង្អៀតណាមួយ នៃបទប្បញ្ញត្តិអនុសញ្ញាយូប៉ូវនិងទាក់ទងនឹងមគ្គុទ្ទេសក៍ឬការអនុវត្តន៍ពីមុន ដែលអាចនាំឱ្យមានការបដិសេធន៍ដែលមិនចាំបាច់នូវការដាក់ឈ្មោះពូជដំណាំ ហើយជាវិបាកការបង្កើតដែលមិនចាំបាច់នូវសទិសន័យនៃពូជដំណាំ។

(គ) ដោយសារអក្ខរក្រមឬប្រព័ន្ធនៃការសរសេរមានភាពផ្សេងគ្នា អាចជាការចាំបាច់ដើម្បីបកប្រែតាមសំលេងឬកត់ត្រាតាមសំលេង នូវការដាក់ឈ្មោះដែលបានស្នើ ដើម្បីឱ្យមានការចុះបញ្ជីបាននៅក្នុងដែនដីមួយផ្សេងទៀត។ ក្នុងករណីនេះការដាក់ឈ្មោះពូជដំណាំដែលបានបញ្ចូលក្នុងពាក្យស្នើសុំនិងការបកប្រែតាមសំលេង ឬកត់ត្រាតាមសំលេង ត្រូវបានចាត់ទុកថាជាការដាក់ឈ្មោះតែមួយ។ ប៉ុន្តែការបកប្រែមិនគួរចាត់ទុកជាការដាក់ឈ្មោះតែមួយទេ។

៥.៣ ខណៈដែលកម្រិតនៃភាពអាចបត់បែនបានមានលក្ខណៈសមសម្ប បញ្ជីដែលមិនកំណត់ដូចខាងក្រោម អាចជួយអាជ្ញាធរទាំងឡាយក្នុងការសម្រេចថាអ្វីមិនសមម្យ។ ក្នុងដែនដីរបស់ខ្លួន អាជ្ញាធរនៃសមាជិកមួយ អាចបដិសេធន៍ការដាក់ឈ្មោះដែលបានស្នើទោះជាមានការខំប្រឹងយ៉ាងណាក៏ដោយ ប្រសិនបើអាជ្ញាធរបង្ហាញថាៈ

(ក) ការដាក់ឈ្មោះមិនស្របតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌ(២)និង(៤) ឬ

(ខ) ការដាក់ឈ្មោះនេះផ្ទុយនឹងគោលនយោបាយសាធារណៈ។

៥.៤ ដើម្បីអនុញ្ញាតឱ្យមានការធ្វើអត្តសញ្ញាណត្រឹមត្រូវនៃពូជដំណាំដែលបានចុះបញ្ជីដោយមានឈ្មោះផ្សេងគ្នា តាមករណីលើកលែង(សូមមើលផ្នែក៥.៣ខាងលើ) ក្នុងដែនដីផ្សេងគ្នា បញ្ជីសទិសន័យតាមតំបន់ឬអន្តរជាតិ អាចត្រូវបានបង្កើតឡើងដោយ យូប៉ូវ និង/ឬដោយសមាជិកមួយចំនួននៃសហភាព។

៥.៥ ដើម្បីកាត់បន្ថយហានិភ័យនៃការដាក់ឈ្មោះពូជដំណាំដែលត្រូវចាត់ទុកថាមិនសមរម្យក្នុងដែនដីដែលស្នើសុំកិច្ចការពារ សមាជិកនៃសហភាព ត្រូវលើកទឹកចិត្តឱ្យអាជ្ញាធរផ្សេងទៀតនិងអ្នកបង្កាត់ពូជដំណាំរកបាននូវលក្ខណៈវិនិច្ឆ័យ មគ្គុទ្ទេសក៍និងការអនុវត្តន៍ល្អបំផុតដែលខ្លួនអនុវត្តចំពោះការដាក់ឈ្មោះពូជដំណាំ ។ ជាពិសេស អាជ្ញាធរទាំងឡាយ ត្រូវបានលើកទឹកចិត្តឱ្យមានមុខងារស្រាវជ្រាវអេឡិចត្រូនិច ដែលខ្លួនប្រើប្រាស់ក្នុងការត្រួតពិនិត្យការដាក់ឈ្មោះក្នុងទម្រង់មួយ ដែលអាចអនុញ្ញាតឱ្យមានការត្រួតពិនិត្យតាមប្រព័ន្ធអ៊ីនធឺណែតនូវការដាក់ឈ្មោះពូជដំណាំដែលបានស្នើ ទល់នឹងប្រព័ន្ធទិន្នន័យនៃពូជដំណាំដែលពាក់ព័ន្ធ ហើយជាពិសេសប្រព័ន្ធទិន្នន័យពូជដំណាំយូប៉ូវ។ សមាជិកនៃសហភាពក៏អាចផ្តល់សេវាកម្មត្រួតពិនិត្យការដាក់ឈ្មោះពូជដំណាំតាមតម្រូវការផងដែរ។ សមាជិកនៃសហភាពត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់គេហទំព័ររបស់យូប៉ូវដើម្បីផ្តល់ព័ត៌មាននិងការតភ្ជាប់ទៅប្រភពទាំងនេះ។

## មាត្រា២០(៦)

(៦) [ព័ត៌មានរវាងអាជ្ញាធរនៃសមាជិករបស់សហភាព] អាជ្ញាធរនៃសមាជិករបស់សហភាពត្រូវធានាថា អាជ្ញាធរនៃសមាជិផ្សេងទៀតទាំងអស់របស់សហភាព ត្រូវបានជូនដំណឹងពីបញ្ហាពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំ ជាពិសេស ការបញ្ជូល ការចុះបញ្ជី និងការលុបចោលការដាក់ឈ្មោះ។ អាជ្ញាធរណាមួយអាចលើកឡើងអំពីការសង្កេតរបស់ខ្លួនបើមាន លើការចុះបញ្ជីការដាក់ឈ្មោះទៅអាជ្ញាធរដែលបានជូនដំណឹងពីការដាក់ឈ្មោះនេះ ។

៦.១ បទប្បញ្ញត្តិនៃកថាខណ្ឌ(៦) បង្ហាញពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្តូរព័ត៌មានរវាងអាជ្ញាធរ។

៦.២ កាតព្វកិច្ចដើម្បីជូនដំណឹងសមាជិកផ្សេងទៀតនៃសហភាពពីបញ្ហាពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំ ផ្អែកលើការផ្លាស់ប្តូរព្រឹត្តិប័ត្រផ្លូវការនិងមធ្យោបាយផ្សេងទៀតនៃការបោះពុម្ពផ្សាយ។ គួរផ្តល់អនុសាសន៍ថា គំរូនៃព្រឹត្តិប័ត្រផ្លូវការត្រូវផ្អែកលើព្រឹត្តិប័ត្រសិទ្ធិអ្នកបង្កាត់ពូជដំណាំគំរូរបស់យូប៉ូវ( ឯកសារUPOV/INF/5) ជាពិសេស ជំពូកនានាដែលមានព័ត៌មានស្តីពីការដាក់ឈ្មោះពូជដំណាំ គួរត្រូវកំណត់ឱ្យបានសមរម្យក្នុងតារាងមាតិកា។ ប៉ុន្តែ ប្រព័ន្ធទិន្នន័យពូជដំណាំយូប៉ូវ ជាយន្តការដែលមានសារៈសំខាន់ដើម្បីឱ្យមានព័ត៌មានជាអតិបរមាសម្រាប់សមាជិកទាំងឡាយនៃសហភាព ពាក់ព័ន្ធនឹងការដាក់ឈ្មោះពូជដំណាំក្នុងទម្រង់នៃការអនុវត្តន៍។

៦.៣ កថាខណ្ឌ(៦) ចែងពីលទ្ធភាពសម្រាប់សមាជិកនៃសហភាពដើម្បីសង្កេត ប្រសិនបើខ្លួនគិតថា ការដាក់ឈ្មោះដែលបានស្នើក្នុងសមាជិកណាមួយផ្សេងទៀតនៃសហភាព មិនសមរម្យ។ ជាពិសេសចំពោះបទប្បញ្ញត្តិនៃកថាខណ្ឌ(៥) អាជ្ញាធរគួរពិចារណាលើការសង្កេតទាំងអស់ដែលធ្វើដោយអាជ្ញាធរទាំងឡាយនៃសមាជិកផ្សេងទៀត នៅពេលសម្រេចលើភាពសមរម្យនៃការដាក់ឈ្មោះដែលបានស្នើ។ អនុលោមតាមបទប្បញ្ញត្តិស្តីពីការដាក់ឈ្មោះពូជដំណាំតាមអនុសញ្ញាយូប៉ូវ ប្រសិនបើការសង្កេតមាននិយាយអំពីឧបសគ្គក្នុងការទទួលការយល់ព្រមដែលអនុវត្តចំពោះសមាជិកទាំងអស់ ការដាក់ឈ្មោះដែលបានស្នើគួរត្រូវបានបដិសេធន៍។ ប្រសិនបើការសង្កេតនិយាយអំពីឧបសគ្គក្នុងការទទួលការយល់ព្រមតែក្នុងសមាជិកនៃសហភាពដែលបានបញ្ជូនការសង្កេត(ដូចជា សិទ្ធិម៉ាកពីមុនក្នុងដែនដីនេះ) អ្នកដាក់ពាក្យស្នើសុំគួរត្រូវបានជូនដំណឹងអំពីរឿងនេះ។ ប្រសិនបើប្រមើលឃើញថា

កិច្ចការពារនឹងត្រូវអនុវត្តចំពោះ ឬប្រសិនបើអាចរំពឹងថាបំណែកពូជដែលផលិតឡើងវិញឬបំណែកពូជដែលអាចយកទៅដាំដុះបាន នឹងត្រូវធ្វើចរាចរក្នុងដែនដីសមាជិកសហភាពដែលបានបញ្ជូនការសង្កេត អាជ្ញាធរដែលត្រួតពិនិត្យការដាក់ឈ្មោះដែលបានស្នើ គួរស្នើឱ្យអ្នកដាក់ពាក្យស្នើសុំស្នើការដាក់ឈ្មោះមួយផ្សេងទៀត។

៦.៤ អាជ្ញាធរដែលធ្វើការសង្កេត និងអាជ្ញាធរដែលត្រួតពិនិត្យបើធ្វើទៅបាន គួរប្រឹងប្រែងដើម្បីឱ្យមានកិច្ចព្រមព្រៀងស្តីភាពអាចទទួលយកបាននៃការដាក់ឈ្មោះពូជដំណាំ។

៦.៥ គួរផ្តល់អនុសាសន៍ថា សេចក្តីជូនដំណឹងពីសេចក្តីសម្រេចចុងក្រោយត្រូវដាក់ទៅអាជ្ញាធរណាមួយដែលបានបញ្ជូនការសង្កេត។

៦.៦ អាជ្ញាធរទាំងឡាយត្រូវបានលើកទឹកចិត្ត ឱ្យផ្ញើព័ត៌មានស្តីពីការដាក់ឈ្មោះពូជដំណាំទៅអាជ្ញាធរដែលពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិផ្សេងទៀត(ដូចជា អាជ្ញាធរទទួលខុសត្រូវចុះបញ្ជីម៉ាក)។

៦.៧ ទម្រង់គំរូសម្រាប់សង្កេតលើការដាក់ឈ្មោះដែលបានស្នើ ដាក់ក្នុងសមាជិកមួយផ្សេងទៀតនៃសហភាព អាចឃើញក្នុងកំណាត់-មាត្រា២០(៦) ទម្រង់គំរូសម្រាប់ការសង្កេត។ ទម្រង់គំរូសម្រាប់ឆ្លើយតបចំពោះការសង្កេត អាចឃើញក្នុង កំណាត់-មាត្រា២០(៦) គំរូឆ្លើយតបចំពោះការសង្កេត។ ច្បាប់ចម្លងនៃសេចក្តីជូនដំណឹងទាំងនេះ គួរត្រូវបានផ្ញើនៅពេលជាមួយគ្នា ទៅអាជ្ញាធរនៃសមាជិកផ្សេងទៀតរបស់សហភាព។

["ទម្រង់គំរូសម្រាប់ការសង្កេតលើការដាក់ឈ្មោះពូជដំណាំ ដែល
បានស្នើ ដាក់ទៅសមាជិកមួយផ្សេងទៀត
នៃសហភាព" មានដូចខាងក្រោម]

ទម្រង់គំរូសម្រាប់ការសង្កេតលើការដាក់ឈ្មោះពូជដំណាំដែលបានស្នើ
ដែលបានដាក់ទៅសមាជិកមួយផ្សេងទៀតនៃសហភាព

ពី:

______________________________
ការយោងរបស់អ្នក

______________________________
ការយោងរបស់យើង

**ការសង្កេតលើការដាក់ឈ្មោះពូជដំណាំដែលបានដាក់**

ទៅ:

ការដាក់ឈ្មោះពូជដំណាំដែលបានដាក់: ______________________________

អំបូរ/ប្រភេទ(ឈ្មោះរុក្ខជាតិ): ______________________ លេខកូដយូប៉ូវ: __________

ព្រឹត្តិប័ត្រ: ______________________________________________

(លេខ/ឆ្នាំ)

អ្នកដាក់ពាក្យស្នើសុំ: ______________________________________

ការសង្កេត: ____________________________________________

______________________________________________________

______________________________________________________

______________________________________________________

ប្រសិនបើការសង្កេត យោងទៅម៉ាកឬសិទ្ធិមួយផ្សេងទៀត ឈ្មោះនិងអាសយដ្ឋានម្ចាស់សិទ្ធិនោះ(ប្រសិនបើមាន):

______________________________________________________

______________________________________________________

______________________________________________________

ច្បាប់ចម្លងផ្ញើទៅអាជ្ញាធរនៃសមាជិកផ្សេងទៀតរបស់សហភាព

កាលបរិច្ឆេទ: __________________ ហត្ថលេខា:______________________________

[“គំរូឆ្លើយតបចំពោះការសង្កេតលើការដាក់ឈ្មោះពូជដំណាំ ដែល
បានស្នើ ដាក់ទៅសមាជិកមួយផ្សេងទៀត
នៃសហភាព” មានដូចខាងក្រោម]

គំរូឆ្លើយតបចំពោះការសង្កេតលើការដាក់ឈ្មោះពូជដំណាំដែលបានស្នើ ដាក់ទៅសមាជិកមួយផ្សេងទៀតនៃសហភាព

ពី:

_______________________

ការយោងរបស់អ្នក

_______________________

ការយោងរបស់យើង

**ការឆ្លើយតបចំពោះការសង្កេតលើការដាក់ឈ្មោះពូជដំណាំដែលបានដាក់**

ទៅ:

ឆ្លើយតបនឹងការជំទាស់របស់អ្នកចំពោះការដាក់ឈ្មោះ[......................] ពូជដំណាំនៃ[ឈ្មោះរុក្ខជាតិ/លេខកូដយូប៉ូវ] យើងចង់ជូនដំណឹងទៅអ្នកថា:

១. ☐ តាមយោបល់របស់យើង មានលក្ខណៈខុសគ្នាគ្រប់គ្រាន់រវាងឈ្មោះ...................... និង.................................ទាំងក្នុងការសរសេរនិងការបញ្ចេញសំលេង។ ដូច្នេះ [អាជ្ញាធរ] គ្មានមូលហេតុបដិសេធន៍ការដាក់ឈ្មោះនេះទេ។

២. ☐ [អាជ្ញាធរ] បានទទួលយកការដាក់ឈ្មោះនេះ និងគ្មានទទួលបានការជំទាស់ក្នុងរយៈពេលដែលបានកំណត់ បន្ទាប់ពីបោះពុម្ពផ្សាយ។

៣. ☐ ពូជដំណាំនេះត្រូវបានចុះបញ្ជីក្នុងឈ្មោះនេះ លើ................................................

៤. ☐ ការបោះពុម្ពលើកដំបូង ជាការដាក់ឈ្មោះដែលបានស្នើក្នុង..................................

